UNODC
United Nations Office on Drugs and Crime

UN WOMEN

# មេរៀនទី១

# ការយល់ដឹងអំពី យេនឌ័រសម្រាប់ ក្រុមមន្ត្រីជួរមុខ និង ក្រុមការងារអនុវត្តច្បាប់

សៀវភៅណែនាំសម្រាប់អ្នកសម្របសម្រួល

មេរៀនទី១

# ការយល់ដឹងអំពី យេនឌ័រសម្រាប់ ក្រុមមន្ត្រីជួរមុខ និង ក្រុមការងារអនុវត្តច្បាប់

ទស្សនៈដែលបានបង្ហាញនៅក្នុងអត្ថបទបោះពុម្ពផ្សាយនេះ គឺជាទស្សនៈផ្ទាល់របស់អ្នកនិពន្ធ ហើយមិនមែនតំណាងឲ្យទស្សនៈរបស់អង្គការ UNODC អង្គការ UN Women អង្គការសហប្រជាជាតិ ឬអង្គការចំណុះណាមួយរបស់អង្គការសហប្រជាជាតិឡើយ។

---

(នេះមិនមែនជាឯកសារផ្លូវការរបស់អង្គការសហប្រជាជាតិទេ។ កំណត់សម្គាល់ដែលត្រូវបានប្រើប្រាស់ និងការបង្ហាញអំពីឧបករណ៍នានាក្នុងឯកសារនេះ មិនមែនជាការបង្ហាញនូវទស្សនៈយល់ឃើញណាមួយរបស់លេខាធិការដ្ឋាននៃការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងឧក្រិដ្ឋកម្ម (United Nations Office on Drugs and Crime) ឬអង្គការ UN Women ទាក់ទងនឹងស្ថានភាពគតិយុត្តនៃប្រទេស ដែនដី ក្រុង ឬតំបន់ អាជ្ញាធរណាមួយនៃតំបន់ទាំងនោះ ឬទាក់ទងនឹងការកំណត់ខ្សែបន្ទាត់ព្រំដែន និងព្រំដែនរបស់ខ្លួននោះឡើយ)។

---

អង្គការ UNODC និង UN Women សូមថ្លែងអំណរគុណចំពោះសំណូមពរ និងការរួមវិភាគទានដ៏ថ្លៃថ្លាពីសំណាក់អ្នកជំនាញបច្ចេកទេស និងបុគ្គលិករបស់ UNODC និង UN Women ដែលបានរួមចំណែកក្នុងការផលិត និងសម្របសម្រួលរៀបចំសៀវភៅណែនាំនេះឡើង។

សៀវភៅណែនាំនេះរៀបរៀងឡើងដោយលោកស្រី Stephanie Hills ជាអ្នកជំនាញឯកទេសផ្នែកកម្មវិធីសិក្សា ពិនិត្យកែសម្រួល និងមើលកែតម្រូវដោយលោកស្រី Mary Ann Perkins ជាអ្នកពិនិត្យកែសម្រួល/មើលកែតម្រូវមាតិកាបច្ចេកទេស និងកម្មវិធីគ្រប់គ្រងព្រំដែនរបស់ UNODC ។

អង្គការ UNODC និង UN Women សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការរួមវិភាគទានរបស់រដ្ឋជាសមាជិកហូតធ្វើឱ្យការរៀបចំសៀវភៅណែនាំនេះដំណើរការទៅបាន។

---

គម្រោងនេះត្រូវបានផ្តល់ហិរញ្ញប្បទានក្រោមការឧបត្ថម្ភសប្បុរសធម៌ពីសំណាក់រដ្ឋាភិបាលកាណាដា។

Canada

© រក្សាសិទ្ធិឆ្នាំ២០២១ ដោយការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងឧក្រិដ្ឋកម្ម (UNODC) និងអង្គការលើកកម្ពស់សមភាពយេនឌ័រ និងការផ្តល់ភាពអង់អាចដល់ស្ត្រី (UN Women)។ អត្ថបទបោះពុម្ពផ្សាយនេះអាចផលិតឡើងវិញទាំងស្រុង ឬមួយផ្នែក និងក្នុងទម្រង់ណាមួយបាន សម្រាប់គោលបំណងអប់រំ ឬមិនស្វែងរកប្រាក់កម្រៃ ដោយមិនចាំបាច់មានការអនុញ្ញាតពិសេសពីម្ចាស់សិទ្ធិអ្នកនិពន្ធ ប្រសិនបើមានការបញ្ជាក់ពីប្រភព។ អង្គការ UNODC និង UN Women រីករាយនឹងទទួលបានច្បាប់ចម្លងនៃអត្ថបទបោះពុម្ពផ្សាយណាមួយដែលប្រើអត្ថបទបោះពុម្ពផ្សាយនេះជាប្រភព តាមរយៈអ៊ីមែលunodc-thailandfieldoffice@un.org, info.bangkok@unwomen.org

រូបថតនៅគម្របសៀវភៅ UNODC/ UN Women/ Ploy Phutpheng (ផ្លូយ ភុតផេង)

UNODC
United Nations Office on Drugs and Crime

ការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងឧក្រិដ្ឋកម្ម (UNODC) ធ្វើការជាមួយរដ្ឋជាសមាជិកទូទាំងពិភពលោកដើម្បីដោះស្រាយបញ្ហាគំរាមកំហែងដោយសារគ្រឿងញៀន ឧក្រិដ្ឋកម្ម និងភេរវកម្ម។ នៅតំបន់អាស៊ីអាគ្នេយ៍ អង្គការរបស់យើងស្ថិតនៅទីតាំងដ៏ពិសេសដើម្បីគាំទ្រដល់ក្របខ័ណ្ឌអាស៊ានក្នុងការដោះស្រាយបញ្ហាប្រឈមនានាដោយសារឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំង និងលើកកម្ពស់យុត្តិធម៌ និងនីតិរដ្ឋ។ កិច្ចខិតខំប្រឹងប្រែងពហុភាគីទាំងនេះបង្កើតបានជាមូលដ្ឋានគ្រឹះមួយសម្រាប់កិច្ចសហប្រតិបត្តិការក្នុងតំបន់លើបញ្ហាសេដ្ឋកិច្ច សង្គម នយោបាយ និងសន្តិសុខ។

ជាមួយបទពិសោធន៍ការងារដ៏ទូលំទូលាយរបស់ខ្លួនសំដៅពង្រឹងកិច្ចសហប្រតិបត្តិការផ្នែកនយោបាយ និងសន្តិសុខក្នុងតំបន់ឲ្យកាន់តែរឹងមាំ អង្គការ UNODC គឺជាជម្រើសដ៏ស័ក្តិសមមួយសម្រាប់ដឹកនាំការអនុវត្តសេចក្តីប្រកាសរួមស្តីពីភាពជាដៃគូគ្រប់ជ្រុងជ្រោយរវាងអាស៊ាន និងអង្គការសហប្រជាជាតិ។ UNODC បានធ្វើការស្រាវជ្រាវ និងបង្កើតក្របខ័ណ្ឌជំនួយបច្ចេកទេសសំដៅគាំទ្រដល់បណ្តារដ្ឋជាសមាជិកប្រកបដោយប្រសិទ្ធភាព លើការលើកកម្ពស់សមភាពយេនឌ័រ និងការផ្តល់ភាពអង់អាចដល់ស្ត្រីនៅក្នុងសសរស្តម្ភទាំងបីនៃសហគមន៍អាស៊ាន។

UNODC ទទួលស្គាល់ថា សមភាពយេនឌ័រ និងការផ្តល់ភាពអង់អាចដល់ស្ត្រី និងក្មេងស្រីនឹងរួមចំណែកជាសារវន្តដល់ដំណើរវិវត្តនៅគ្រប់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។ តាមរយៈសកម្មភាពកសាងសមត្ថភាពរបស់យើងយើងបាន និងកំពុងធ្វើការបង្កើនការចូលរួម និងភាពជាអ្នកដឹកនាំរបស់មន្ត្រីជាស្ត្រីនៅតាមទីភ្នាក់ងារអនុវត្តច្បាប់។ លើសពីនេះទៀត សកម្មភាពទាំងនេះជួយឱ្យមន្ត្រីជួរមុខអាចបំពេញតម្រូវការរបស់ស្ត្រី និងក្មេងស្រីបានល្អប្រសើរ

---

UN WOMEN

អង្គការលើកកម្ពស់សមភាពយេនឌ័រ និងការផ្តល់ភាពអង់អាចដល់ស្ត្រី (UN Women) គឺជាស្ថាប័នមួយរបស់អង្គការសហប្រជាជាតិ ដែលប្តេជ្ញាសម្រេចឱ្យបាននូវសមភាពយេនឌ័រ និងការផ្តល់ភាពអង់អាចដល់ស្ត្រី។ អង្គការ UN Women គាំទ្រដល់បណ្តារដ្ឋជាសមាជិករបស់អង្គការសហប្រជាជាតិ ដោយបានកំណត់បទដ្ឋានសកលដើម្បីសម្រេចបាននូវសមភាពយេនឌ័រ ក៏ដូចជាធ្វើការជាមួយរដ្ឋាភិបាល និងសង្គមស៊ីវិលក្នុងការរៀបចំបង្កើតច្បាប់ គោលនយោបាយ កម្មវិធី និងសេវាចាំបាច់នានា សំដៅធានាបាននូវការអនុវត្តបទដ្ឋានប្រកបដោយប្រសិទ្ធភាព និងផ្តល់ផលប្រយោជន៍ពិតប្រាកដដល់ស្ត្រី និងក្មេងស្រីទូទាំងពិភពលោក។ អង្គភាពនេះធ្វើការជាសកលដើម្បីធ្វើឱ្យចក្ខុវិស័យនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពក្លាយទៅជាការពិតសម្រាប់ស្ត្រី និងក្មេងស្រី និងគាំទ្រដល់ការចូលរួមដោយស្មើភាពរបស់ស្ត្រីនៅក្នុងគ្រប់ទិដ្ឋភាពទាំងអស់នៃជីវិត។ អង្គការប្រើប្រាស់បទពិសោធន៍នៅតាមប្រទេសនានា ដើម្បីជាមូលដ្ឋានមួយនៃការឯកភាពយល់ព្រមលើបទដ្ឋានសមភាពយេនឌ័រថ្មី ហើយតាមរយៈទំនាក់ទំនងរបស់ខ្លួននៅទូទាំងអង្គការ សហប្រជាជាតិ បានដាក់បញ្ចូលសមភាពយេនឌ័រជាធាតុស្នូលមួយនៃសសរស្តម្ភទាំងបីនៃដំណើរវិវត្តន៍ជាសកល ពោលគឺសន្តិភាពនិងសន្តិសុខ សិទ្ធិមនុស្ស និងការអភិវឌ្ឍប្រកបដោយចីរភាព។ អង្គការ UN Women ក៏បានសម្របសម្រួលនិងលើកកម្ពស់ការងាររបស់ប្រព័ន្ធសហប្រជាជាតិផងដែរ ក្នុងការជំរុញសមភាពយេនឌ័រ និងនៅក្នុងការពិភាក្សា និងកិច្ចព្រមព្រៀងទាំងទាំងឡាយពាក់ព័ន្ធនឹងរបៀបវារៈឆ្នាំ២០៣០ ។

# មាតិកា


| | |
|---|---|
| ទិដ្ឋភាពទូទៅ | ៥ |
| ការរៀបចំកម្មវិធីបណ្តុះបណ្តាល | ៧ |
| ទម្រង់នៃកម្មវិធីបណ្តុះបណ្តាល | ១២ |
| សេចក្តីណែនាំសម្រាប់ផ្តល់ការបណ្តុះបណ្តាល | ១៤ |
| សេចក្តីសង្ខេបអំពីមេរៀន | ២៤ |
| **ថ្ងៃទីមួយ** | ២៨ |
| ម៉ោងសិក្សាទីមួយ៖ ការកំណត់និយមន័យយេនឌ័រ | ២៨ |
| ម៉ោងសិក្សាទីពីរ៖ អាកប្បកិរិយា និងលទ្ធផលដែលទាក់ទងនឹងយេនឌ័រ | ៣៤ |
| ម៉ោងសិក្សាទីបី៖ ការប្រាស្រ័យទាក់ទងក្នុងសង្គមទៅតាមយេនឌ័រ | ២៩ |
| ម៉ោងសិក្សាទីបួន៖ ការប្រាស្រ័យទាក់ទងក្នុងសង្គមទៅតាមយេនឌ័រ និងបិតុនិយម | ៤៣ |
| **ថ្ងៃទីពីរ** | ៥០ |
| ម៉ោងសិក្សាទីមួយ៖ ទំនោរផ្លូវភេទ និងអត្តសញ្ញាណកម្មភេទ | ៥០ |
| ម៉ោងសិក្សាទីពីរ៖ អន្តរទំនាក់ទំនង និងយេនឌ័រ | ៥៥ |
| ម៉ោងសិក្សាទីបី៖ ការធើសអើងយេនឌ័រ | ៦២ |
| ម៉ោងសិក្សាទីបួន៖ បរិបទនៃការធើសអើង | ៦៧ |
| **ថ្ងៃទីបី** | ៧០ |
| ម៉ោងសិក្សាទីមួយ៖ ការរំលោភបំពាន និងអំពើហិង្សាយេនឌ័ | ៧០ |
| ម៉ោងសិក្សាទីពីរ៖ ការប្រែប្រួលនៃអំណាចដែលស្ថិតនៅពីក្រោយការរំលោភបំពាន /អំពើហិង្សាយេនឌ័រ (GBA/GBV) | ៧៧ |
| ម៉ោងសិក្សាទីបី៖ ក្របខណ្ឌច្បាប់ និងដំណោះស្រាយសម្រាប់យេនឌ័រផ្អែក លើមូលដ្ឋានសិទ្ធិ | ៨៥ |
| ម៉ោងសិក្សាទីបួន៖ ការរំឭកមេរៀន និងការបង្កើតផែនការសកម្មភាព ១៩ | ៩៩ |
| **ឧបសម្ព័ន្ធ៖ សម្ភារៈបណ្តុះបណ្តាល** | ១០២ |
| ១.១.១ យេនឌ័រ និងភេទ | ១០៣ |
| ១.១.២ កញ្ចប់សកម្មភាពស្តីពី សម្ភារៈ សកម្មភាព និងតួអង្គ | ១០៤ |
| ១.២.១ កញ្ចប់សកម្មភាពស្តីពី គុណភាព អារម្មណ៍ និងអាកប្បកិរិយានៃយេនឌ័រ | ១២០ |
| ១.៤.១ ផ្នាំងកាតឥទ្ធិពល | ១២៣ |
| ២.១.១ និយមន័យ អ្នកស្រលាញ់ភេទដូចគ្នា ឬ LGBTI+ | ១២៨ |
| ២.២.១ កាតតួអង្គ | ១២៩ |
| ២.២.២ ការកំណត់គោលដៅ | ១៣០ |
| ៣.១.១ ប្រភេទហិង្សាយេនឌ័រ | ១៣១ |
| ៣.២.១ កិច្ចការ អំណាច និងការត្រួតត្រា | ១៣៩ |
| ៣.៣.១ CEDAW | ១៤០ |
| ៣.៤.១ សំណួរឆ្លុះបញ្ចាំងអំពីការធ្វើផែនការសកម្មភាព | ១៤៤ |

# ទិដ្ឋភាពទូទៅ

មេរៀនទាំង៣ ដែលស្ថិតនៅក្នុងកម្មវិធីបណ្តុះបណ្តាលនេះ គាំទ្រដល់ចំណាត់ការនានារបស់ទីភ្នាក់ងារអនុវត្តច្បាប់ ក្នុងការពង្រឹងសមត្ថភាពទូទៅរបស់មន្ត្រីត្រួតពិនិត្យតាមព្រំដែន និងប្រសិទ្ធភាព នៅក្នុងការឆ្លើយតបទៅនឹងអំពើហិង្សាទាក់ទងនឹង យេនឌ័រ និងការជួញដូរស្ត្រីនិងកុមារី។ ខ្លឹមសារនៅក្នុងកម្មវិធីបណ្តុះបណ្តាលនេះមានបំណងធ្វើការបញ្ជ្រាបយេនឌ័រនៅរាល់ការបណ្តុះបណ្តាលទាំងអស់ ដើម្បីទទួលបានចំណេះដឹង និងជំនាញនានា។

## គោលបំណង

គោលបំណងនៃមេរៀនទាំងបីនេះ គឺដើម្បីបង្កើនសមត្ថភាពរបស់ក្រុមការងារអនុវត្តច្បាប់តាមវិធីគ្រប់ជ្រុងជ្រោយចំនួនពីរ៖

១. ផ្តល់ការគាំទ្រដល់ក្រុមការងារអនុវត្តច្បាប់ ឱ្យមានការឆ្លើយតបប្រកបដោយបរិយាប័ន្ចំពោះបញ្ហាយេនឌ័រ នៅក្នុងប្រតិបត្តិការរាល់ថ្ងៃរបស់ពួកគេ ទាំងក្នុងការិយាល័យ និងក្រោយពេលធ្វើការ។

២. បង្កើនសមត្ថភាពរបស់ក្រុមការងារអនុវត្តច្បាប់ ក្នុងការអនុវត្តការងារស៊ើបអង្កេត ដែលឆ្លើយតបនឹងបញ្ហា យេនឌ័រ ចំពោះសកម្មភាពជួញដូរមនុស្ស (THB) និងសកម្មភាពឧក្រិដ្ឋកម្មដទៃទៀត។

## វត្ថុបំណងនៅពេលបញ្ចប់ការបណ្តុះបណ្តាល

វត្ថុបំណងជារួមក្រោយពេលបញ្ចប់ការបណ្តុះបណ្តាលនៃមេរៀនទាំងនេះរួមមានដូចខាងក្រោម៖

១. បង្កើនការយល់ដឹងអំពីយេនឌ័រនៅក្នុងចំណោមមន្ត្រីជួរមុខ និងក្រុមការងារអនុវត្តច្បាប់

២. ជំរុញការអនុវត្តការស៊ើបអង្កេតជាមួយជនងាយរងគ្រោះ (រួមមានជនរងគ្រោះ និងការជួញដូរមនុស្ស) ដែលប្រតិបត្តិការនោះមានការឆ្លើយតបនឹង យេនឌ័រ

៣. បង្កើនបរិយាកាសការងារដែលមានការឆ្លើយតបនឹងយេនឌ័រច្រើនជាងមុន។ ជាពិសេស ផ្តល់ការគាំទ្រដល់សុខមាលភាពរបស់បុគ្គលិក និង ធ្វើឲ្យសមាជិកក្រុមការងារគ្រប់រូបមានទំនុកចិត្ត និងមានសមត្ថភាពនៅក្នុងការអភិវឌ្ឍ និងធ្វើឲ្យមានភាពរីកចម្រើននៅក្នុងតួនាទីរបស់ពួកគេ។

## មេរៀន

មេរៀនទាំងបី រួមមានដូចខាងក្រោម៖

មេរៀនទី ១៖ ការយល់ដឹងអំពីយេនឌ័រសម្រាប់ក្រុមមន្ត្រីជួរមុខ និងក្រុមការងារអនុវត្តច្បាប់ [1]

មេរៀនទី ២៖ ការស៊ើបអង្កេតដែលឆ្លើយតបចំពោះបញ្ហាយេនឌ័រសម្រាប់ ជនរងគ្រោះនៃអំពើជួញដូរមនុស្ស និងជនងាយរងគ្រោះដទៃទៀត

មេរៀនទី ៣៖ ការថែទាំខ្លួន ការអភិវឌ្ឍខ្លួន និងការបង្កើនការធ្វើការងារជាក្រុម ដែលឆ្លើយតបចំពោះបញ្ហាយេនឌ័រសម្រាប់ក្រុមការងារអនុវត្តច្បាប់

## សិក្ខាកាមគោលដៅ

កម្មវិធីបណ្តុះបណ្តាលនេះត្រូវបានបង្កើតឡើង សម្រាប់ក្រុមសិក្ខាកាម ដែលមានសិក្ខាកាមអប្បរិមា ២០ នាក់ សម្រាប់មន្ត្រីអនុវត្តច្បាប់កម្រិតទាប ដល់កម្រិតមធ្យម។ ដើម្បីសម្រេចបាននូវវត្ថុបំណងនៃការផ្លាស់ប្តូរដូចមានចែងនៅក្នុងមេរៀនទាំងនេះ យើងណែនាំថា វគ្គបណ្តុះបណ្តាលនីមួយៗគួរតែមានសិក្ខាកាមជាបុរស និងស្ត្រី ហើយក្នុងនោះគួរតែមានយ៉ាងហោចណាស់ ៣៥%ជាស្ត្រី ។ ពេលវេលា និងទីកន្លែងរបស់វគ្គបណ្តុះបណ្តាល គួរតែបានរៀបចំទុកជាមុន ដើម្បីឲ្យស្ត្រីងាយស្រួលចូលរួមស្របតាមកាលៈទេសៈ និងបរិបទវប្បធម៌។

# ការរៀបចំកម្មវិធីបណ្តុះបណ្តាល

រូបភាព: UNODC/ UN Women/ Ngoc Le

កម្មវិធីបណ្តុះបណ្តាលត្រូវបានរៀបចំឡើងដើម្បីបំពេញតម្រូវការរបស់អ្នករៀនសូត្រ ដោយផ្តោតលើវិធីសាស្ត្ររៀនចំនួន ៣ សំខាន់ៗ រួមមាន ការរៀនសូត្រតាមរយៈចក្ខុវិញ្ញាណ សោតវិញ្ញាណ និងការធ្វើសកម្មភាពផ្លូវកាយ (ការរៀនសូត្រតាមរយៈកាយវិញ្ញាណ)។ វិធីសាស្ត្ររួមបញ្ចូលគ្នាមួយត្រូវបានប្រើប្រាស់ ដោយរួមមាន៖

- ការធ្វើបទបង្ហាញដោយផ្ទាល់ (ផ្ទាល់ភ្នែក)
- ករណីសិក្សា
- ការសួរសំណួរដែលមានភាពឆ្លុះបញ្ចាំង
- ការងារប្រាស្រ័យទាក់ទងគ្នាជាក្រុមដែលអភិវឌ្ឍបន្ថែមលើជំនាញជាច្រើនខុសៗគ្នា ដូចជាការវិភាគយ៉ាងដិតដល់ការដោះស្រាយបញ្ហា និងការរៀនសូត្រពីមិត្តភ័ក្តិ/ការចែករំលែក។

## ការសម្របសម្រួលដែលឆ្លើយតបនឹងយេនឌ័រ

កម្មវិធីបណ្តុះបណ្តាលនេះ គាំទ្រដល់វិធីសាស្ត្រនៃការចូលរួមដែលឆ្លើយតបទៅនឹងយេនឌ័រ ហើយកែសម្រួលគោលការណ៍សំខាន់ៗនៃការរៀនសូត្ររបស់មនុស្សពេញវ័យ ដូចត្រូវបានកំណត់ដោយ «គោលការណ៍នៃការរៀនសូត្ររបស់មនុស្សពេញវ័យ» របស់ Malcolm Knowles តាមរយៈការពិនិត្យលើបញ្ហាយេនឌ័រ។ នៅក្នុងការអនុវត្តវិធីសាស្ត្រនេះ អ្នកសម្របសម្រួលគួរតែផ្តោតលើចំណុចនានាដូចខាងក្រោម៖

មនុស្សពេញវ័យមានភាពស្វយ័ត និងចេះកំណត់ទិសដៅដោយខ្លួនឯង៖ គ្រូបណ្តុះបណ្តាលគួរតែដើរតួជាអ្នកសម្របសម្រួល ដោយគាំទ្រឲ្យសិក្ខាកាម (អ្នករៀនសូត្រ) ក្លាយជាដៃគូដែលសកម្មនៅក្នុង «ដំណើរនៃការរៀនសូត្រ» នៃវគ្គបណ្តុះបណ្តាលនេះ។ សកម្មភាពនានាត្រូវបានរៀបចំឡើងដើម្បីធ្វើឲ្យវិធីសាស្ត្រនេះអាចអនុវត្តទៅបានតាមរយៈការដោះស្រាយបញ្ហាជាក្រុម ការវិភាគ និងលើកទឹកចិត្តឲ្យមានការរៀនសូត្រពីមិត្តភ័ក្តិតាមរយៈការធ្វើបទបង្ហាញជាក្រុម។

វិធីសាស្ត្រនេះតម្រូវឲ្យសិក្ខាកាមមានអារម្មណ៍ថា ត្រូវបានលើកទឹកចិត្តនៅក្នុងការធ្វើសកម្មភាពទាំងនោះ ដែលធ្វើឲ្យពួកគាត់មានអារម្មណ៍សុវត្ថិភាព មិនភ័យខ្លាច និងមានទំនុកចិត្តនៅក្នុងការចែករំលែកគំនិត ទស្សនៈរបស់ពួកគេ និងហ៊ានសួរសំណួរ។ ទោះបីជាយ៉ាងណាក៏ដោយ ក្នុងការអនុវត្តនៃបញ្ហាបចំនេះដឹងពីសក្តានុពលរបស់យេនឌ័រនៅក្នុង បរិបទវប្បធម៌ និងវិជ្ជាជីវៈ អាចបង្ហាញថា បុគ្គលមួយចំនួនប្រហែលជាពុំមានទំនុកចិត្តនៅក្នុងការធ្វើសកម្មភាពទាំងនេះនោះទេ។ ឧទាហរណ៍៖ នៅក្នុងបន្ទប់បណ្តុះបណ្តាលមួយ ដែលភាគច្រើនជាមនុស្សប្រុស មនុស្សស្រីអាចមានអារម្មណ៍ភ័យខ្លាចនៅក្នុងការចែករំលែកគំនិតរបស់ពួកគេ។ ឧទាហរណ៍មួយផ្សេងទៀតអាចជា នៅក្នុងបរិបទវប្បធម៌ និងវិជ្ជាជីវៈដែលមានលក្ខណៈបិតុនិយម សិក្ខាកាមដែលជាបុរសប្រហែលជាមានអារម្មណ៍ទើសទាល់នៅក្នុងការពិភាក្សាអំពីប្រធានបទនានា ដែលតម្រូវឲ្យការឆ្លុះបញ្ចាំងអំពីអារម្មណ៍ផ្ទាល់ខ្លួននៅក្នុងកម្រិតណាមួយ។

អ្នកសម្របសម្រួលគួរតែធ្វើការពិចារណាអំពីចំនុចសំខាន់ទាំងនេះមុនពេលបណ្តុះបណ្តាល តាមរយៈ៖

### ១. ការស្វែងយល់អំពីប្រវត្តិរូបរបស់ក្រុមសិក្ខាកាម

ក. មានការយល់ដឹងពីបរិបទវប្បធម៌នៅទីតាំងដែលនឹងធ្វើការបណ្តុះបណ្តាល និងកត្តាដែលអាចជះឥទ្ធិពលដល់ការស្វែងយល់របស់សិក្ខាកាមដែលចូលរួម

ខ. ប្រសិនបើអាចធ្វើបាន ការដំណើរការការបណ្តុះបណ្តាល ដែលឆ្លើយតបនឹងយេនឌ័រមួយតម្រូវឲ្យមានការវាយតម្លៃ ដើម្បីប្រមូលព័ត៌មានស្តីពីគោលដៅនិងការរំពឹងទុករបស់សិក្ខាកាមចំពោះការបណ្តុះបណ្តាលនោះ ព្រមទាំងព័ត៌មានស្តីពីបទពិសោធន៍កាលពីមុនរួមទាំងលក្ខណៈសម្បត្តិ។ល។ ផងដែរ។ អ្នកមានបទពិសោធន៍ អាចផ្តល់ព័ត៌មានបន្ថែមក្នុងករណីមានការកែសម្រួលខ្លឹមសារមេរៀន និងការរៀបពិនិត្យ និងគ្រប់គ្រងលើ

ការរំពឹងទុករបស់សិក្ខាកាម។ សម្រាប់សិក្ខាកាមដែលចូលរួមថ្មីវិញ អាចជាកត្តាបន្ថែមមួយដ៏ល្អក្នុងការលើកទឹកចិត្ត សិក្ខាកាមដែលមានបទពិសោធន៍ខុសៗគ្នាឲ្យធ្វើការជាមួយគ្នាកាន់តែប្រសើរជាងមុន។ មិនតែប៉ុណោះ កាលដែលប្រមូលព័ត៌មានស្តីពីគោលដៅ និងការរំពឹងទុករបស់សិក្ខាកាម ចំពោះការបណ្តុះបណ្តាលនោះក៏អាចធ្វើឲ្យ អ្នកចូលរួមមានអារម្មណ៍ថាបទពិសោធន៍ ដែលខ្លួនមានត្រូវបានគេទទួលស្គាល់ ដែលទាំងនេះគឺជាកត្តាគាំទ្រដល់ការបង្កើនទំនុកចិត្តក្នុងការចែករំលែកបន្ថែម។

គ. ការប្រមូលការរំពឹងទុកនិងយោបល់ផ្សេងៗរបស់សិក្ខាកាមលើវគ្គបណ្តុះបណ្តាលគួរតែត្រូវបានធ្វើឡើង និងកំនត់សម្គាល់ដើម្បីរកដំណោះស្រាយមុនចាប់ផ្តើមវគ្គបណ្តុះបណ្តាលនីមួយៗ។

## ២.បង្កើតយុទ្ធសាស្ត្រដោយរួមបញ្ចូលគ្នា

ក. នៅក្នុងកម្មវិធីបើកវគ្គបណ្តុះបណ្តាលគួរតែមាន «វិធានមូលដ្ឋាន» មួយដែលយល់ស្របដោយសិក្ខាកាម។[២] អ្នកសម្របសម្រួលគួរតែបញ្ជាក់អំពីសារៈសំខាន់របស់ស្ត្រីនៅក្នុងការចែករំលែកគំនិត និងចំណេះដឹងរបស់ពួកគេនៅក្នុងវគ្គបណ្តុះបណ្តាលនេះទាំងមូល។

ខ. អ្នកសម្របសម្រួលគួរតែបន្តផ្តោត និងពិនិត្យលើប្រពលភាពនៅទីកន្លែងវគ្គបណ្តុះបណ្តាល ជាពិសេសប្រពលភាពដែលពាក់ព័ន្ធនឹងយេនឌ័រ។ ការដឹងអំពីបុគ្គលិកលក្ខណៈខុសៗគ្នា និងរបៀបដែលពួកគេធ្វើប្រស្រ័យទាក់ទងគ្នាទៅវិញទៅមក ដើម្បីអាចឲ្យងាយសន្និដ្ឋាន បានថាតើមានយុទ្ធសាស្ត្រអ្វីខ្លះ ដែលអាចត្រូវយកមកប្រើប្រាស់។ ឧទាហរណ៍៖ ការលើកទឹកចិត្តសិក្ខាកាម ដែលមានភាពស្មៀមស្ងាត់ជាងគេឲ្យមានទំនាក់ទំនងជាមួយអ្នកដទៃ ដោយប្រើ ពាក្យសម្តីទន់ភ្លន់ តាមរយៈការសួរសំណួរទៅកាន់ពួកគេ ដូច្នេះពួកគេនឹងមានទំនុកចិត្តថា ពួកគេនឹងអាចធ្វើការឆ្លើយតបនឹងសំណួរនោះបាន ឬក៏អាចផ្តល់ជូនពួកគេនូវតួនាទីណាមួយ ដូចជាការធ្វើជាអ្នកកត់ត្រានៅក្នុងការធ្វើសកម្មភាពជាក្រុម ជាដើម។

គ. អ្នកសម្របសម្រួលអាចប្រើប្រាស់វិធីសាស្ត្រផ្សេងៗ ដោយឲ្យសិក្ខាកាមបង្កើតបែងចែកជាក្រុមតូចៗ ដែលផ្តល់ឱកាសដល់ពួកគាត់អាចធ្វើការជាមួយអ្នកដ៏ទៃនៅក្នុងវគ្គបណ្តុះបណ្តាលទាំងមូល។ ឧទាហរណ៍

i. ឲ្យអ្នកទាំងអស់គ្នារាប់ពី ១ ទៅ ៤ បន្ទាប់មកស្នើសុំឲ្យ«អ្នកដែលមានលេខ១» ទាំងអស់ធ្វើការជាមួយគ្នា ហើយ«អ្នកដែលមានលេខ២»ទាំងអស់ធ្វើការជាមួយគ្នា។ល។

ii. ឬឲ្យសិក្ខាកាមរៀបជាជួរដោយផ្អែកលើកត្តាដូចជា តើផ្ទះពួកគាត់នៅចម្ងាយ

[២] មើល «សេចក្តីណែនាំសម្រាប់ផ្តល់ការបណ្តុះបណ្តាល» រួមបញ្ចូលទាំង ច្បាប់នានានៃការជំរុញនិងលើកទឹកចិត្ត

ប៉ុន្មានពីទីតាំងវគ្គបណ្តុះបណ្តាល? (រៀបជាជួរពីទីឆ្ងាយមកទីជិត) ឬក៏ឲ្យរៀបជាជួរតាមថ្ងៃខែកំណើតរបស់ពួកគាត់ (ពីខែមករាដល់ខែធ្នូ)។ បន្ទាប់មកអ្នកសម្របសម្រួលអាចចែកពួកគាត់ជាក្រុមតូចៗ ដោយមានគ្នា៤នាក់ ដោយរាប់ចាប់ពីខាងមុខមក។ ឧទាហរណ៍ អាចចាប់ក្រុបដោយ ឲ្យ៤នាក់ដំបូងជាក្រុមទី១ ៤នាក់បន្ទាប់ជាក្រុមទី២ ។ល។

**មនុស្សពេញវ័យ ពួកគាត់មានចំណេះដឹង និងបទពិសោធន៍ជីវិត ជាច្រើនដែលអាចចែករំលែងនៅក្នុងវគ្គបណ្តុះបណ្តាលនេះ៖** កម្មវិធីបណ្តុះបណ្តាលត្រូវបានរៀបចំឡើងដើម្បីលើកទឹកចិត្តសិក្ខាកាមឲ្យធ្វើការឆ្លុះបញ្ចាំង និងចែករំលែកបទពិសោធន៍ និងគំនិតរបស់ពួកគេ នៅពេលដែល ឬក៏ប្រសិនបើពួកគេមានអារម្មណ៍សុវត្ថិភាពនៅក្នុងការចែករំលែកបទពិសោធន៍ និងចំណេះដឹងទាំងនោះ។

**មនុស្សពេញវ័យ ពួកគាត់គឺផ្តោតលើគោលដៅ៖** របៀបវារៈនៃវគ្គបណ្តុះបណ្តាលនីមួយៗ ទិដ្ឋភាពទូទៅនឹងបង្ហាញឡើងក្នុងពេលចាប់ផ្តើមនៃវគ្គបណ្តុះបណ្តាលនោះ។ ដូចគ្នានេះដែរវត្ថុបំណងរបស់វគ្គសិក្សា គួរតែត្រូវបានពន្យល់នៅពេលចាប់ផ្តើមនៃម៉ោងសិក្សានីមួយៗរៀងៗគ្នា។ ការដែលយើងតែងតែបង្ហាញសិក្ខាកាម ពីអ្វីដែលពួកគាត់អាចសិក្សាបន្ថែមពីមេរៀននីមួយៗជាមុន វានឹងធ្វើឲ្យពួកគាត់ដឹងច្បាស់ថាពួកគាត់នឹងទទួលបានអ្វីនៅចុងបញ្ចប់នៃមេរៀន។

**មនុស្សពេញវ័យ ពួកគាត់គឺផ្តោតលើភាពពាក់ព័ន្ធគ្នា៖** កម្មវិធីបណ្តុះបណ្តាល និងកំណត់សម្គាល់នានារបស់អ្នកសម្របសម្រួល នឹងបង្ហាញពីភាពឆ្លុះបញ្ចាំងបន្ថែមអំពីរបៀប ដែលខ្លឹមសារនៃការបណ្តុះបណ្តាលនេះមានទំនាក់ទំនងជាមួយសិក្ខាកាម ទាំងតាមរយៈទស្សនៈវិស័យយេនឌ័រ និងនៅក្នុងតួនាទីក្នុងផ្នែកវិជ្ជាជីវៈរបស់ពួកគេផងដែរ។ អ្នកសម្របសម្រួលក៏គួរតែស្វែងរកឱកាសផ្សេងៗទៀតដើម្បីសាកសួរសិក្ខាកាម អំពីរបៀបដែលខ្លឹមសារនៃការបណ្តុះបណ្តាលអាចនេះមានទំនាក់ទំនងនឹងការងាររបស់ពួកគេ និងរបៀបដែលពួកគេនឹងយកខ្លឹមសារទាំងនោះទៅអនុវត្តផងដែរ។

ដើម្បីឲ្យសិក្ខាកាមមានអារម្មណ៍ថាការបណ្តុះបណ្តាលសំខាន់ និងមានតម្លៃស័ក្តិសមនឹងការចំណាយពេលវេលា ពិសេសគឺការចូលរួមចំណែករបស់ពួកគេ យើងសូមណែនាំថា អ្នកសម្របសម្រួលគួរតែផ្តល់ជូនសិក្ខាកាមនូវឱកាស ក្នុងការផ្តល់មតិត្រឡប់ (feedback) នៅចុងបញ្ចប់នៃម៉ោងសិក្សាសម្រាប់ថ្ងៃនីមួយៗ។[៣] ការធ្វើបែបនេះ ផ្តល់ការគាំទ្រដល់អ្នកសម្របសម្រួលនៅក្នុងការពិនិត្យតាមដាន និងកែសម្រួលវគ្គសិក្សា ដើម្បីឆ្លើយតបទៅនឹងតម្រូវការបានយ៉ាងឆាប់រហ័ស។

**មនុស្សពេញវ័យ ពួកគាត់មានមានភាពជាក់ស្តែង៖** កម្មវិធីបណ្តុះបណ្តាលលើកទឹកចិត្តសិក្ខាកាមឲ្យគិតអំពីរបៀបដែលពួកគាត់យកការរៀនសូត្ររបស់ពួកគេទៅអនុវត្ត។ ចំណុចនេះអាចធ្វើទៅបានតាមរយៈការសួរសំណួរឆ្លុះបញ្ចាំង និងការសួរសំណួរជាក្រុម ព្រមទាំងកិច្ចការនានានៃការធ្វើផែនការសកម្មភាពផងដែរ។ លើកទឹកចិត្តសិក្ខាកាមឲ្យគិតអំពីបញ្ហាប្រឈមនៅក្នុងការយកការរៀនសូត្រទាំងនោះទៅអនុវត្ត ដែលរួមបញ្ចូលទាំងរបៀបដែលយេនឌ័រអាចជះឥទ្ធិពលលើបញ្ហាប្រឈមនានា

---

៣ ចូរមើលកំណត់សម្គាល់ស្តីពី «សេចក្តីណែនាំសម្រាប់ផ្តល់ការបណ្តុះបណ្តាល» ដែលបង្ហាញពីវិធីបិទកម្មវិធីរៀងរាល់ម៉ោងសិក្សា។

រូបភាព: UNODC/ UN Women

សម្រាប់សមាជិកក្រុមរបស់ពួកគាត់ និងវិធីដែលអាចយកឈ្នះលើបញ្ហាទាំងនេះបានផងដែរ។

ការបណ្តុះបណ្តាល គួរតែតែងទទួលបានការយល់ឃើញថាជាកាតាលីករ សម្រាប់ការអភិវឌ្ឍសមត្ថភាព ចំណុចសំខាន់ គឺលើកទឹកចិត្តសិក្ខាកាម ឲ្យបង្កើតផែនការសកម្មភាពសម្រាប់ការយកការរៀនសូត្រទាំងនោះទៅអនុវត្តនៅកន្លែងធ្វើការ និងធ្វើជាភ្នាក់ងារនៃការផ្លាស់ប្តូរ។

**អ្នករៀនសូត្រដែលជាមនុស្សពេញវ័យ គួរត្រូវតែទទួលបានការគោរព៖** ចំណុចនេះគួរត្រូវយកចិត្តទុកដាក់នៅក្នុងកម្មវិធីបណ្តុះបណ្តាល ព្រោះវគ្គនេះគឺធ្វើឡើងដើម្បីការផ្តល់ឱកាសជូនសិក្ខាកាម ធ្វើការចែករំលែកចំណេះដឹង និងបទពិសោធន៍របស់ពួកគាត់។ ទោះបីជាយ៉ាងណាក៏ដោយ ចំណុចនេះត្រូវបានដោះស្រាយជាចម្បងតាមរយៈវិធីសាស្ត្ររបស់អ្នកសម្របសម្រួល ក្នុងការស្វែងយល់អំពីតម្រូវការរបស់សិក្ខាកាមនៅក្នុងកន្លែងបណ្តុះបណ្តាល និងជំនាញ ដែលអ្នកសម្របសម្រួលយកមកអនុវត្តដើម្បីគ្រប់គ្រងស្ថានការណ៍នានា។ ឧទាហរណ៍៖ នៅពេលដែលសិក្ខាកាមណាមួយកាត់សម្តីអ្នកដទៃជាបន្តបន្ទាប់ ដើម្បីលើកឡើងអំពីចំណុចណាមួយនោះ ពួកគាត់គួរតែទទួលបានការដោះស្រាយដោយពាក្យសម្តីទន់ភ្លន់ ច្រើនជាងការស្តីបន្ទោស ពោលគឺ អ្នកសម្របសម្រួលអាចពន្យល់ថា ចំណុចដែលពួកគេបានលើកឡើងនោះ មានភាពសមស្រប ហើយអ្នកដែលកាត់សម្តីអ្នកដ៏ទៃនឹងអាចលើកឡើងអំពីចំណុចនោះបន្តទៀតបាន បន្ទាប់ពីបុគ្គលដែលត្រូវបានពួកគាត់កាត់សម្តីនោះ បានបញ្ចប់ការលើកឡើងរបស់គាត់រួចរាល់ហើយ។

# ទម្រង់នៃកម្មវិធីបណ្តុះបណ្តាល

រូបភាព: UNODC/ UN Women/ Ploy Phutpheng

ចំណុចខាងក្រោម នឹងបង្ហាញពីចំណុចដែលនឹងបញ្ចូលនៅក្នុងផ្នែកនីមួយៗនៃកម្មវិធីបណ្តុះបណ្តាល៖

**ទិដ្ឋភាពទូទៅនៃមេរៀន៖ ផ្នែកនេះផ្តល់ទិដ្ឋភាពទូទៅអំពីមេរៀន ដែលរួមមាន៖**

- គោលបំណងរបស់មេរៀន៖ សម្រេចបានគោលដៅសំខាន់របស់មេរៀន
- វត្ថុបំណងនៅពេលបញ្ចប់វគ្គបណ្តុះបណ្តាល៖ សម្រេចបានរាល់វត្ថុបំណងតាមគោលបំណងរបស់មេរៀន(បន្ទាប់មកវត្ថុបំណងទាំងនេះនឹងត្រូវបានវិភាគយ៉ាងលម្អិតនៅក្នុងវត្ថុបំណងដែលអាចអនុវត្តបាននៃម៉ោងសិក្សានីមួយៗ (មើលផ្នែកខាងក្រោម)។
- របៀបវារៈនៃវគ្គបណ្តុះបណ្តាល៖ ទិដ្ឋភាពទូទៅនៅក្នុងទម្រង់ជាតារាងពេលវេលា ស្តីពីរបៀបដែលមេរៀននីមួយៗនឹងត្រូវបានផ្តល់ជូនតាមថ្ងៃដែលបានរៀបចំទុក។

**ការសង្ខេបអំពីម៉ោងសិក្សា៖ ការសង្ខេបអំពីម៉ោងសិក្សានីមួយៗ គឺជាការបំបែកជាផ្នែកតូចៗនៃរបៀបដែលម៉ោងសិក្សានឹងត្រូវបានផ្តល់ជូននៅពេលចាប់ផ្តើមសង្ខេបត្រួសៗអំពីម៉ោងសិក្សានីមួយៗ នឹងមាន៖**

- គោលបំណងរបស់ម៉ោងសិក្សា៖ ផ្អែកលើវត្ថុបំណងនៅពេលបញ្ចប់ការបណ្តុះបណ្តាលរបស់មេរៀន។
- វត្ថុបំណងរបស់ម៉ោងសិក្សា៖ វត្ថុបំណងនៃការ រៀនសូត្រជាច្រើន ដើម្បីសម្រេចបាននូវគោល បំណងរបស់ម៉ោងសិក្សា។
- ពេលវេលា៖ ពេលវេលាសម្រាប់ម៉ោងសិក្សាទាំងមូល។
- សម្ភារៈ៖ តារាងមួយដែលពន្យល់អំពីសម្ភារៈនានាដែលចាំបាច់សម្រាប់ម៉ោងសិក្សានោះ និងកំណត់សម្គាល់ណាមួយដែលជួយដល់អ្នកសម្របសម្រួលនៅក្នុងការត្រៀមសម្ភារៈទាំងនោះមុនម៉ោងសិក្សា។
- សកម្មភាព៖ ម៉ោងសិក្សានីមួយៗនឹងត្រូវបានបំបែកជាសកម្មភាពនានា ដែលនឹងត្រូវបានបំបែកជាផ្នែកតូចៗបន្តទៀត ដូចខាងក្រោម៖
  + គោលបំណង៖ ពន្យល់អំពីគោលបំណងរបស់សកម្មភាពនេះ (ជាមូលដ្ឋាន គឺរបៀបដែលសកម្មភាពនេះមានទំនាក់ទំនងជាមួយនឹងវត្ថុបំណងរបស់ម៉ោងសិក្សា
  + ពេលវេលា៖ ពេលវេលាសម្រាប់សកម្មភាពនោះទាំងមូល
  + សេចក្តីណែនាំសម្រាប់អ្នកសម្របសម្រួល៖ ណែនាំមួយដំណាក់កាលម្តងៗ ស្តីពីរបៀបធ្វើសកម្មភាពនោះ ដែលរួមបញ្ចូលទាំងការកំណត់ពេលវេលាសម្រាប់សមាសធាតុនីមួយៗរៀងៗគ្នាផងដែរ។
  +

**ការកំណត់លេខ៖** រាល់សម្ភារៈទាំងអស់ត្រូវបានដាក់លេខជូនតាមលំដាប់ យោងតាមថ្ងៃ ម៉ោងសិក្សា និងសកម្មភាពផ្សេងៗនានា សម្រាប់អ្នកប្រើប្រាស់ ប្រសិនបើសម្ភារៈណាមួយត្រូវបានដាក់លេខ ២.៣.៤ មានន័យថាសម្ភារៈនោះគឺស្រាប់ប្រើនៅ៖

- ថ្ងៃទី២
- ម៉ោងទី៣
- សកម្មភាពទី៤

# សេចក្តីណែនាំ
# សម្រាប់ផ្តល់ការបណ្តុះបណ្តាល

រូបភាព: UNODC/ UN Women

## សេចក្តីណែនាំសម្រាប់ការបង្ហាញអំពីបញ្ហាយេនឌ័រ

របៀបដោះស្រាយបញ្ហាយេនឌ័រនឹងមានភាពខុសគ្នាទៅតាមបរិបទរបស់ប្រទេសនីមួយៗ។ នៅក្នុងប្រទេសមួយចំនួន សិក្ខាកាមអាចនឹងមានអារម្មណ៍ងាយស្រួល ក្នុងការសិក្សាស្វែងយល់អំពីយេនឌ័រ ប្រកបដោយការយល់ចិត្ត យោងតាមទស្សនៈវិស័យដែលមិនបែងចែកយេនឌ័រជាពីរ។ ប្រសិនបើករណីនេះកើតឡើង ហើយអ្នកសម្របសម្រួលមានសមត្ថភាពក្នុងសម្របសម្រួលកិច្ចពិភាក្សា គាត់នឹងទទួលបានការលើកទឹកចិត្តឲ្យធ្វើបែបនេះ ព្រមទាំងអាចកែសម្រួល និង បន្ថែមកត្តាផ្សេងទៀតទៅក្នុងកម្មវិធីបណ្តុះបណ្តាល ដើម្បីឱ្យអាចជួយសម្រួលកម្មវិធីបណ្តុះបណ្តាលបានកាន់តែច្រើនបន្ថែមទៀត។

## ធាតុចូលបន្ថែមពីអ្នកសម្របសម្រួល

សេចក្តីសង្ខេបនៃម៉ោងសិក្សានីមួយៗ ដែលនៅក្នុងកម្មវិធីបណ្តុះបណ្តាលនេះ វាផ្តល់នូវការណែនាំ និងចំណេះដឹងលម្អិតបន្ថែមនៅក្នុងអំឡុងម៉ោងសិក្សានោះដោយផ្ទាល់។ ទោះបីជាយ៉ាងណាក៏ដោយយើងរំពឹងទុកថាអ្នកសម្របសម្រួលនឹងយកចំនុច ឬកត្តាផ្សេងៗនៃកម្មវិធី ដែលបង្កើតឡើងស្របតាមឆន្ទានុសិទ្ធិរបស់ពួកគេមកចែករំលែក ដែលរួមមាន៖

- កម្មវិធីបើកវគ្គនៃមេរៀនទី ១ ដែលធ្វើឡើងនៅពេលព្រឹកថ្ងៃទីមួយ
- កិច្ចការសម្របសម្រួលប្រចាំថ្ងៃ
  + ការរំឭកមេរៀន ដែលធ្វើឡើងជារៀងរាល់ព្រឹក (លើកលែងតែថ្ងៃដំបូង) ដើម្បីរឭកឡើងវិញអំពីមេរៀនសំខាន់ៗដែលបានរៀនកាលពីថ្ងៃមុន
  + សកម្មភាពបង្កើនថាមពលក្រោយអាហារថ្ងៃត្រង់ ត្រូវបានណែនាំឲ្យអនុវត្តដើម្បីបង្កើនកម្រិតថាមពល និងការផ្ទង់ផ្នែកប្រាជ្ញាស្មារតីសម្រាប់ម៉ោងសិក្សានៅពេលរសៀល
  + ម៉ោងសួរសំណួរជារៀងរាល់ថ្ងៃ ដែលធ្វើឡើងនៅពេលបញ្ចប់នៃថ្ងៃនីមួយៗ (លើកលែងតែពេលចុងក្រោយ ដែលសិក្ខាកាមធ្វើការវាយតម្លៃលើវគ្គបណ្តុះបណ្តាល)

ផ្នែកខាងក្រោម ផ្តល់ការណែនាំ និងគន្លឹះអំពីការអនុវត្តចំណុចទាំងនេះ

## កម្មវិធីបើកវគ្គ

ក្នុងពេលបើកវគ្គបណ្តុះបណ្តាល (ថ្ងៃទីមួយ) ត្រូវបានផ្តល់ឆន្ទានុសិទ្ធិជូនអ្នកសម្របសម្រួលជាអ្នករៀបចំឡើង ប៉ុន្តែវាគួរតែរួមបញ្ចូលធាតុនានាដូចខាងក្រោម៖

### ១. សកម្មភាពបំបែកទឹកកក

វិធីសាស្ត្រមួយដែលបង្កភាពសប្បាយរីករាយ និងធ្វើឲ្យសិក្ខាកាមចូលរួមចំណែកនៅក្នុងការណែនាំខ្លួនរបស់ពួកគេ។

សកម្មភាពនេះគួរតែបានអនុវត្ត ទោះបីជាសិក្ខាកាមបានស្គាល់គ្នាហើយក៏ដោយ ពីព្រោះវាជួយបង្កើតបរិយាកាសនៃការបណ្តុះបណ្តាលឲ្យមានភាពជិតស្និត និងសុវត្ថិភាពជាងមុន។ អ្នកសម្របសម្រួលអាចស្វែងរកគំនិតជាច្រើនផ្សេងៗនៅតាមប្រព័ន្ធអ៊ីនធឺណិត សម្រាប់សកម្មភាពបំបែកទឹកកកនេះ ដើម្បីប្រើប្រាស់ជាមួយសិក្ខាកាមទាំងឡាយ ដែលមិនស្គាល់គ្នា និង សិក្ខាកាមដែលជាមិត្តរួមការងារជាមួយគ្នាស្រាប់ ឧទាហរណ៍៖

- ល្បែងដូមីណូ៖
  - + សិក្ខាកាមត្រូវបានផ្តល់ជូននូវក្រដាស A4 ម្នាក់មួយសន្លឹក និងបិចម្នាក់មួយដើម។ ពួកគេត្រូវបានស្នើសុំឲ្យបត់ក្រដាសនោះជាពីរ ហើយពន្លារាឡើងវិញ ធ្វើដូច្នេះនៅលើក្រដាសនោះនឹងមានបន្ទាត់ពុះកណ្តាលមួយ។ ឲ្យពួកគេយកបិចគូសបន្ទាត់មួយតាមស្នាមបត់នោះ ធ្វើដូច្នេះក្រដាសនោះនឹងមានពីរកំណាត់យ៉ាងច្បាស់លាស់ ដូចជាដូមីណូមួយដែរ ។
  - + ស្នើសុំឲ្យសិក្ខាកាមគូររូបភាពមួយ (មិនមែនជាពាក្យនោះទេ) នៅលើក្រដាសមួយកំណាត់ ដែលតំណាងឲ្យការងាររបស់ពួកគេ និងរូបភាពមួយ នៅលើក្រដាសមួយកំណាត់ទៀត ដែលតំណាងឲ្យជីវិតផ្ទាល់ខ្លួនរបស់ពួកគេ។ បន្ទាប់មក ឲ្យសិក្ខាកាមឈរជារង្វង់។
  - + អ្នកសម្របសម្រួល គួរតែចាប់ផ្តើមមុនគេបង្អស់ និងណែនាំអំពីខ្លួនពួកគេ ដោយប្រើដូមីណូ របស់ពួកគេ ហើយដាក់ដូមីណូនោះនៅលើកម្រាល។
  - + សាកសួរថាតើមានសិក្ខាកាមម្នាក់ផ្សេងទៀតដែលអាចមានទំនាក់ទំនងទៅនឹងជីវិតការងារ ឬជីវិតផ្ទាល់ខ្លួនរបស់សិក្ខាកាមម្នាក់នោះដែរឬទេ ហើយធ្វើការតភ្ជាប់ដូមីណូរបស់ពួកគេទៅតាមនោះ និងធ្វើការណែនាំអំពីខ្លួនពួកគេ។
  - + ធ្វើបែបនេះជាបន្តបន្ទាប់រហូតទាល់តែសិក្ខាកាមទាំងអស់បានធ្វើការតភ្ជាប់ដូមីណូរបស់ពួកគេ និងបានណែនាំខ្លួនពួកគេរួចរាល់ហើយ។
- ល្បែងស្វែងរកការពិត
  - + សិក្ខាកាមត្រូវបានណែនាំឲ្យសរសេរអង្គហេតុ ឬឃ្លាចំនួន ៣ រៀបរាប់អំពីខ្លួនពួកគេនៅលើក្រដាសមួយសន្លឹក។ ការសរសេរអង្គហេតុ គួរតែជាអ្វី ដែលមិនមែនជារឿងទូទៅ ងាយស្រួលទាយ តែអាចអ្វីកំប្លែងក៏បាន ប៉ុន្តែត្រូវចាំថា ក្នុងអង្គហេតុទាំង៣៖
    - អង្គហេតុ ១ មិនមែនជាការពិត
    - អង្គហេតុ ២ ទៀត គឺជាការពិត
  - + សិក្ខាកាមត្រូវឆ្លាស់វេនគ្នាអាន «អង្គហេតុ» ទាំងនោះ ហើយសិក្ខាកាមដទៃទៀតធ្វើការទស្សន៍ទាយថាតើអង្គហេតុមួយណា នៅក្នុងចំណោមអង្គហេតុទាំងបីនេះគឺជាការពិត។

+ សូមណែនាំទៅកាន់អ្នកសម្របសម្រួលគួរតែចាប់ផ្តើមជាមួយនឹងអង្គហេតុចំនួនបីរបស់ខ្លួនឯងដោយផ្ទាល់សិន ទើបឲ្យសិក្ខាកាមធ្វើម្តង។
+ បន្ទាប់ពីធ្វើការទស្សន៍ទាយអង្គហេតុរបស់សិក្ខាកាមមួយចប់ហើយ ដល់ពេលម្ចាស់អង្គហេតុត្រូវប្រាប់ការពិតថាអង្គហេតុមួយពិត មួយណាមិនពិត។

- សម្ភារៈនៅលើកោះដាច់ស្រយាល
  + ប្រាប់សិក្ខាកាមថា ពួកគេម្នាក់ៗត្រូវបានជ្រើសរើសឲ្យចូលរួមសម្តែងនៅក្នុងកម្មវិធីទូរទស្សន៍ថ្មីមួយដែលបង្ហាញអំពីតថភាពនៃជីវិតរស់នៅប្រចាំថ្ងៃ ដែលពួកគេត្រូវតែចំណាយពេល ៣ខែ នៅលើកោះដាច់ស្រយាលមួយតែម្នាក់ឯង។
  + ពួកគេត្រូវបានអនុញ្ញាតឲ្យយកសម្ភារៈ «ប្រណិត» មួយ តែមិនអាចជារូបថតរបស់មនុស្សជាទីស្រលាញ់ ឬភាវរស់ណាមួយនោះទេ។ ហើយទុកពេលឲ្យសិក្ខាកាមគិតពីចម្លើយរបស់ពួកគេ
  + អ្នកសម្របសម្រួលគួរតែចាប់ផ្តើមពីខ្លួនឯង ដោយការពន្យល់អំពីអ្វីដែលជាសម្ភារៈដ៏ប្រណិតនិងហេតុផលដែលខ្លួនបានជ្រើសយកវា។ បន្ទាប់មកគឺដល់វេនសិក្ខាកាមជាអ្នកបរិយាយពីវត្ថុដែលគេចង់យកទៅតាម និងមូលហេតុរបស់ពួកគេបន្តគ្នា។

## ២. សេចក្តីផ្តើមអំពីមេរៀនទី ១

ដោយប្រើប្រាស់ស្លាយនៃបទបង្ហាញបើក គ្រូបណ្តុះបណ្តាលគួរតែផ្តល់ទិដ្ឋភាពទូទៅនៃមេរៀន និងវគ្គបណ្តុះបណ្តាល និង របៀបវារៈលម្អិតនៃវគ្គបណ្តុះបណ្តាលនោះ។ គួរតែពន្យល់សិក្ខាកាមថា សៀវភៅណែនាំនានានឹងត្រូវបានផ្តល់ជូន ប៉ុន្តែស្នើសុំឲ្យសិក្ខាកាមចៀសវាងការអានសៀវភៅណែនាំនោះដោយតែម្នាក់ឯង ពីព្រោះដំណើរនៃវគ្គបណ្តុះបណ្តាលនឹងល្អប្រសើរជាងនេះ ប្រសិនបើម្នាក់ៗឆ្លងកាត់មេរៀនតំណាលគ្នា ខណៈពេលដែលវគ្គបណ្តុះបណ្តាលនោះកំពុងតែមានការវិវត្តទៅមុខ។

## ៣. ការរំពឹងទុក សង្ឃឹម និងកង្វល់

វាមានសារៈសំខាន់ដែលគ្រូបណ្តុះបណ្តាលគួរ តែដឹងអំពីការរំពឹងទុករបស់សិក្ខាកាម ធ្វើដូច្នេះការរំពឹងទាំងនោះអាចនឹងស្ថិតនៅក្រោមការគ្រប់គ្រងរបស់ពួកគេ ហើយគ្រូបណ្តុះបណ្តាលក៏គួរតែដឹងអំពីកង្វល់ផ្សេងៗដែលសិក្ខាកាមអាចនឹងមាន ស្តីពីវគ្គបណ្តុះបណ្តាលនោះផងដែរ ពិសេសពាក់ព័ន្ធនឹងខ្លឹមសារ និងវិធីសាស្ត្រនៅក្នុងការផ្តល់ចំណេះដឹង។ ឧទាហរណ៍ តើសិក្ខាកាម មានភាពភ័យខ្លាចដែរឬទេ នៅពេលពួកគេនឹងត្រូវបានស្នើសុំឲ្យចែករំលែកព័ត៌មានផ្ទាល់ខ្លួន? ប្រសិនបើការរំពឹងទុក និងកង្វល់របស់សិក្ខាកាម អាចដឹងទុកជាមុន នោះអ្នកសម្របសម្រួលអាចលៃលកកវិធី ដើម្បីគ្រប់គ្រងនិងបញ្ចាក់ការរំពឹងទុករបស់សិក្ខាកាមដោយជាពាក្យសម្តីផ្ទាល់មាត់ នៅក្នុងកម្មវិធីបើកវគ្គ ក៏ដូចជាធានាជូនថានឹងដោះស្រាយ ពីការព្រួយបារម្ភណាមួយ ដែលបានលើកឡើងពីសិក្ខាកាម។

ការផ្តល់មតិត្រឡប់ទៅសិក្ខាកាមវិញ ចាំបាច់ត្រូវបានផ្តល់ជូនដោយពាក្យសម្តីទន់ភ្លន់ និងជាអនាមិក ធ្វើដូច្នេះ សិក្ខាកាមនឹងមានអារម្មណ៍សុវត្ថិភាពនៅក្នុងការចែករំលែក។ អ្នកសម្របសម្រួលប្រហែលជាអាចទទួលបានព័ត៌មាននេះនៅមុនពេលចាប់ផ្តើមវគ្គបណ្តុះបណ្តាល តាមរយៈការវាយតម្លៃអំពីតម្រូវការ។

វិធីសាស្ត្រមួយទៀត គឺការអនុវត្តវិធីសាស្ត្រដែលមានការចូលរួម នៅក្នុងអំឡុងពេលបើកវគ្គបណ្តុះបណ្តាល ដូចជា ឧទាហរណ៍ខាងក្រោម៖

## ក្តីសង្ឃឹម និងកង្វល់

- គូសបន្ទាត់បញ្ឈរមួយនៅចំកណ្តាលផ្ទាំងក្រដាសធំមួយ នៅខាងមុខបន្ទប់។
- នៅផ្នែកខាងលើបង្គស់នៃកូឡោនមួយ សរសេរពាក្យ «ក្តីសង្ឃឹម» និងនៅផ្នែកខាងលើបង្គស់នៃ កូឡោនមួយផ្សេងទៀត សរសេរពាក្យ «កង្វល់»។
- ផ្តល់ជូនសិក្ខាកាមទាំងឡាយនូវក្រដាសកត់ត្រា ដែលមានភាពស្អិតនៅផ្នែកខាងក្រោយ (sticky note) ឬ អាចជំនួសដោយក្រដាសដែលមានទំហំស្មើប៉ុស្តិ៍កាត និង ដាក់បង់ស្អិតនៅក្បែរក្តារបញ្ឈរផ្ទាំងក្រដាសធំនោះ ធ្វើដូច្នេះពួកគេអាចបិតក្រដាសរបស់ពួកគេនៅលើផ្ទាំងក្រដាសធំនោះបាន។
- ផ្តល់ជូនសិក្ខាកាមម្នាក់ៗនូវក្រដាសចំនួន ៤-៦សន្លឹក និងស្នើសុំឲ្យពួកគេសរសេរគំនិតខុសៗគ្នានៅលើក្រដាសដាច់ដោយឡែកពីគ្នា គំនិតមួយ ប្រើក្រដាសមួយ។
- សម្រាប់ «ក្តីសង្ឃឹម» ពួកគេគួរតែសរសេរអំពីអ្វីដែលពួកគេសង្ឃឹមថានឹងទទួលបានពីវគ្គបណ្តុះបណ្តាលនោះ ឧទាហរណ៍ ចង់ដឹងពីប្រធានបទណាមួយ ឬចេះមេរៀនអ្វីមួយ អាចជាជំនាញជាក់លាក់ណាមួយក៏បាន។
- សម្រាប់ «កង្វល់» ពួកគេគួរតែសរសេរអំពីកង្វល់នានាដែលពួកគេមាន ស្តីពីវគ្គបណ្តុះបណ្តាលនោះ អាចពាក់ព័ន្ធនឹងខ្លឹមសារមេរៀន ឬសិល្បៈក្នុងការបង្រៀនមនុស្សពេញវ័យ/វិធីសាស្ត្របង្រៀននៃវគ្គបណ្តុះបណ្តាលនោះ។ ឧទាហរណ៍ ពួកគេមានកង្វល់ថា វគ្គបណ្តុះបណ្តាលនឹងរួមបញ្ចូលការសម្តែង ឬថា ពួកគេនឹងមិនទទួលបានចំណេះដឹងថ្មីៗនោះទេ។ល។
- បញ្ជាក់ជូនសិក្ខាកាមថា សកម្មភាពនេះនឹងរក្សាជូននូវភាពអនាមិក និងលើកទឹកចិត្តពួកគេឲ្យសរសេរអ្វីក៏ដោយដែលពួកគេគិតដោយផ្ទាល់។
- នៅពេលដែលសិក្ខាកាមគ្រប់រូបបានបញ្ចប់ការបិតក្រដាសរបស់ពួកគេ នៅលើក្តារបញ្ឈរផ្ទាំងក្រដាសធំនោះរួចរាល់ហើយ អ្នកសម្របសម្រួលគួរតែអានក្រដាសទាំងនោះដោយស្ងៀមស្ងាត់និងមើលថាជារួម តើមានក្រដាសមួយចំនួន ដែលអាចដាក់បញ្ចូលគ្នាជាក្រុមបានដែរឬទេ។ ឧទាហរណ៍ៈ ប្រសិនបើមានមនុស្សពីរឬបីនាក់បានកំណត់រកឃើញប្រភេទជាក់លាក់ណាមួយនៃវិធីសាស្ត្របង្រៀនថាជាកង្វល់មួយ។ល។
- អ្នកសម្របសម្រួលគួរតែដោះស្រាយជាមួយ ក្តីសង្ឃឹម និង កង្វល់ទាំងនោះ តាមរយៈការគ្រប់គ្រងការរំពឹងទុកការបញ្ជាក់អំពីក្តីសង្ឃឹមនៅចំណុចដែលពាក់ព័ន្ធ និងការដោះស្រាយបញ្ហាកង្វល់នានាដែលបានលើកឡើង។

## ៤. ការការពារសុវត្ថិភាព

នៅពេលបើកវគ្គនីមួយៗ គួរតែរួមចងចាំ និងទទួលស្គាល់ថាមនុស្សម្នាក់ៗមាន«ស្នាកស្នាមអតីតកាល» ខុសៗគ្នា។ បញ្ជាក់ចំពោះសិក្ខាកាមទាំងឡាយថា ប្រសិនបើនៅចំណុចណាមួយនៅក្នុងអំឡុងពេលនៃវគ្គបណ្តុះបណ្តាលនេះ ពួកគេមានអារម្មណ៍ទើសទាល់នោះ ពួកគេអាចចេញទៅក្រៅបន្ទប់ និងចំណាយពេលមួយចំនួននៅខាងក្រៅតែម្នាក់ឯងបាន។ មិនតែប៉ុនណោះ ព្រមទាំងលើកទឹកចិត្តពួកគេឲ្យស្នើសុំការជំនួយពីអ្នកសម្របសម្រួលផងដែរ ប្រសិនបើពួកគេត្រូវការ។ វាក៏ជាទម្លាប់អនុវត្តដ៏ល្អមួយផងដែរនៅក្នុងការបង្ការជាមុន ចំពោះស្លាកស្នាមនានាពីអតីតកាល ដែលអាចកើតឡើងចំពោះសិក្ខាកាមទាំងឡាយ នៅមុនពេលចាប់ផ្តើមការបណ្តុះបណ្តាល និងស្វែងរកព័ត៌មានអំពីសេវាគាំទ្រនានា ដែលសិក្ខាកាមអាចរកឃើញតាមសញ្ញាដែលប្រាប់ពីទីតាំងកន្លែងប្រឹក្សាយោបល់ ប្រសិនបើចាំបាច់។ ឧទាហរណ៍៖ តើមានសេវាផ្តល់ប្រឹក្សាយោបល់នៅក្នុងមូលដ្ឋានណាមួយ ដែលពួកគេអាចទទួលបានការបង្ហាញផ្លូវទៅកាន់ទីនោះដែរឬទេ ប្រសិនបើត្រូវការ?

## ៥. ព័ត៌មានអំពីកន្លែងបណ្តុះបណ្តាល

អ្នកសម្របសម្រួលក៏គួរតែគ្របដណ្តប់លើចំណុចនានាដែលពាក់ព័ន្ធនឹងការបំពេញតាមតម្រូវការមូលដ្ឋានផងដែរ ដូចជា៖

- សុវត្ថិភាព និងសន្តិសុខ ពោលគឺ ច្រកចេញនៅពេលមានអគ្គិភ័យ និងអ្វីដែលត្រូវធ្វើក្នុងករណីមានសញ្ញាប្រកាសអាសន្ន
- ទីតាំងបង្គន់ និងសម្ភារៈបន្ទប់ទឹក
- ម៉ោងទទួលទានអាហារថ្ងៃត្រង់ និងព័ត៌មានលម្អិតណាមួយដែលពាក់ព័ន្ធ

## ៦. វិធានមូលដ្ឋាន

នៅពេលចាប់ផ្តើមនៃវគ្គសិក្សានីមួយៗ អ្នកសម្របសម្រួលគួរតែរួមគ្នាបង្កើតវិធានមូលដ្ឋានមួយចំនួនជាមួយសិក្ខាកាមទាំងឡាយ ធ្វើដូច្នេះ នឹងមានវិធីធ្វើការមួយដែលទទួលបានការព្រមព្រៀង ដែលជាមូលដ្ឋានគ្រឹះសម្រាប់ការកាត់បន្ថយកត្តាអវិជ្ជមាន និងគ្រប់គ្រងឥរិយាបថនានា ដូចជា ការប្រើប្រាស់ទូរស័ព្ទចល័តនៅអំឡុងពេលបណ្តុះបណ្តាល ជាដើម។

សរសេរវិធានមូលដ្ឋាននៅលើផ្ទាំងក្រដាសធំ នៅខាងមុខបន្ទប់បណ្តុះបណ្តាល និងស្នើសុំឲ្យសិក្ខាកាមធ្វើការសំណូមពរអំពីអ្វីដែលគួរតែជាវិធានមូលដ្ឋាន។ វិធានមូលដ្ឋានអាចរួមបញ្ចូលចំណុចនានាដូចជា៖

- ទូរស័ព្ទចល័តគួរតែត្រូវបានរក្សាទុកនៅក្នុងកាបូប រហូតដល់ម៉ោងសម្រាក
- ពុំមានការជជែកគ្នាជាមួយអ្នកអង្គុយក្បែរខាង នៅខណៈពេលដែលនរណាម្នាក់កំពុងតែនិយាយនៅក្នុងការប្រជុំក្រុមនោះទេ
- ផ្តល់ការគោរពចំពោះទស្សនៈខុសៗគ្នា
- អ្វីដែលបាននិយាយនៅក្នុងបន្ទប់បណ្តុះបណ្តាលគួរតែត្រូវបានរក្សាទុកជាការសម្ងាត់
- សិក្ខាកាមគ្រប់រូបគួរតែត្រឡប់មកពីសម្រាកវិញឲ្យបានទាន់ពេលវេលា។

## ៧. ក្រដាសសួនសំណួរ និងធនធាន

បិតផ្ទាំងក្រដាសធំពីរសន្លឹកនៅលើជញ្ជាំងបន្ទប់បណ្តុះបណ្តាល។ ផ្ទាំងក្រដាសធំមួយសន្លឹកគួរតែបិតស្លាកឈ្មោះថា «សួនសំណួរ» និងផ្ទាំងក្រដាសធំមួយសន្លឹកទៀតគួរតែបិតស្លាកឈ្មោះថា «ធនធាន»។

- សួនសំណួរ៖ គឺសម្រាប់សិក្ខាកាមទាំងឡាយមកកាន់ផ្ទាំងក្រដាសធំនោះ និងសរសេរសំណួរណាមួយជាលក្ខណៈអនាមិក ដែលពួកគេមានអារម្មណ៍ថា ពួកគេមិនទទួលបានចម្លើយសម្រាប់សំណួរទាំងនោះនៅក្នុងអំឡុងពេលបណ្តុះបណ្តាលនោះទេ។ ឬអ្នកសម្រប សម្រួលអាចបន្ថែមសំណួរ ដែលអ្នកចូលរួមបានសួរនៅក្នុងអំឡុងពេលបណ្តុះបណ្តាល ដែលអ្នកសម្របសម្រួលយល់ថា ពួកគេមិនអាចឆ្លើយតបនឹងសំណួរទាំងនោះបាននៅពេលនោះ។ បន្ទាប់មក អ្នកសម្របសម្រួលអាចត្រួតពិនិត្យឡើងវិញ និងឆ្លើយតបនៅពេលណាមួយផ្សេងទៀត ដែលសមស្រប។
- ធនធាន៖ ជាញឹកញាប់ អ្នកសម្របសម្រួល ឬសិក្ខាកាមត្រូវគិតអំពីធនធាន (សៀវភៅ ឬគេហទំព័រ។ល។) ដែលមានប្រយោជន៍ នៅក្នុងអំឡុងពេលនៃវគ្គបណ្តុះបណ្តាលនោះ។ អ្នកសម្របសម្រួលគួរតែប្រើប្រាស់ក្តារធនធាន ដើម្បីធ្វើការកត់ត្រាធនធានដែលមានប្រយោជន៍ទាំងនេះ ជាបញ្ជីធនធានបន្ថែមមួយសម្រាប់សិក្ខាកាម។ នៅចុងបញ្ចប់នៃម៉ោងសិក្សានីមួយៗ អ្នកសម្របសម្រួលអាចចែកជូនសិក្ខាកាមនូវព័ត៌មានបន្ថែមនានាដែលនៅក្នុងម៉ោងជូនដល់សិក្ខាកាម។

## កិច្ចការសម្របសម្រួលប្រចាំថ្ងៃ
### ការរំឭកមេរៀននៅពេលព្រឹក

ជារៀងរាល់ព្រឹកនៃវគ្គបណ្តុះបណ្តាល គួរតែត្រូវបានចាប់ផ្តើមដោយការរំឭកឡើងវិញអំពីចំណុចសំខាន់ៗដែលបានរៀនសូត្រកាល់ពីថ្ងៃមុន។ ការរំឭកមេរៀននេះគួរតែបានធ្វើឡើងដោយប្រើសកម្មភាព ដែលបង្កភាពសប្បាយរីករាយ និងមានរយៈពេលមិនលើសពី ១៥ នាទីនោះទេ។ ប្រភេទនៃសកម្មភាពអាចជា៖

- ការសួរសំណួរជាក្រុម
- ល្បែងបាល់ ដែលតម្រូវឲ្យសិក្ខាកាមបោះបាល់ទៅម្នាក់ និងសួរ/ឆ្លើយសំណួរ ដោយផ្អែកលើមេរៀនដែលបានរៀនកាលពីថ្ងៃមុន
- សំណួរដែលត្រូវបានបង្កើតឡើងជាមុន ត្រូវបានសរសេរនៅលើក្រដាស និងបត់ទុកនៅក្នុងមួកមួយ។ សិក្ខាកាមចាប់យកសំណួរដោយចៃដន្យ។

អ្នកសម្របសម្រួលគួរតែធានាថា សិក្ខាកាមគ្រប់រូប (ទាំងបុរស និងស្ត្រី) បានចូលរួមនៅក្នុងសកម្មភាពនានាក្នុងសកម្មភាពការរំឭកមេរៀននោះ។

## សកម្មភាពបង្កើនថាមពលក្រោយអាហារថ្ងៃត្រង់

មានការទទួលស្គាល់យ៉ាងទូលំទូលាយថា កម្រិតថាមពលនៃការផ្លង់អារម្មណ៍ និងការចូលរួមចំណែករបស់សិក្ខាកាមនឹងធ្លាក់ចុះនៅក្រោយអាហារថ្ងៃត្រង់ គេបានណែនាំថា ពេលរសៀលនីមួយៗគួរតែចាប់ផ្តើមដោយសកម្មភាពបង្កើនថាមពលនៅពេលរសៀល ដែលជាសកម្មភាពបង្កើតភាពសប្បាយរីករាយមួយ ដើម្បីធ្វើឲ្យសិក្ខាកាមធ្វើការផ្លាស់ទីនៃរាងកាយរបស់ពួកគេ។ មានគំនិតជាច្រើនដែលអាចស្វែងរកបាននៅតាមប្រព័ន្ធអ៊ីនធឺណិត ឬអាចទទួលបានគំនិតច្នៃប្រឌិតតាមរយៈការបង្កើតឡើងវិញនូវល្បែងនានាដែលអ្នកធ្លាប់លេងកាលពីក្មេង។ ចំនុចសំខាន់ក្នុងសកម្មភាពនេះ គឺធ្វើឲ្យសិក្ខាកាមធ្វើការផ្លាស់ទី ឬមានចលនា។

ទោះបីជាយ៉ាងណាក៏ដោយ ចូរប្រុងប្រយ័ត្នថា មិនត្រូវស្នើសុំឲ្យចូលរួមធ្វើអ្វីដែលអាចធ្វើឲ្យពួកគេមានអារម្មណ៍ទើសទាល់ផ្លូវកាយ ឬផ្លូវចិត្តនោះទេ។

## ការរំឭកប្រចាំថ្ងៃ (បិទ)

នៅពេលបញ្ចប់ថ្ងៃនីមួយៗ អ្នកសម្របសម្រួលគួរតែលៃលកពេល ១៥នាទី សម្រាប់ឲ្យសិក្ខាកាមសួរសំណួរ និងផ្តល់មតិត្រឡប់ជាលក្ខណៈអនាមិកផងដែរ។ មតិត្រឡប់អាចត្រូវបានប្រើប្រាស់សម្រាប់ផ្តល់ព័ត៌មានអំពីរបៀបដែលអ្នកសម្របសម្រួលនឹងធ្វើការបង្រៀននៅថ្ងៃបន្ទាប់។

វិធីមួយក្នុងការផ្តល់មតិត្រឡប់នេះ គឺមានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងវិធីសាស្ត្រដែលបានពន្យល់នៅក្នុងវិធីសាស្ត្រ «ក្តីសង្ឃឹម និងកង្វល់» ដែរ ដែលត្រូវបានរៀបរាប់នៅក្នុងផ្នែកខាងលើ។

Photo: UNODC/ UN Women/ Ploy Phutpheng

ប៉ុន្តែជំនួសឲ្យការប្រើប្រាស់ «ក្តីសង្ឃឹម និងកង្វល់» ជាចំណងជើងនោះ ចូរប្រើប្រាស់ចំណងជើង «តើចំណុចណាខ្លះដែលដំណើរការបានយ៉ាងល្អជាងមុន?» និង «តើចំណុចណាខ្លះដែលគួរតែធ្វើឲ្យបានល្អជាងនេះទៀត ប្រសិនបើអាច» (តើចំណុចណាខ្លះដែលអ្នកចង់ឲ្យអនុវត្តខុសពីនេះ)។ អ្នកសម្របសម្រួលត្រូវធានាថា ក្តារនោះបែរមុខទៅរកជញ្ជាំងម្ខាង ដើម្បីរក្សាភាពអនាមិក។

របៀបដែលយេនឌ័រត្រូវបានដោះស្រាយ នឹងខុសគ្នារវាងបរិបទរបស់ប្រទេស។ នៅក្នុងប្រទេសមួយចំនួនសិក្ខាកាមនឹងមានអារម្មណ៍សុខស្រួលជាមួយនឹងការស្វែងយល់អំពីយេនឌ័រដោយយល់ចិត្តពីទស្សនៈដែលមិនមែនបែងចែកជា២។ តែប្រសិនបើជាមានករណីបែងចែកជា២ នោះអ្នកសម្របសម្រួលត្រូវមានសមត្ថភាពក្នុងការសម្របសម្រួលការពិភាក្សា ដោយលើកទឹកចិត្តពួកគេ ឲ្យសាកល្បងបែងចែកយេនឌ័រជា២ ដោយសម្របខ្លួននិងសាកល្បងសម្របទៅតាមកម្មវិធីសិក្សា ដូច្នេះវាអាចសម្របនឹងវាបន្ថែមទៀត។

# សេចក្តីសង្ខេប អំពីមេរៀន

រូបភាព: UNODC/ UN Women/ Ploy Phutpheng

## គោលបំណង

គោលបំណងរបស់មេរៀនទី ១ នេះគឺដើម្បីផ្តល់ជូនមន្ត្រីអនុវត្តច្បាប់នូវគំនិត នៃទស្សនាទានជារួម អំពី យេនឌ័រ។ មេរៀនទី ១ នេះផងដែរក៏គាំទ្រដល់ការបង្កើតគ្រោងនៃមេរៀនបន្ទាប់ ដែលមានភាពចាំបាច់ចំពោះការរួមបញ្ចូលទាំងមេរៀនទី ២ និងមេរៀនទី ៣ ជាបន្តបន្ទាប់ នៅក្នុងវគ្គសិក្សានេះផងដែរ។

## វត្ថុបំណងនៃការរៀនសូត្រ

១. ផ្តល់សេចក្តីផ្តើមអំពីទស្សនាទានជារួមនៃយេនឌ័រ និងរបៀបដែលទស្សនាទានទាំងនោះត្រូវបានបង្កើតឡើង ត្រូវបានថែរក្សា និងមានការវិវត្តនៅក្នុងសង្គម

២. សិក្សាស្វែងយល់អំពីការជះឥទ្ធិពលនៃការប្រាស្រ័យទាក់ទងក្នុងសង្គមទៅតាមយេនឌ័រ

៣. កំណត់និយមន័យអំពីអត្តសញ្ញាណកម្មនៃយេនឌ័រ និងទំនោរផ្លូវភេទ

៤. កត់សម្គាល់អំពីការរើសអើង យេនឌ័រ

៥. ពិភាក្សាអំពីដើមចមនៃការបំពាន/អំពើហិង្សាទាក់ទងនឹងយេនឌ័រ

៦. ផ្តល់ការណែនាំដល់សិក្ខាកាមអំពីក្របខណ្ឌច្បាប់ និងការប្តេជ្ញាចិត្តជាសកលដែលពាក់ព័ន្ធ និងទស្សនាទាននៃការអនុវត្តវិធីសាស្ត្រដែលផ្អែកលើគោលការណ៍សិទ្ធិមនុស្ស

## កំណត់សម្រាប់សម្រាប់អ្នកសម្របសម្រួល

ចំណុចសំខាន់ៗនៃមេរៀននេះគឺបង្កើនការឆ្លើយតបនឹងការប្រែប្រួលនៃយេនឌ័រ ខណៈពេកដែល៖

- មន្ត្រីអនុវត្តច្បាប់ធ្វើការជាក្រុម ក្នុងពេលធ្វើការជាមួយជនរងគ្រោះ
- មន្ត្រីអនុវត្តច្បាប់ធ្វើការម្នាក់ឯង និងជាក្រុម។

រាល់ការផ្លាស់ប្តូរអ្វីមួយ វាត្រូវការពេលវេលា និងភាពស៊ីសង្វាក់គ្នា ដូច្នេះហើយដើម្បីវគ្គសិក្សាត្រឹមរយៈពេលប៉ុន្មានថ្ងៃពិតមិនអាចផ្លាស់ប្តូរអ្វីបានច្រើនទេ។ ហេតុនេះ វគ្គបណ្តុះបណ្តាលនេះ គឺដើម្បីផ្តល់ជូន និងគាំទ្រដល់សិក្ខាកាមក្នុងការស៊ាំទៅនឹងការផ្លាស់ប្តូរ និងការខិតខំមួយចំនួនដូចខាងក្រោម៖

- សម្គាល់ពីតម្រូវការនៃការផ្លាស់ប្តូរ ដែលឆ្លើយតបនឹង យេនឌ័រ
- ឆ្លុះបញ្ចាំងពីរបៀបដែល យេនឌ័រមានផល់ប៉ះពាល់លើទំនុកចិត្តរបស់បុគ្គលណាម្នាក់ និងភាពជឿជាក់របស់គេ
- បង្កើនការយល់ចិត្តចំពោះមិត្តរួមការងារ ដែលផ្តោតលើការលើកទឹកចិត្ត និងការខិតខំក្នុងការផ្លាស់ប្តូរ
- បង្កើនចំណេះដឹង ជំនាញ និងបច្ចេកទេសនានា ដែលអាចប្រើប្រាស់ និងចែករំលែកជាមួយមិត្តរួមការងារដ៏ទៃ

សិក្ខាកាមក្នុងវគ្គនេះគួរតែមានចំណេះដឹងមូលដ្ឋានពីចំនុចខាងក្រោមនេះ៖

- ភេទ
- បទដ្ឋាន និងកត្តាផ្សេងៗនៃយេនឌ័រ
- បិតុនិយម
- ការរើសអើងយេនឌ័រ

## របៀបវារៈនៃវគ្គបណ្តុះបណ្តាល

| ថ្ងៃទីមួយ | ថ្ងៃទីពីរ | ថ្ងៃទីបី |
|---|---|---|
| កិច្ចស្វាគមន៍ និងម៉ោងបើកវគ្គ | ម៉ោងរំឭកមេរៀនពេលព្រឹក | ម៉ោងរំឭកមេរៀនពេលព្រឹក |
| ម៉ោងសិក្ខាទីមួយ៖<br>កំណត់និយមន័យយេនឌ័រ<br>រយៈពេល៖ ៩០ នាទី | ម៉ោងសិក្ខាទីមួយ៖<br>ទំនោរផ្លូវភេទ និងការធ្វើអត្តសញ្ញាណកម្មភេទ<br>រយៈពេល៖ ៩០ នាទី | ម៉ោងសិក្ខាទីមួយ៖<br>ការរំលោភបំពាន និងអំពើហិង្សាយេនឌ័រ<br>រយៈពេល៖ ៨៥ នាទី |
| សម្រាក (១៥ នាទី) | សម្រាក (១៥ នាទី) | សម្រាក (១៥ នាទី) |
| ម៉ោងសិក្ខាទីពីរ៖<br>អាកប្បកិរិយា និងលទ្ធផលទាក់ទងនឹងយេនឌ័រ<br>រយៈពេល៖ ៩០ នាទី | ម៉ោងសិក្ខាទីពីរ៖<br>អន្តរទំនាក់ទំនង និងយេនឌ័រ<br>រយៈពេល៖ ៩០ នាទី | ម៉ោងសិក្ខាទីពីរ៖<br>ការប្រែប្រួលនៃអំណាចដែលនៅពីក្រោយការរំលោភបំពាន ឬអំពើហិង្សាយេនឌ័រ (GBA/GBV)<br>រយៈពេល៖ ៩០ នាទី |
| អាហារថ្ងៃត្រង់ (៦០ នាទី) | អាហារថ្ងៃត្រង់ (៦០ នាទី) | អាហារថ្ងៃត្រង់ (៦០ នាទី) |
| ម៉ោងសិក្ខាទីបី៖<br>ការប្រាស្រ័យទាក់ទងក្នុងសង្គមទៅតាមយេនឌ័រ<br>រយៈពេល៖ ៩០ នាទី | ម៉ោងសិក្ខាទីបី៖<br>ការរើសអើង យេនឌ័រ<br>រយៈពេល៖ ៩០ នាទី | ម៉ោងសិក្ខាទីបី៖<br>ក្របខណ្ឌច្បាប់ និងដំណោះស្រាយសម្រាប់ យេនឌ័រ ដោយផ្អែកលើមូលដ្ឋានសិទ្ធិ<br>រយៈពេល៖ ៩០ នាទី |
| សម្រាក (១៥ នាទី) | សម្រាក (១៥ នាទី) | សម្រាក (១៥ នាទី) |
| ម៉ោងសិក្ខាទីបួន៖<br>ការប្រាស្រ័យទាក់ទងក្នុងសង្គមទៅតាមយេនឌ័រ និងបិតុនិយម<br>រយៈពេល៖ ៩០ នាទី | ម៉ោងសិក្ខាទីបួន៖<br>បរិបទ នៃការរើសអើង<br>រយៈពេល៖ ៩០ នាទី | ម៉ោងសិក្ខាទីបួន៖<br>ការរំឭកមេរៀន និងការធ្វើផែនការសកម្មភាព(រួមទាំងការវាយតម្លៃវគ្គបណ្តុះបណ្តាល)<br>រយៈពេល៖ ៦០ នាទី |
| ការបូកសរុបមេរៀនប្រចាំថ្ងៃ | ការបូកសរុបមេរៀនប្រចាំថ្ងៃ | |

## ការសង្ខេបត្រួសៗអំពីម៉ោងសិក្សា

សៀវភៅសម្រាប់អ្នកសម្របសម្រួលនឹងបង្ហាញពីការសង្ខេបត្រួសៗអំពីម៉ោងសិក្សា សម្រាប់មេរៀនទី ១។ ម៉ោងសិក្សានានាដូចខាងក្រោមគួរតែត្រូវបានបង្កើតឡើងដោយអ្នកសម្របសម្រួល៖

- កម្មវិធីបើកវគ្គ
- ការរំឭកមេរៀនពេលព្រឹក
- ការបូកសរុបមេរៀនប្រចាំថ្ងៃ

នៅក្នុងផ្នែកសេចក្តីណែនាំសម្រាប់វគ្គបណ្តុះបណ្តាល ខាងលើបានផ្តល់នូវព័ត៌មាននិងចំណុចសំខាន់ៗ សម្រាប់ការរៀបចំវគ្គបណ្តុះបណ្តាលនេះ។.

រូបភាព: UNODC/ UN Women

# ថ្ងៃទី ១

## ម៉ោងសិក្សាទីមួយ

## ការកំណត់និយមន័យយេនឌ័រ

**គោលបំណង៖** ដើម្បីណែនាំសិក្ខាកាមឲ្យស្គាល់អំពី «យេនឌ័រ» នៅក្នុងនាមជាទស្សនៈមួយ។

**វត្ថុបំណងនៃការរៀនសូត្រ៖**

នៅចុងបញ្ចប់នៃម៉ោងសិក្សានេះ សិក្ខាកាមនឹង...

- ទទួលស្គាល់ថា «យេនឌ័រ» គឺជាទស្សនៈមួយដែលត្រូវបានបង្កើតឡើងដោយសង្គម (មិនមែន ដែលជីវសាស្ត្រនោះទេ)
- អាចសរសេរឧទាហរណ៍យ៉ាងតិចបី ស្តីពីភាពខុសគ្នារវាង «យេនឌ័រ» និង «ភេទ»

**ពេលវេលា៖** ៩០ នាទី

| **សេចក្តីពណ៌នាអំពីធនធាន** | **សេចក្តីណែនាំអំពីការត្រៀមសម្ភារៈ** |
|---|---|
| ការធ្វើបទបង្ហាញ | |
| ១.១.១៖ ភាពខុសគ្នារវាង «យេនឌ័រ» និង «ភេទ» | សម្រាប់ក្រុមនីមួយៗ ឲ្យឯកសារចម្លងមួយច្បាប់ និងកាត់កាតជាផ្នែកៗ |
| ១.១.២៖ ការបែងចែកកញ្ចប់សម្ភារៈ សកម្មភាព និងតួនាទីតាមយេនឌ័រ<br><br>កាតសម្រាប់បុរស និងកាតសម្រាប់ស្ត្រី | កាតសម្រាប់បុរស និងកាតសម្រាប់ស្ត្រីអាចត្រូវបានបោះពុម្ពនៅលើក្រដាសពណ៌ ស ទទេរស្អាត។<br><br>ពាក្យ «សម្ភារៈ» «សកម្មភាព» និង «តួនាទី» គួរតែត្រូវបានបោះពុម្ពនៅលើក្រដាសបីពណ៌ខុសៗគ្នា ទៅតាមប្រភេទនីមួយៗ ដែលពាក្យស្ថិតនៅក្រោមនោះ ។ |
| ផ្ទាំងក្រដាសធំ និងហ្វឺតសម្រាប់ការងារជាក្រុម | សម្រាប់សកម្មភាពនេះ អ្នកសម្របសម្រួលនឹងតម្រូវឲ្យរៀបចុះខ្សែរែងចំនួនពីរខ្សែផងដែរ ដើម្បីបង្កើតជាជារង្វង់នៅលើឥដ្ឋ។ |

## ទិដ្ឋភាពទូទៅនៃម៉ោងសិក្សានេះ

| សកម្មភាព | គោលបំណង | រយៈពេល |
|---|---|---|
| ១. ភាពខុសគ្នារវាង យេនឌ័រ និង ភេទ | លើកទឹកចិត្តឲ្យសិក្ខាកាមឆ្លុះបញ្ចាំង ពីភាពខុសគ្នារវាងយេនឌ័រ និងភេទ ហើយដើម្បីបង្កើនបរិយាកាសនៅកន្លែងវគ្គបណ្តុះបណ្តាលឲ្យគាំទ្រ ដល់សិក្ខាកាមដ៏ទៃទៀតមានអារម្មណ៍ចែករំលែក និងរៀនសូត្រប្រកបដោយជាសុខភាព។ | ៤៥ នាទី |
| ២. ការបែងចែកកញ្ចប់សម្ភារៈ សកម្មភាព និងតួនាទីតាមយេនឌ័រ | ធ្វើជាគំរូតាមការបែងចែកយេនឌ័រនៃតួនាទីនៅក្នុងសង្គម។ | ៤៥ នាទី |

## សកម្មភាពទីមួយ៖ យេនឌ័រ ធៀបនឹង ភេទ

**គោលបំណង៖** ដើម្បីលើកទឹកចិត្តសិក្ខាកាមឲ្យធ្វើការឆ្លុះបញ្ចាំងអំពីភាពខុសគ្នារវាង «យេនឌ័» និង «ភេទ» និងចាប់ផ្តើមបង្កើតបរិយាកាស ដែលមានការចូលរួមមួយនៅក្នុងបន្ទប់បណ្តុះបណ្តាល ដែលគាំទ្រឲ្យសិក្ខាកាមមានអារម្មណ៍សុខស្រួលនៅក្នុងការចែករំលែក និងការរៀនសូត្រ។

**រយៈពេល៖** ៤៥ នាទី

**សេចក្តីណែនាំសម្រាប់អ្នកសម្របសម្រួល៖**

**១.១ ការងារជាគូ** (១០ នាទី)

បែងចែកសិក្ខាកាមជាគូៗ និងស្នើសុំឲ្យពួកគេធ្វើការពិភាក្សាអំពី៖

«តើអ្វីខ្លះគឺជាភាពខុសគ្នារវាង «យេនឌ័រ» និង «ភេទ»?»

បន្ទាប់ពីពិភាក្សាគ្នាបាន ៥ នាទីហើយ បង្រួមក្រុមបញ្ចូលគ្នាវិញ និងទទួលយកមតិត្រឡប់ចំពោះគំនិតរបស់ពួកគេ។ អ្នកសម្របសម្រួលគួរតែកត់ត្រាចំណុចសំខាន់ៗនៅលើក្តារបញ្ឆរផ្ទាំងក្រដាសធំដែលនៅខាងមុខ។

**១.២ ការងារជាក្រុម** (១៥ នាទី)

១. បែងចែកសិក្ខាកាមជាក្រុមតូចៗ និងប្រគល់ជូនពួកគេនូវកញ្ចប់សម្រាប់សកម្មភាព ១.១.១៖ យេនឌ័រ ធៀបនឹង ភេទ។

២. ពន្យល់ថាក្រុមទាំងនោះគួរតែបង្កើតកូឡោនចំនួនពីរ កូឡោនមួយដោយប្រើកាត "ភេទ" ជាចំណងជើង និងកូឡោនមួយផ្សេងទៀត ដោយប្រើកាត "យេនឌ័រ" ជាចំណងជើង។ បន្ទាប់មក ពួកគេគួរតែរៀបចំកាតនៃគ្រប់ប្រយោគទាំងអស់នៅខាងក្រោមចំណងជើងដែលពួកគេយល់ថាវាស័ក្តិសមជាទីបំផុត។ ផ្តល់ជូនពួកគេនូវពេលវេលារហូតដល់ ១៥ នាទី ដើម្បីធ្វើការងារនេះ។

**១.៣ យោបល់ត្រឡប់/កិច្ចប្រជុំ** (២០ នាទី)

១. ១៥ នាទីក្រោយមក (ឬបន្ទាប់ពីគ្រប់ក្រុមទាំងអស់បានបញ្ចប់ការបែងចែកកាតទៅតាមប្រភេទនានាហើយនោះ) បង្រួមក្រុមចូលគ្នាវិញ និងពិភាក្សាអំពីជម្រើសនៃការបែងចែកប្រភេទរបស់ពួកគេ។ តារាងខាងក្រោមបង្ហាញអំពីប្រភេទនានា (លំដាប់លំដោយនៃការដាក់សេចក្តីពណ៌នាផ្សេងៗនៅខាងក្រោមប្រភេទនីមួយៗ គឺមិនត្រូវការនោះទេ)។

២. សួរទៅកាន់សិក្ខាកាម ថាតើពួកគេគិតថាអ្វីជាចំណុចខុសគ្នាសំខាន់ៗរវាងប្រភេទទាំងនេះ? ចំណុចសំខាន់ត្រង់មេរៀននេះ គឺកំណត់រកឃើញទស្សនៈដែល ភេទ ត្រូវបង្កើតឡើងដោយជីវសាស្ត្រ នៅខណៈពេលដែល យេនឌ័រត្រូវបានបង្កើតឡើងដោយសង្គម។

| ភេទ | យេនឌ័រ |
|---|---|
| ស្ត្រីមានក្រូម៉ូសូម X ២ នៅខណៈពេលដែលបុរសមានក្រូម៉ូសូម X ១ និងក្រូម៉ូសូម Y ១ | ស្ត្រីងាយរំជួលចិត្តជាងបុរស |
| ស្ត្រីផ្តល់កំណើតដល់ទារក | ស្ត្រីមានសក់វែងជាងបុរស |
| បុរសមានអរម៉ូនតេស្តូស្តេរ៉ូននៅកម្រិតខ្ពស់ជាងស្ត្រី | បុរសពូកែបើកបរជាងស្ត្រី |
| ស្ត្រីមានអរម៉ូនអេស្ត្រូជែននៅកម្រិតខ្ពស់ជាងបុរស | ស្ត្រីទទួលខុសត្រូវចំពោះការថែទាំកូន |
| ស្ត្រីអាចបំបៅដោះកូនបានស្ត្រីអាចបំបៅដោះកូនបាន | បុរសកាន់តួនាទីដែលមានអំណាចខ្ពស់ភាគច្រើនក្នុងជួររដ្ឋាភិបាល |
| បុរសបែកសម្លេងនៅពេលពេញវ័យ | កុមារាចូលចិត្តពណ៌ខៀវ ហើយកុមារីចូលចិត្តពណ៌ផ្កាឈូក |
| ស្ត្រីចាប់ផ្តើមមានរដូវនៅអំឡុងពេលពេលវ័យ | ស្ត្រីពូកែចម្អិនម្ហូប និងធ្វើការបោសសម្អាត ជាងបុរស |

ត្រង់កន្លែងនេះ គួរតែអនុញ្ញាតឲ្យសិក្ខាកាមមានការជជែកដែកញែកជុំវិញចំណុចណាមួយដែលបានលើកឡើង ប៉ុន្តែជំនួសឲ្យការប្រកួតប្រជែងនឹងគំនិតនានារបស់សិក្ខាកាមដែលបានលើកឡើង អ្នកសម្របសម្រួលគួរតែផ្តល់សំណួរដែលមានលក្ខណៈឆ្លុះបញ្ចាំងវិញ។

ឧទាហរណ៍៖ ប្រសិនបើសិក្ខាកាមម្នាក់សួរថា ប្រយោគដែលលើកឡើងថា៖ "បុរសអាចធ្វើការងារដែលប្រើប្រាស់កម្លាំងកាយបានច្រើនជាងស្ត្រី" គួរតែស្ថិតនៅក្នុងប្រភេទ ភេទ ឬយេនឌ័រ នៅពេលនោះ សួរទៅកាន់ក្រុមសិក្ខាកាមទាំងមូលវិញថាតើពួកគេអាចគិតដល់ការងារណាមួយដែលស្ត្រីធ្វើ ដែលត្រូវការប្រើកម្លាំងដៃរឬទេ។

## **សកម្មភាពទីពីរ៖** ការបែងចែកសម្ភារ សកម្មភាព និងតួនាទីតាមយេនឌ័រ

**គោលបំណង៖** ដើម្បីធ្វើគំរូតាមការបែងចែកតួនាទីតាមយេនឌ័រ នៅក្នុងសង្គម

**រយៈពេល៖** ៤៥ នាទី

**សេចក្តីណែនាំសម្រាប់អ្នកសម្របសម្រួល៖**

**២.១ ការងារជាក្រុម** (១០ នាទី)

១. នៅចំកណ្តាលបន្ទប់ អ្នកសម្របសម្រួលគួរតែប្រើប្រាស់ខ្សែដើម្បីបង្កើតរង្វង់ធំពីរនៅលើកម្រាលឥដ្ឋ ដែលមានទីធ្លាគ្រប់គ្រាន់សម្រាប់ការដើរនៅចន្លោះពួកគេ។ នៅចំណុចកណ្តាលនៃរង្វង់នីមួយៗ ដាក់កាតសញ្ញាបុរស និងស្ត្រី ដែលត្រូវបានរកឃើញនៅក្នុងកញ្ចប់សម្ភារៈសម្រាប់សកម្មភាព ១.១.២៖ ការបែងចែកសម្ភារ សកម្មភាព និងតួនាទីតាមយេនឌ័រ។

២. បែងចែកសិក្ខាកាមជាក្រុមតូចៗ ឬជាគូៗ អាស្រ័យលើទំហំក្រុម (អនុញ្ញាតឲ្យក្រុម ឬគូនីមួយៗ មានកាតយ៉ាងតិច ៦)។

៣. ដាក់បញ្ចូលគ្នានូវកាតដែលនៅសល់ នៅក្នុងកញ្ចប់ ១.១.២៖ ការបែងចែកសម្ភារ សកម្មភាព និងតួនាទីតាមយេនឌ័រ និងផ្តល់ជូនក្រុម/គូនីមួយៗនូវការជ្រើសរើសកាតនានា រហូតទាល់តែកាតទាំងអស់ត្រូវបានចាត់ចែងរួចរាល់។

៤. ពន្យល់ថា ពួកគេមានពេល ៥ នាទី ដើម្បីសម្រេចថាតើកាតនីមួយៗគួរតែស្ថិតនៅក្នុងប្រភេទណាមួយ (បុរស/ស្ត្រី) និងដាក់វានៅក្នុងរង្វង់រៀងៗគ្នា។

៥. បញ្ជាក់ជាមួយសិក្ខាកាមឡើងវិញថា ពួកគេនឹងត្រូវបានគេវាយតម្លៃដោយផ្អែកតាមការសម្រេចចិត្តរបស់ពួកគេនោះទេ ប៉ុន្តែចូរធ្វើសកម្មភាពនេះដោយផ្អែកតាមសភាវគតិរបស់ពួកគេ នៅពេលដែលពួកគេអានកាតទាំងនោះ។

កាតនៅក្នុងកញ្ចប់ ១.១.២៖ ការបែងចែកសម្ភារ សកម្មភាព និងតួនាទីតាមយេនឌ័រ មានដូចតទៅ៖

| **សម្ភារ** | **សកម្មភាព** | **តួនាទី** |
|---|---|---|
| គ្រឿងជាត់មុខ | ការបើកបរ | គ្រូបង្រៀន |
| កាបូបដៃ | ការសាងសង់ | គិលានុប្បដ្ឋាយិកា |
| កាសែត | ការចម្អិនម្ហូប | អ្នកនយោបាយ |
| ក្រវ៉ាត់ ក | ការលេងជាមួយក្មេងៗ | មេគ្រួសារ |
| ខោជើងវែង | ការបោសសម្អាតផ្ទះ | អ្នកមើលថែកូន |
| ឆ្នាំងខ្ទះ | ការដេរខោអាវ | អ្នកមើលថែទាំមនុស្សចាស់ក្នុងផ្ទះ |
| រទេះរុញទារក | ការចាក់សាំងរថយន្ត | កសិករ |
| កុំព្យូទ័រយួរដៃ | ទៅផ្សារ | អ្នកបើកតាក់ស៊ី |
| រថយន្ត | ការរាំ | អ្នកពន្លត់អគ្គិភ័យ |

**២.២ មតិត្រឡប់/កិច្ចប្រជុំ** (២០ នាទី)

១. នៅពេលក្រុមនីមួយៗបានបញ្ចប់ការបែងចែកកាតរបស់ពួកគេទៅតាមរង្វង់រៀងៗគ្នាហើយនោះ អ្នកសម្របសម្រួលគួរតែសួរថា តើពួកគេដឹងអំពីសារៈសំខាន់នៃពណ៌ខុសៗគ្នាដែលត្រូវបានប្រើប្រាស់នៅលើកាតទាំងនោះដែរឬទេ។ ព្យាយាមទាញយកព័ត៌មានពីសិក្ខាកាមថា មានប្រភេទចំនួនបីខុសៗគ្នា ដែលត្រូវបានតំណាងដោយ "សម្ភារៈ" "សកម្មភាព" និង "តួនាទី"។

២. នៅពេលនេះ អ្នកសម្របសម្រួលគួរតែលើកទឹកចិត្ត ឲ្យមានការពិភាក្សាគ្នាជុំវិញមូលហេតុដែលសិក្ខាកាមទាំងឡាយបានធ្វើការសម្រេចចិត្តមួយចំនួននៅក្នុងការបែងចែកប្រភេទកាត តាមប្រភេទកាតបុរស និងកាតស្ត្រី។ គោលបំណង គឺដើម្បីធ្វើឲ្យសិក្ខាកាមដឹងថាពួកគេបានជាប់លក្ខខណ្ឌ នៅក្នុងការផ្សារភ្ជាប់ទំនាក់ទំនងរវាងសម្ភារៈ សកម្មភាព និងតួនាទីនានាជាមួយយេនឌ័រ។

៣. សម្រាប់ជម្រើសនីមួយៗដែលត្រូវបានធ្វើឡើង អ្នកសម្របសម្រួលគួរតែសាកសួរថាតើមានមូលហេតុផ្នែកជីវសាស្ត្រណាមួយដែលធ្វើឲ្យសម្ភារៈ សកម្មភាព ឬតួនាទីនោះមានទំនាក់ទំនងជាមួយយេនឌ័រដែរឬទេ បន្ទាប់មកធ្វើការសួរដេញដោលបន្តទៀត ដើម្បីស្វែងរកមូលហេតុដែលការសម្រេចចិត្តទាំងនោះត្រូវបានធ្វើឡើង សំណួរអាចរួមបញ្ចូលចំណុចនានា ដូចជា៖

+ តើរូបភាពអ្វីខ្លះដែលលេចឡើងនៅក្នុងចិត្តរបស់ពួកគេ នៅពេលដែលពួកគេគិតអំពីសម្ភារៈ សកម្មភាព និងតួនាទីណាមួយដែលមាននៅលើកាតទាំងនោះ។ ហេតុអ្វីបានជាពួកគេគិតដល់តថភាពទាំងនោះ ដែលបានលេចឡើងនៅក្នុងចិត្តរបស់ពួកគេ?
+ សាកសួរថាតើសិក្ខាកាមមានស្គាល់អ្នកដទៃណាមួយដែលមានយេនឌ័រណាមួយ ហើយមានតួនាទីការងារជាក់លាក់ណាមួយដែរឬទេ និងថាតើតួនាទីនេះត្រូវបានផ្លាស់ប្តូរ/កំពុងតែមានការផ្លាស់ប្តូរនៅក្នុងសង្គមដែរឬទេ?
+ ថាតើពួកគេធ្លាប់ត្រូវបានគេបង្អាក់ទឹកចិត្ត ឬលើកទឹកចិត្តចំពោះតួនាទីការងារជាក់លាក់ណាមួយដែរឬទេ នៅពេលដែលពួកគេនៅក្មេង និងថាតើពួកគេយល់ថាការបង្អាក់ទឹកចិត្ត ឬការលើកទឹកចិត្តនោះបណ្តាលមកពីភេទរបស់ពួកគេ មែនដែរឬទេ។
+ ប្រសិនបើសិក្ខាកាមអាចធ្វើសកម្មភាពមួយចំនួនដែលពួកគេបានសន្មត់ថាជាសកម្មភាពរបស់ភេទផ្សេងទៀតនោះ។ ឧទាហរណ៍ តើសមាជិកក្រុមដែលជាបុរសអាចដេរខោអាវបានដែរឬទេ? តើពួកគេធ្លាប់ត្រូវបានគេបង្រៀនឲ្យធ្វើសកម្មភាពនោះដែរឬទេ?
+ តើពួកគេធ្លាប់ទិញរបស់ក្មេងលេងដែលតំណាងឲ្យសម្ភារៈមួយចំនួន ពោលគឺរទេះរុញទារក និងកូនក្រមុំដេរ ឬរថយន្ត នៅពេលដែលពួកគេនៅក្មេង ដែរឬទេ?

៤. សំណួរទាំងអស់នេះត្រូវបានរៀបចំឡើងដើម្បីជួយដល់សិក្ខាកាមនៅក្នុងចាប់ផ្តើមសួរសំណួរអំពីទិដ្ឋភាពនានានៃការប្រាស្រ័យទាក់ទងក្នុងសង្គមទៅតាមយេនឌ័រ។

បិទម៉ោងសិក្សាដោយការសួរសំណួរណាមួយ។

# ម៉ោងសិក្សាទីពីរ

# អាកប្បកិរិយា និងលទ្ធផល ដែលទាក់ទងនឹងយេនឌ័រ

**គោលបំណង៖** ដើម្បីស្វែងយល់អំពីរបៀបដែលគុណភាព អារម្មណ៍ និងអាកប្បកិរិយានានាត្រូវបានកំណត់ទៅតាមប្រភេទយេនឌ័រ។

## វត្ថុបំណងនៃការរៀនសូត្រ៖

នៅចុងបញ្ចប់នៃម៉ោងសិក្សានេះ សិក្ខាកាមនឹង...

- អាចផ្តល់ឧទាហរណ៍យ៉ាងតិចបី ស្តីពីរបៀបដែលគុណភាព អារម្មណ៍ និងអាកប្បកិរិយានានាត្រូវបានកំណត់ទៅតាមប្រភេទយេនឌ័រ។
- អាចផ្តល់ឧទាហរណ៍យ៉ាងតិចបី អំពីរបៀបដែលផលប៉ះពាល់នៃអាកប្បកិរិយាមានភាពខុសគ្នារវាង យេនឌ័រ។
- បានពិភាក្សាថាតើរបៀបដែលអាកប្បកិរិយា និងលទ្ធផលដែលទាក់ទងនឹងយេនឌ័រមានការផ្លាស់ប្តូរទៅតាមពេលវេលាយ៉ាងដូចម្តេច។

**ពេលវេលា៖** ៩០ នាទី

| **សេចក្តីពណ៌នាអំពីធនធាន** | **សេចក្តីណែនាំអំពីការត្រៀមសម្ភារៈ** |
|---|---|
| ការធ្វើបទបង្ហាញ | |
| ១.២.១ កញ្ចប់សកម្មភាពនៃ គុណភាព អារម្មណ៍ និងអាកប្បកិរិយាតាមយេនឌ័រ<br><br>កញ្ចប់សំនួរឆ្លុះបញ្ចាំងមួយ និងករណីសិក្សាចំនួនបី | កញ្ចប់សម្ភារៈមួយ សម្រាប់មួយក្រុម |

## ទិដ្ឋភាពទូទៅនៃម៉ោងសិក្សានេះ

| សកម្មភាព | គោលបំណង | ពេលវេលា |
|---|---|---|
| គុណភាព អារម្មណ៍ និងអាកប្បកិរិយានានាត្រូវបានកំណត់ទៅតាមប្រភេទយេនឌ័រ និងផលប៉ះពាល់របស់វា | បង្កើតគំរូតាមការបែងចែកតួនាទីតាមយេនឌ័រនៅក្នុងសង្គម។ | ៩០ នាទី |

**សកម្មភាពទីមួយ៖** គុណភាព អារម្មណ៍ និងអាកប្បកិរិយា តាមយេនឌ័រ និងផលប៉ះពាល់របស់វា

**គោលបំណង៖** ដើម្បីធ្វើគំរូតាមការបែងចែកតួនាទីតាមយេនឌ័រ នៅក្នុងសង្គម

**រយៈពេល៖** ៩០ នាទី

**សេចក្តីណែនាំសម្រាប់អ្នកសម្របសម្រួល៖**

**១.១ ការងារជាក្រុម** (៤៥ នាទី)

១. បំបែកសិក្ខាកាមជាក្រុមតូចៗ

២. ផ្តល់ជូនក្រុមនីមួយៗនូវសំណៅចម្លងមួយច្បាប់នៃកញ្ចប់ ១.២.១ គុណភាព អារម្មណ៍ និងអាកប្បកិរិយាតាមយេនឌ័រ។ សូមបញ្ជាក់ទៅកាន់សិក្ខាកាមថា នៅក្នុងកញ្ចប់នីមួយៗមានករណីសិក្សាខ្លីៗ ចំនួន ៣ រួមជាមួយក្រដាសកិច្ចការមួយ ដែលមានសំណួរនានាដែលនឹងត្រូវប្រើប្រាស់សម្រាប់ករណីសិក្សានីមួយៗ។ អ្នកសម្របសម្រួលត្រូវផ្តល់ជូនក្រុមនីមួយៗនូវផ្ទាំងក្រដាសធំចំនួនពីរសន្លឹក។

៣. ពន្យល់ប្រាប់ពួកគាត់ថា កិច្ចការទាំងនេះមានសមាសធាតុចំនួនពីរដែលរត់ក្នុងទិសដៅស្របគ្នា គឺការអាន និងការវិភាគអំពីករណីសិក្សា ហើយនោះគឺជាមូលហេតុដែលពួកគេទទួលបានផ្ទាំងក្រដាសធំចំនួន២សន្លឹក៖




## កំណត់បង្ហាញសម្រាប់អ្នកសម្របសម្រួល

### កិច្ចការផ្នែកទី១

១. ណែនាំឲ្យសិក្ខាកាមគូសបន្ទាត់កាត់ចំកណ្តាលផ្ទាំងក្រដាសធំ ពុះក្រដាសធំជា២កូឡោន ដែលដាក់ចំណងជើងកូឡោនមួយថា បុរស និងកូឡោនមួយទៀតថា ស្ត្រី

២. ពន្យល់ក្រុមសិក្ខាកាមថា នៅពេលដែលពួកគាត់អានករណីសិក្សា ពួកគាត់គួរតែកត់សំគាល់គុណនាម អាចជាពាក្យ ឬឃ្លាបដែលពាក់ព័ន្ធនឹងកិច្ចការ ហើយយកពាក្យ ឬឃ្លាទាំងនោះដាក់ទៅក្នុងកូឡោនដែលពួកគាត់គិតថាសាកសម។ ឧទាហរណ៍ ប្រសិនបើករណីសិក្សាណាមួយមានប្រើគុណនាម «ងាយរងការប៉ះទង្គិចផ្លូវចិត្ត»(វេទយិក) តើពាក្យនេះសាកសមសម្រាប់បុរស ឬស្ត្រី? សិក្ខាកាមមិនចាំបាច់កត់សំគាល់ថាពាក្យឬឃ្លានោះដកស្រង់ចេញពីករណីមួយណានោះទេ។ អ្វីដែលសំខាន់គឺការបែងចែកគុណនាមសម្រាប់ភេទនីមួយៗ

៣. ទុករយៈពេល៤៥នាទី សម្រាប់ការងារក្រុមនេះ ហើយក្រុមនីមួយៗនឹងភ្ជួរក្រដាសចម្លើយនៅលើជញ្ជាំង

### កិច្ចការផ្នែកទី២

១. នៅក្នុងកញ្ចប់កិច្ចការនីមួយៗមានសំនួរឆ្លុះបញ្ចាំងសម្រាប់ករណីសិក្សានីមួយៗ ដូចជា៖

- តើអ្នកគិតថាតើតួអង្គក្នុងករណីសិក្សាជាបុរស ឬស្ត្រី? ចូរបកស្រាយ។

- តើមានផលប៉ះពាល់អ្វីខ្លះពីសកម្មភាពដែលកើតឡើងនៅក្នុងករណីសិក្សា ដែលរួមបញ្ចូលទាំងប្រតិកម្មរបស់គ្រួសារនិងសហគមន៍ និងផលប៉ះពាល់តាមផ្លូវច្បាប់ ផ្នែកសេដ្ឋកិច្ច និងក្នុងរយៈពេលវែងផងដែរ?
- តើផលប៉ះពាល់ទាំងនោះមានភាពខុសគ្នាដែរឬទេ ប្រសិនបើអ្នកប្រព្រឹត្តសកម្មភាពនោះជាបុរស ឬស្ត្រី? បើមាន តើវាខុសគ្នាយ៉ាងដូចម្តេចដែរ?
- តើអ្នកគិតថាផលប៉ះបាល់ដែលពាក់ព័ន្ធអាស្រ័យភេទក្នុងសំណួរខាងលើ អាចមានចំនុចខុសគ្នាទេសម្រាប់ពេលបច្ចុប្បន្ន បើធៀបទៅនឹងជំនាន់ឪពុកម្តាយ ឬជីដូនជីតារបស់អ្នកកាលពីពួកគាត់នៅក្មេង?

ផ្តល់ពេលវេលាជូនសិក្ខាកាម ចំនួន ៤៥ នាទី ដើម្បីបញ្ចប់កិច្ចការទាំង២នេះ។

**១.២ វគ្គក្រុមធំ (៤៥ នាទី)**

១. បន្ទាប់ពីបញ្ចប់កិច្ចការនោះហើយ ស្នើឲ្យក្រុមសិក្ខាកាមមួយបិតក្រដាស ដែលពួកគេបានកត់ត្រាគុណនាមនោះ នៅលើជញ្ជាំងជាជួរ។ ពួកគេនឹងធ្វើការឆ្លុះបញ្ចាំងអំពីគុណនាមទាំងនោះនៅពេលក្រោយ។ បង្រួមក្រុមតូចៗចូលគ្នាវិញ ដើម្បីដំណើរការវគ្គក្រុមធំដើម្បីពិភាក្សាបន្តលើ៖

- មូលហេតុដែលក្រុមនានាធ្វើការភ្ជាប់ទំនាក់ទំនងករណីសិក្សានីមួយជាមួយភេទបុរស ឬស្ត្រី?
- លក្ខណៈនៃលទ្ធផលដែលអាចកើតឡើង និងរបៀប/មូលហេតុដែលលទ្ធផលទាំងនោះអាចមានភាពខុសគ្នា?
  + តើលទ្ធផលដែលពាក់ព័ន្ធ វាមានភាពខុសគ្នាទៅតាមពេលវេលាដែរឬទេ? ឬដោយរបៀបណា? និងតើភាពខុសគ្នានេះបានប្រាប់អ្វីខ្លះដល់យើង? (ការយល់ឃើញអំពីយេនឌ័រមានការប្រែប្រួលទៅតាមពេលវេលា)

២. ទាញចំណាប់អារម្មណ៍សិក្ខាកាមឲ្យផ្តោតទៅលើផ្ទាំងក្រដាសធំនៅលើជញ្ជាំង ដែលមានគុណនាមដែលពួកគេបានកំណត់រកឃើញនោះ។ អ្នកសម្របសម្រួលគួរតែស្នើសុំឲ្យពួកគេធ្វើការឆ្លុះបញ្ចាំងអំពីប្រភេទពាក្យ ដែលស្ថិតនៅក្រោមភេទនីមួយៗ។ អ្នកសម្របសម្រួលអាចទទួលបានចម្លើយ តាមរយៈការសួរសំណួរដូចជា៖

- តើអ្នកនឹងពណ៌នាអំពីប្រភេទពាក្យនានា ដែលត្រូវបានប្រើប្រាស់នៅក្រោម

កូឡោននីមួយៗយ៉ាងដូចម្តេចខ្លះ?

- ប្រសិនបើអ្នកត្រូវពណ៌នាដោយនរណាម្នាក់ថាមានចរិកលក្ខណៈដូចគុណនាមទាំងនោះ តើវានឹងធ្វើឲ្យអ្នកមានអារម្មណ៍យ៉ាងដូចម្តេចដែរ? (ការពង្រឹងភាពអង្គអាច ឬការបំបាក់ភាពអង្គអាច។ល។)
- តើអ្នកមានឧទាហរណ៍អ្វីផ្សេងទៀតដែលធ្វើឲ្យបុរស និងស្ត្រីបញ្ចេញអាកប្បកិរិយាខុសគ្នាដែរឬទេ? ឧទាហរណ៍៖
  + នៅពេលប្រារព្ធពិធីតាមបែបវប្បធម៌/សាសនា?
  + នៅថ្ងៃចុងសប្តាហ៍
  + នៅពេលជាយុវវ័យ

ហើយក៏អាចពន្យល់សិក្ខាកាមថា សកម្មភាពនៅព្រឹកនេះគួរតែធ្វើជាគំរូមួយ ដែលថាយេនឌ័រពុំមានលក្ខណៈជីវសាស្ត្រនោះទេ ប៉ុន្តែផ្ទុយមកវិញ វាត្រូវបានបង្កើតឡើងដោយសង្គមមួយដែលមានការប្រែប្រួលទៅតាមពេលវេលា។ នៅក្នុងសកម្មភាពនៃមេរៀននេះ សបញ្ជាក់ពីភាពខុសគ្នាលើ ការរំពឹងទុកពីការបញ្ចេញការវិការរបស់បុគ្គលម្នាក់ៗ ហើយក៏អាស្រ័យទៅតាមភេទនីមួយផងដែរ។ នៅក្នុងម៉ោងសិក្សាបន្ទាប់ យើងនឹងសិក្សាស្វែងយល់អំពីចំណុចនានា ដែលជួយកំណត់តួនាទីយេនឌ័រ ការយល់ឃើញអំពីយេនឌ័រ។ល។ ឲ្យកាន់តែស៊ីជម្រៅជាងនេះទៀត។

# ម៉ោងសិក្សាទីបី

# ការប្រាស្រ័យទាក់ទងក្នុងសង្គមទៅតាមយេនឌ័រ

**គោលបំណង៖** ដើម្បីកំណត់រកបុព្វហេតុនានា ដែលយេនឌ័រត្រូវបានបង្កើតឡើង និងត្រូវបានរកឃើញនៅក្នុងសង្គម

## វត្ថុបំណងនៃការរៀនសូត្រ៖

នៅចុងបញ្ចប់នៃម៉ោងសិក្សានេះ សិក្ខាកាមនឹងអាច...

- បានស្វែងយល់អំពីតួនាទីរបស់ពាក្យស្លោកបុរាណនៅក្នុងការប្រកាន់ខ្ជាប់តាមនិយាមយេនឌ័រ
- បានកំណត់រកឃើញភាពជាបុរស និងភាពជាស្ត្រីនៅក្នុងបរិបទវប្បធម៌។

**ពេលវេលា៖** ៩០ នាទី

| **សេចក្តីពណ៌នាអំពីធនធាន** | **សេចក្តីណែនាំអំពីការត្រៀមសម្ភារៈ** |
|---|---|
| ការធ្វើបទបង្ហាញ | ជ្រើសយកឧទាហរណ៍មួយចំនួនទាក់ទងនឹងពាក្យស្លោកបុរាណទាក់ទងនឹងយេនឌ័រដូចជា «មនុស្សប្រុសរឹងមាំមិនត្រូវយំ« «ទីកន្លែងរបស់ស្ត្រីគឺនៅក្នុងផ្ទះបាយ» ជាដើម។ |
| ផ្ទាំងក្រដាសធំមួយចំនួន សម្រាប់ក្រុមនីមួយៗ | |

## ទិដ្ឋភាពទូទៅនៃម៉ោងសិក្សានេះ

| **សកម្មភាព** | **គោលបំណង** | **ពេលវេលា** |
|---|---|---|
| ពាក្យស្លោកបុរាណ | ណែនាំអំពីការប្រាស្រ័យទាក់ទងក្នុងសង្គមទៅតាមយេនឌ័រ តាមរយៈពាក្យស្លោកបុរាណ | ៩០ នាទី |

## **សកម្មភាពទីមួយ៖** ពាក្យស្លោកបុរាណ

**គោលបំណង៖** ដើម្បីណែនាំអំពីការប្រាស្រ័យទាក់ទងក្នុងសង្គមទៅតាមយេនឌ័រ

**សេចក្តីណែនាំសម្រាប់អ្នកសម្របសម្រួល**

**១.១ សម្គាល់ពាក្យស្លោក** (២០ នាទី)

១. គ្រូបណ្តុះបណ្តាលគួរតែត្រៀមជាមុននូវឧទាហរណ៍ពីរ ឬបី នៃពាក្យស្លោកបុរាណដែលមានដោយផ្តោតលើយេនឌ័រជាពិសេស ឧទាហរណ៍៖ «មនុស្សប្រុសរឹងមាំ មិនយំ» «ទីកន្លែងរបស់ស្ត្រីគឺនៅក្នុងផ្ទះបាយ»។

២. ណែនាំអំពីពាក្យស្លោកទាំងនោះទៅកាន់ក្រុម និងសួរថាតើពួកគេស្គាល់ពាក្យស្លោកទាំងនោះដែរឬទេ។

៣. បែងចែកសិក្ខាកាមជាក្រុមតូចៗ និងកំណត់កិច្ចការជូនពួកគេ ដោយឲ្យពួកគេគិតអំពីពាក្យស្លោកបែបនេះ ដែលមាននៅក្នុងវប្បធម៌របស់ពួកគេ ឲ្យបានច្រើនបំផុតតាមដែលអាចធ្វើបាន។ ឲ្យពួកគេសរសេរពាក្យស្លោកទាំងនោះនៅលើផ្ទាំងក្រដាសធំ។

៤. ២០ នាទីក្រោយមក ស្នើសុំឲ្យក្រុមនានាធ្វើការចែករំលែកពាក្យស្លោកមួយចំនួន និងអញ្ជើញក្រុមនានាឲ្យបន្ថែមពាក្យស្លោករបស់ក្រុមដទៃទៀតនៅលើផ្ទាំងក្រដាសធំរបស់ពួកគេ ប្រសិនបើពួកគេមិនទាន់មានពាក្យស្លោកទាំងនោះ។

រូបភាព: UNODC/ UN Women

**១.២ ការវិភាគពាក្យស្លោក** (៤០ នាទី)

១. ផ្តល់ជូនក្រុមនីមួយៗនូវផ្ទាំងក្រដាសធំមួយសន្លឹក និងស្នើសុំឲ្យពួកគេបែងចែកផ្ទាំងក្រដាសធំនោះជាពីរកូឡោន នៅផ្នែកខាងលើបំផុតនៃកូឡោនមួយ សរសេរពាក្យ បុរស និងនៅផ្នែកខាងលើបំផុតនៃកូឡោនមួយផ្សេងទៀត សរសេរពាក្យ ស្ត្រី។

២. ពន្យល់ថា នៅពេលនេះ ពួកគេគួរតែអានគ្រប់ពាក្យស្លោកទាំងអស់ និងសង្ខេបអំពីអត្ថន័យរបស់ពាក្យស្លោកទាំងនោះជាប្រយោគមួយ ឬជាពាក្យពេចន៍ពីរឬបីម៉ាត់ ហើយសរសេរសេចក្តីសង្ខេបនោះនៅក្នុងកូឡោនដែលពាក់ព័ន្ធ ឧទាហរណ៍ សម្រាប់ពាក្យស្លោក៖

- "មនុស្សប្រុសរឹងមាំ មិនយំ" ពួកគេអាចសរសេរថា - បុរសមិនគួរបង្ហាញអារម្មណ៍នោះទេ។
- "ទីកន្លែងរបស់ស្ត្រីគឺនៅក្នុងផ្ទះបាយ" ពួកគេអាចសរសេរថា - តួនាទីរបស់ស្ត្រី គឺមើលថែទាំផ្ទះ។

ប្រាប់ទៅក្រុមនីមួយៗថាពួកគាត់មានពេល ២០នាទីសម្រាប់កិច្ចការមួយនេះ។

៣. ២០ នាទីក្រោយមក បង្រួមក្រុមចូលគ្នាវិញម្តងទៀត និងពន្យល់ថា ជំហានបន្ទាប់នៅក្នុងការវិភាគ គឺការអានសេចក្តីសង្ខេបនានា និងធ្វើបញ្ជីមួយនៃចរិកលក្ខណៈជាទូទៅមួយដែលអាចបញ្ជាក់ថាជាបុគ្គលិកលក្ខណៈរបស់បុរស ឬស្ត្រី។ ដើម្បីធ្វើកិច្ចការនេះបានសិក្ខាកាមគួរតែអានសេចក្តីសង្ខេបទាំងអស់ និងកំណត់សម្គាល់មូលបទ និងសម្គាល់ថាតើមូលបទទាំងនោះបានកើតឡើងម្តងហើយ ម្តងទៀតចំនួនប៉ុន្មានដង។ ឧទាហរណ៍៖ មូលបទមួយប្រហែលជាអាចលើកឡើងថា បុរសមិនគួរបង្ហាញអារម្មណ៍នោះទេ ហើយវាអាចជាអត្ថន័យដែលនៅពីក្រោយពាក្យស្លោកជាច្រើន ដូច្នេះវាគឺជាមូលបទដែលត្រូវបានទទួលស្គាល់យ៉ាងជាទូទៅ និងគួរតែស្ថិតនៅផ្នែកខាងលើបំផុតនៃបញ្ជីរបស់បុរស។ អ្វីដែលយើងរៀនបានពីកិច្ចការនេះគឺ ដើម្បីទទួលបានបញ្ជីចរិកលក្ខណៈរបស់បុរស និងបញ្ជីចរិកលក្ខណៈរបស់ស្ត្រី។

**១.៣ វគ្គក្រុមធំ** (៣០ នាទី)

១. នាំក្រុមតូចៗឲ្យត្រឡប់មកជាក្រុមធំវិញ និងទទួលយកមតិត្រឡប់នៅលើបញ្ជីរបស់ក្រុមនោះ បង្កើតបញ្ជីប្រមូលផ្តុំមួយ នៅខាងមុខបន្ទប់បណ្តុះបណ្តាល ស្តីពីចរិកលក្ខណៈរបស់បុរស ធៀបនឹង ចរិកលក្ខណៈរបស់ស្ត្រី។

២. សួរសំណួរដូចខាងក្រោម៖

- តើអ្នកយល់ស្របដែរឬទេថា លក្ខណៈពិសេសឬចរិកលក្ខណៈសម្រាប់បុរសឬស្ត្រី

ទាំងនេះ ត្រូវបានអនុវត្តនៅក្នុងសង្គមរបស់អ្នកដែរឬទេ?

- តើតាមវិធីណាខ្លះ ដែលលក្ខណៈពិសេសឬចរិកលក្ខណៈដែលយើងបានកំណត់រកឃើញនេះបានធ្វើការរឹតត្បិតចំពោះបុរសឬស្ត្រី?
- នៅក្នុងនាមជាបុរសឬស្ត្រីម្នាក់ តើមានពាក្យស្លោកណាមួយស្តីពីយេនឌ័ររបស់អ្នកដែលអ្នកមិនចូលចិត្តជាពិសេសដែរឬទេ? ហេតុអ្វី?
- តើតាមវិធីណាខ្លះ ដែលលក្ខណៈពិសេសឬចរិកលក្ខណៈដែលយើងបានកំណត់រកឃើញនេះបានបង្កើនភាពអង់អាចដល់បុរសឬស្ត្រី?
- នៅក្នុងនាមជាបុរស/ស្ត្រីម្នាក់ តើមានពាក្យស្លោកណាមួយស្តីពីយេនឌ័ររបស់អ្នកដែលអ្នកចូលចិត្តជាពិសេសដែរឬទេ? ហេតុអ្វី?
- តើមានពាក្យស្លោកណាមួយដែលអ្នកបានមើលឃើញ អាចលើកទឹកចិត្តយេនឌ័រមួយឲ្យប្រព្រឹត្តិអវិជ្ជមានចំពោះយេនឌ័រមួយផ្សេងទៀតដែរឬទេ?

ឥទ្ធិពលរបស់ពាក្យស្លោកទាំងនោះ គឺជាពាក្យស្លោកបុរាណ ដែលបានចាក់ឫសយ៉ាងជ្រៅពីមួយជំនាន់ទៅមួយជំនាន់។

អ្នកសម្របសម្រួល គួរតែផ្តល់ការណែនាំអំពីការអនុវត្តកិច្ចការនេះតាមរយៈវិធីមួយ ដែលលើកទឹកចិត្តសិក្ខាកាមឲ្យធ្វើការឆ្លុះបញ្ចាំង អំពីផលប៉ះពាល់នៃពាក្យស្លោកទាំងនេះ ចំពោះរបៀបដែលអ្នកដទៃមានការយល់ឃើញចំពោះយេនឌ័រខុសៗគ្នា។ ជាទូទៅ ដំណាក់កាលនៃការវិភាគលើកទឹកចិត្តរបស់សិក្ខាកាម ឲ្យចាប់ផ្តើមកត់សម្គាល់ និយាមនៃភាពជាបុរសដែលជះឥទ្ធិពលអវិជ្ជមាន ដូចជានៅក្នុងចំណោមពាក្យស្លោកនានា៖

- បុរសមិនអាចបង្ហាញអារម្មណ៍បាននោះទេ
- ស្ត្រីគួរតែផ្តោតលើការងារផ្ទះ និងគ្រួសារច្រើនជាងការងាររកលុយ
- ស្ត្រីត្រូវបានគេប្រៀបដូចជាវត្ថុ តាមរយៈរូបរាងខាងក្រៅរបស់ពួកគេ
- សម្ពាធលើបុរស ដែលត្រូវតែមានភាពរឹងមាំផ្នែករាងកាយ និងធ្វើជាអ្នករាប់រងបន្ទុក។

### កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល

ការលើកទឹកចិត្តសិក្ខាកាមឲ្យមានការយល់ដឹង និងជ្រួតជ្រាបចំពោះការប្រាស្រ័យទាក់ទងក្នុងសង្គមទៅតាម យេនឌ័រ និងរបៀបដែលបទដ្ឋានយេនឌ័រត្រូវបានចាក់ឫក និងត្រូវបានពង្រឹងកាន់តែខ្លាំង គឺវាមានសារៈសំខាន់ខ្លាំងណាស់ ដែលមនុស្សជាច្រើននៅមានចម្ងល់ជាច្រើនជុំវិញបញ្ហានេះ។ ការយល់ដឹងពីការប្រាស្រ័យទាក់ទងក្នុងសង្គមទៅតាមយេនឌ័រ គឺជាជំហានដំបូងនៅក្នុងការបង្កើនសមត្ថភាពរបស់សិក្ខាកាម ដើម្បីចូលរួមនៅក្នុងប្រធានបទនានាដែលត្រូវបានបង្ហាញនៅក្នុងម៉ោងសិក្សាបន្ទាប់ៗទៀត។

# ម៉ោងសិក្សាទីបួន

# ការប្រាស្រ័យទាក់ទងក្នុងសង្គមទៅតាមយេនឌ័រ និងបិតុនិយម

**គោលបំណង៖** ដើម្បីកំណត់រកបុព្វហេតុនានា ដែលយេនឌ័រត្រូវបានបង្កើតឡើង និង ត្រូវបានរកឃើញនៅក្នុងសង្គម

**វត្ថុបំណងនៃការរៀនសូត្រ៖**

នៅចុងបញ្ចប់នៃម៉ោងសិក្សានេះ សិក្ខាកាមនឹងអាច...

- រំឭកឡើងវិញអំពីទិដ្ឋភាពនានានៃទស្សន:ស្តីពីការប្រាស្រ័យទាក់ទងសង្គមទៅតាមយេនឌ័រ
- ពន្យល់ថាតើ «បិតុនិយម» មានអត្ថន័យយ៉ាងដូចម្តេច
- កំណត់រកកត្តាខុសៗគ្នានៅក្នុងសង្គមដែលជះឥទ្ធិពល និង បង្កើតទ្រង់ទ្រាយនៃការយល់ឃើញរបស់យើងអំពី យេនឌ័រ។

**ពេលវេលា៖** ៩០ នាទី

| **សេចក្តីពណ៌នាអំពីធនធាន** | **សេចក្តីណែនាំអំពីការត្រៀមសម្ភារៈ** |
|---|---|
| ការធ្វើបទបង្ហាញ | |
| កិច្ចការទាក់ទងនឹងសង្គមបែបបិតុនិយម សកម្មភាព១.៤.១<br><br>ផ្ទាំងក្រដាសធំស្រាប់ក្រុមនីមួយៗ<br><br>ផ្ទាំងកាតឥទ្ធិពលសម្រាប់ក្រុមនីមួយៗ | ១.៤.១ ផ្ទាំងកាតឥទ្ធិពល៖ សម្រាប់កិច្ចការនេះ អ្នកសម្របសម្រួលគួរតែជ្រើសរូបថត ឬរូបភាពមួយចំនួនដែលមានទំនាក់ទំនងវប្បធម៌ ដែលសមស្របនឹងបរិបទរបស់សិក្ខាកាម។ |

## ទិដ្ឋភាពទូទៅនៃម៉ោងសិក្សានេះ

| សកម្មភាព | គោលបំណង | ពេលវេលា |
|---|---|---|
| ការប្រាស្រ័យទាក់ទងក្នុងសង្គមទៅតាមយេនឌ័រ និងបិតុនិយម | ដើម្បីណែនាំអំពីបិតុនិយម និងនិយាមនៃភាពជាបុរសដែលជះឥទ្ធិពលអវិជ្ជមាន និងសិក្សាស្វែងយល់បន្ថែមទៀតអំពីការប្រាស្រ័យទាក់ទងក្នុងសង្គមទៅតាមយេនឌ័រ | ៩០ នាទី |

## សកម្មភាពទីមួយ៖ ការប្រាស្រ័យទាក់ទងក្នុងសង្គមទៅតាមយេនឌ័រ និងបិតុនិយម

**គោលបំណង៖** ដើម្បីណែនាំអំពីបិតុនិយម និងនិយាមនៃភាពជាបុរសដែលជះឥទ្ធិពលអវិជ្ជមាន និងសិក្សាស្វែងយល់បន្ថែមទៀតអំពីការប្រាស្រ័យទាក់ទងក្នុងសង្គមទៅតាមយេនឌ័រ

**សេចក្តីណែនាំសម្រាប់អ្នកសម្របសម្រួល**

**១.១ ការធ្វើបទបង្ហាញជាស្លាយ** (១៥ នាទី)

១. ពន្យល់ថា ម៉ោងសិក្សានេះពង្រឹងបន្ថែមពីលើម៉ោងសិក្សាមុនដែលពួកគេបានសិក្សាស្វែងយល់អំពីពាក្យស្លោកបុរាណដែលប្រកាន់ខ្ជាប់តាមនិយាមយេនឌ័រ។

២. បង្ហាញទៅកាន់សិក្ខាកាមនូវស្លាយ និងស្នើសុំឲ្យពួកគេពិភាក្សាគ្នា៖

### ពិភាក្សា

«តើការប្រាស្រ័យទាក់ទងក្នុងសង្គមទៅតាម យេនឌ័រ មានអត្ថន័យយ៉ាងដូចម្តេច?»

៣. ស្វាគមន៍ការផ្តល់មតិត្រឡប់ និងដាក់រួមបញ្ចូលគ្នាជាមួយស្លាយនោះNow show the




៤. នៅពេលនេះ ចូរបង្ហាញស្លាយដែលស្តីពីបិតុនិយម និងពន្យល់អំពីទស្សនាទាននោះទៅកាន់សិក្ខាកាមៈ




[4] https://blogs.unicef.org/evidence-for-action/what-is-gender-socialization-and-why-does-it-matter/.

៥. អាចពន្យល់សិក្ខាកាមថាថា សង្គមបិតុនិយមត្រូវបានប្រកាន់ខ្ជាប់ដោយមានវត្តមាននិយាមយេនឌ័រត្រូវបានបង្កើតឡើង និងត្រូវបានប្រកាន់ខ្ជាប់។ ដូចដែលបានសិក្សាស្វែងយល់កាលពីម្សិលមិញ តាមរយៈរបៀបដែលពាក្យស្លោកបានផ្តល់បង្ហាញពីអត្ថន័យជាស្ត្រី ឬបុរសនៅក្នុងសង្គមនេះ។

៦. អាចពន្យល់បន្ថែមថា ពួកគេនឹងសិក្សាស្វែងយល់អំពីចំណុចនេះបន្ថែមទៀត តាមរយៈការធ្វើកិច្ចការជាក្រុម។

**១.២ ការងារជាក្រុម៖ កាតកត្តាជះឥទ្ធិពល (៥០ នាទី)**

*កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួលនៅក្នុងការបង្កើតធនធាន*

ធនធាន ១.៤.១ កាតឥទ្ធិពលសម្រាប់កិច្ចការនេះគួរតែត្រូវបានបង្កើតឡើងដោយអ្នកសម្របសម្រួលមុនពេលបណ្តុះបណ្តាល ពីព្រោះពួកគេនឹងចាំបាច់ត្រូវតែជាប់ពាក់ព័ន្ធនឹងវប្បធម៌សម្រាប់បរិបទប្រទេស។ កិច្ចការនេះអាចដំណើរការបានដោយមិនចាំបាច់មានកាតឥទ្ធិពលនោះទេ ប៉ុន្តែការប្រើប្រាស់រូបថតដែលជាប់ពាក់ព័ន្ធនឹងវប្បធម៌ នឹងជួយជម្រុញឲ្យការពិភាក្សាជាក្រុមល្អជាងមុន។[៥]

កាតកត្តាជះឥទ្ធិពល ១.៤.១ គួរតែមានចំណុចនានាដូចខាងក្រោម៖

១. កាតទំហំ A៤ មួយកញ្ចប់ ដែលនៅលើកាតនីមួយៗមានពាក្យកត្តាជះឥទ្ធិពលដូចខាងក្រោម៖

- សាសនា
- នយោបាយ
- ការអប់រំ
- ការងារ
- ប្រព័ន្ធផ្សព្វផ្សាយ/ប្រព័ន្ធផ្សព្វផ្សាយសង្គម

២. រួមជាមួយពាក្យ "កត្តាជះឥទ្ធិពល" អ្នកសម្របសម្រួលត្រូវបានណែនាំថា កាតនីមួយៗគួរតែមានរូបភាពផ្សេងៗ ដែលបង្កើតឲ្យមានការពិភាក្សាអំពីរបៀបដែលបិតុនិយម និងភាពជាបុរសដែលជះឥទ្ធិពលអវិជ្ជមានត្រូវបានប្រកាន់ខ្ជាប់ដោយកត្តាជះឥទ្ធិពលខាងលើទាំងនោះ។ អ្នកសម្របសម្រួលអាចទទួលបានពាក្យកត្តាជះឥទ្ធិពលទាំងនេះតាមរយៈការថតចម្លងពាក្យកត្តាជះឥទ្ធិពលទាំងនេះពីអ៊ីនធឺណិត និងប្រភពផ្សេងៗទៀត។ គំនិតមួយចំនួន អំពីអ្វី ដែលត្រូវអាចដាបញ្ចូលក្នុងកាតទាំងនោះ រួមមានដូចខាងក្រោម៖

- សាសនា៖ វិធាន រូបភាពរបស់បព្វជិតដែលជាបុរស (ស្ត្រីមិនត្រូវបានអនុញ្ញាតនោះទេ) សម្លៀកបំពាក់សាសនា

[៥] https://trainingcentre.unwomen.org/mod/glossary/view.php?id=36&mode=letter&hook=P&sortkey=&sortorder=

- នយោបាយ៖ ស្ថិតិអ្នកតំណាងដែលជាស្ត្រីឬបុរស រូបថត ចំណងជើងការសែត
- ការអប់រំ៖ ឯកសណ្ឋាន រូបថតនៃការប្រឡង ស្ថិតិ
- ការងារ៖ ស្ថិតិអ្នកតំណាងដែលជាស្ត្រីឬបុរសនៅក្នុងថ្នាក់ដឹកនាំ រូបថត ចំណងជើងការសែត
- ប្រព័ន្ធផ្សព្វផ្សាយ/ប្រព័ន្ធផ្សព្វផ្សាយសង្គម៖ ការតំណាងឲ្យ "រាងកាយដែលល្អឥតខ្ចោះ" កម្មវិធីបែងចែកប្រភេទនៃការចូលមើលព័ត៌មានណាមួយតាមប្រព័ន្ធអ៊ីនធឺណិត (filter) គេហទំព័រខុសៗគ្នានៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម ការផ្សាយពាណិជ្ជកម្មអំពីផលិតផលមួយចំនួនដែលមានបំណងសំដៅទៅរកយេនឌ័រខុសៗគ្នា និង សារដែលនៅពីក្រោយការផ្សាយពាណិជ្ជកម្មទាំងនោះ។

**កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល**

១. បែងចែកសិក្ខាកាមជាក្រុមតូចៗ និងផ្តល់ជូនក្រុមនីមួយៗនូវផ្ទាំងក្រដាសធំមួយសន្លឹក និងស្នើសុំឲ្យពួកគេបង្កើតសំណៅចម្លងមួយច្បាប់នៃគំរូដ្យាក្រាមពីងពាងនៅលើស្លាយនៅក្នុងក្រុមរបស់ពួកគេ។




២. ពន្យល់ថា សម្រាប់ប្រភេទនីមួយៗនៅក្នុងចំណោមកត្តាជះឥទ្ធិពលទាំងប្រាំប្រភេទ ពួកគេគួរតែពិភាក្សាគ្នាអំពីសំណួរនានាដូចខាងក្រោម និងកត់ត្រានៅលើដ្យាក្រាមពីងពាងរបស់ពួកគេ និងរៀបរៀងគំនិតរបស់ពួកគេតាមវិធីដែល ឧទាហរណ៍សម្រាប់កត្តាសាសនា ត្រូវបានបញ្ចប់រួចរាល់ហើយ។

- តើ "កត្តាជះឥទ្ធិពល" ទាំងនេះបង្កឱ្យមានការរំពឹងទុកអ្វីខ្លះទៅលើបុរស និង ស្ត្រី?
- តើមានវិធាន (ផលប៉ះពាល់ផ្នែកផ្លូវច្បាប់ និងផ្នែកវប្បធម៌) អ្វីដែរឬទេ ដែលពាក់ព័ន្ធទៅនឹងកត្តាជះឥទ្ធិពលនេះ ដែលបង្កើតឲ្យមានភាពខុសគ្នារវាងយេនឌ័រផ្សេងគ្នា? (ឧទាហរណ៍ ច្បាប់ដែលមិនអនុញ្ញាតឲ្យស្ត្រីធ្វើការបើកបរ)។

ក្រុមនីមួយៗគួរតែចំណាយពេល ១០ នាទី លើកត្តាជះឥទ្ធិពលនីមួយៗ ដោយពិភាក្សាអំពីសំណួរនានាដែលស្ថិតនៅក្នុងបរិបទនៃកត្តាជះឥទ្ធិពលនោះ និងរៀបរៀងគំនិតរបស់ពួកគេនៅលើដ្យាក្រាមពីងពាង។ (៥០ នាទី)

**១.៣ វគ្គក្រុមធំ (២៥ នាទី)**

១. ជួយសម្របសម្រួលប្រមូលផ្តល់មតិត្រឡប់ ទាញយកចំណុចសំខាន់ៗដែលក្រុមនានាបានពិភាក្សាអំពីកត្តាជះឥទ្ធិពលនីមួយៗ ឧទាហរណ៍អាចរួមមាន (ជាអាទិ៍)៖

**សាសនា៖**

- មានក្រមនៃការស្លៀកពាក់តាមបែបសាសនាសម្រាប់បុរស និងស្ត្រី
- សេចក្តីរំពឹងទុកមួយចំនួនត្រូវបានដាក់លើយេនឌ័រ តាមរយៈក្រមឬវិធានស្តីពីការរៀបអាពាហ៍ពិពាហ៍
- បុរស និងស្ត្រីត្រូវបានរំពឹងទុកឲ្យអនុវត្តតាមទម្លាប់មួយចំនួន ឧទាហរណ៍ ការកាត់ប្រដាប់ភេទស្ត្រី ((FGM/C) ការតមអាហារ ការនៅឆ្ងាយពីអ្នកដទៃក្នុងអំឡុងពេលមករដូវ។ល។
- ស្ត្រីមិនត្រូវបានអនុញ្ញាតឲ្យអនុវត្តតួនាទីមួយចំនួននៅក្នុងសាសនានោះទេ ពោលគឺថ្នាក់ដឹកនាំ
- ភាសាដែលត្រូវបានប្រើប្រាស់នៅក្នុងលទ្ធិសាសនាមានលក្ខណៈបិតុនិយម ពាក្យ «គាត់» ជាញឹកញាប់ ត្រូវបានប្រើប្រាស់ដើម្បីបង្ហាញអំពីឧត្តមភាព។

**នយោបាយ**

- វត្តមានរបស់ស្ត្រីនៅក្នុងផ្នែកនយោបាយមានតិច ជាពិសេសនៅក្នុងតួនាទីធ្វើសេចក្តីសម្រេច
- នៅក្នុងវប្បធម៌មួយចំនួន ស្ត្រីមិនត្រូវបានអនុញ្ញាតឲ្យ ចូលរួមនៅក្នុងការធ្វើសេចក្តីសម្រេចផ្នែកនយោបាយនោះទេ។

**ការងារ៖**

- មានការពិបាកនៅក្នុងវិវត្តទៅកាន់មុខតំណែងជាថ្នាក់ដឹកនាំ
- ការងារមួយចំនួនមានភាពអំណោយផលចំពោះភេទណាមួយជាពិសេស ឧទាហរណ៍ តួនាទីនៃវិជ្ជាជីវៈផ្នែកការថែទាំភាគច្រើនជាស្ត្រី និងវិជ្ជាជីវៈផ្នែកសាងសង់ភាគច្រើនជាបុរស
- តុល្យភាពយេនឌ័រនៅក្នុងអង្គភាពអនុវត្តច្បាប់
- ស្ត្រីភាគច្រើនមានអារម្មណ៍ថាពួកគេត្រូវធ្វើការជ្រើសរើសរវាងការងាររបស់ពួកគេ និងការមើលថែទាំគ្រួសារ។

[6] មើលនៅក្នុងតំណភ្ជាប់នេះសម្រាប់ឧទាហរណ៍តាមតំបន់. http://www.unwomen.org/en/digital-library/publications/2019/03/women-in-politics-2019-map

រូបភាព: UNODC/ UN Women/ Ploy Phutpheng

**ប្រព័ន្ធផ្សព្វផ្សាយ/ប្រព័ន្ធផ្សព្វផ្សាយសង្គមៈ**

- រូបភាពនៃផ្នត់គំនិតយេនឌ័រ
- ការកែប្រែពណ៌រូបថត (photograph filters) នៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម ធ្វើឲ្យផ្នត់គំនិតយេនឌ័រកាន់តែខ្លាំងជាងមុន
- ភាសាដែលធ្វើឲ្យរំជួលចិត្ត ឬភាសាដែលមានការបែងចែក
- សម្តាធពីការរំពឹងទុកលើរូបភាព យេនឌ័រ ដូចជាការបង្ហាញពីប្រភេទជីវិតដែលល្អឥតខ្ចោះ
- អាចធ្វើការចូលប្រើប្រព័ន្ធផ្សព្វផ្សាយកាន់តែប្រសើរជាមួយនឹងបច្ចេកវិទ្យា

**ការអប់រំៈ**

- សារដែលត្រូវបានបញ្ជូននៅក្នុងកម្មវិធីសិក្សាអាចប្រកាន់ខ្ជាប់នូវផ្នត់គំនិតយេនឌ័រ
- ជំនឿរបស់គ្រូបង្រៀន អាចបង្កើតឱ្យមាននូវការព្យាករណ៍ទុកមុនដែលសម្រេចដោយគ្រូខ្លួនឯង ទៅលើការរំពឹងទុក អាកប្បកិរិយា និងលទ្ធផលសិក្សារបស់កូនសិស្សខ្លួន ឬហៅថាឥទ្ធិពលនៃសេចក្តីរំពឹងទុក(the Pygmalion Effect)
- កុមារី ជាញឹកញាប់ត្រូវបានបង្ខំឲ្យឈប់រៀនមុនកុមារា ជាពិសេសនៅតំបន់ដែលភាពក្រីក្រមានកម្រិតខ្ពស់
- មុខវិទ្យាមួយចំនួនមានទំនោរទៅកាន់ទៅរកកុមារី ធៀបនឹង កុមារា ឧ. ថ្នាក់គេហកិច្ចមានបំណងសំដៅទៅរកកុមារី

អ្នកសម្របសម្រួលគួរតែលើកទឹកចិត្តសិក្ខាកាមឲ្យធ្វើការឆ្លុះបញ្ចាំង ឲ្យបានច្បាស់លាស់អំពីតម្រូវការក្នុងការប្រកួតប្រជែង និងផ្លាស់ប្តូរផ្នត់គំនិតយេនឌ័រ និងទម្លាប់អនុវត្តការរើសអើងនានា ដោយលើកឡើងអំពីសន្ធិសញ្ញាអន្តរជាតិដែលត្រូវបានគ្របដណ្តប់លើ ផ្នែកខាងក្រោយនៅក្នុងមេរៀនទី ១នេះ។

---

[៧] https://www.duq.edu/about/centers-and-institutes/center-for-teaching-excellence/teaching-and-learning/pygmalion

# ថ្ងៃទី ២

## ម៉ោងសិក្សាទីមួយ

## ទំនោរផ្លូវភេទ និងអត្តសញ្ញាណកម្មភេទ

**គោលបំណង៖** សិក្សាស្វែងយល់អំពីអត្ថន័យរបស់ទំនោរផ្លូវភេទ និងអត្តសញ្ញាណកម្មយេនឌ័រ

**វត្ថុបំណងនៃការរៀនសូត្រ៖**

នៅចុងបញ្ចប់នៃម៉ោងសិក្សានេះ សិក្ខាកាមនឹង...

- អាចកំណត់និយមន័យពាក្យបច្ចេកទេសគន្លឹះរបស់អ្នកស្រលាញ់ភេទដូចគ្នា ឬ LGBTI
- បានពិភាក្សាអំពីឥរិយាបថតាមផ្លូវច្បាប់ ឥរិយាបថនៅក្នុងសង្គម និងវប្បធម៌ដែលមានចំពោះសហគមន៍LGBTIនៅក្នុងបរិបទតំបន់ ឬប្រទេស

**ពេលវេលា៖** ៩០ នាទី

| **សេចក្តីពណ៌នាអំពីធនធាន** | **សេចក្តីណែនាំអំពីការត្រៀមសម្ភារៈ** |
|---|---|
| ការធ្វើបទបង្ហាញ | |
| ២.៤.១៖ និយមន័យរបស់អ្នកស្រលាញ់ភេទដូចគ្នា ឬ LGBTI | ថតចម្លង១សន្លឹកសម្រាប់គូនីមួយៗ |

**ទិដ្ឋភាពទូទៅនៃម៉ោងសិក្សានេះ**

| **សកម្មភាព** | **គោលបំណង** | **ពេលវេលា** |
|---|---|---|
| គុណភាព អារម្មណ៍ និងអាកប្បកិរិយានានាត្រូវបានកំណត់ទៅតាមប្រភេទយេនឌ័រ និងផលប៉ះពាល់របស់វា | បង្កើតគំរូតាមការបែងចែកតួនាទីតាមយេនឌ័រនៅក្នុងសង្គម។ | ៩០ នាទី |

**កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល៖**

ប្រធានបទនេះតម្រូវឲ្យមានការអនុវត្តដោយយកចិត្តទុកដាក់ខ្ពស់ ហើយវិធីសាស្ត្របង្រៀននៅក្នុងម៉ោងសិក្សានេះត្រូវបានបង្កើតឡើងដើម្បីបង្ហាញសិក្ខាកាមថា អ្នកសម្របសម្រួលនឹងនៅក្បែរពួក និងធ្វើជាទីប្រឹក្សា។ ចំណុចពិភាក្សាគួរតែស្ថិតនៅក្បែរអង្គហេតុដែលងាយស្រួលចាប់បាន ជាជាងផ្តោតលើកត្តាទូទៅ ដែលធំនិងទូលំទូលាយ។

នៅក្នុងបរិបទនៃប្រទេសមួយចំនួន មានការណែនាំថា មិនគួរអនុវត្តម៉ោងសិក្សានេះនោះទេ។ អ្នកសម្របសម្រួលគួរតែទំនាក់ទំនងជាមួយអ្នកគ្រប់គ្រង ឬដៃគូកម្មវិធីប្រចាំប្រទេសមុនពេលចាប់ផ្តើមវគ្គបណ្តុះបណ្តាល។

## សកម្មភាពទីមួយ ៖ និយមន័យរបស់អ្នកស្រលាញ់ភេទដូចគ្នា ឬLGBTI

**គោលបំណង៖** ដើម្បីពន្យល់ពាក្យគន្លឹះរបស់អ្នកស្រលាញ់ភេទដូចគ្នា ឬLGBTI និងណែនាំអំពីសហគមន៍អ្នកស្រលាញ់ភេទដូចគ្នា ឬLGBTIនៅក្នុងបរិបទតំបន់ ឬប្រទេស។

**សេចក្តីណែនាំសម្រាប់អ្នកសម្របសម្រួល**

**១.១ ការងារជាគូ៖ និយមន័យពាក្យគន្លឹះ** (១៥ នាទី)

បំបែកសិក្ខាកាមជាគូៗ និងផ្តល់ជូនពួកគេនូវកញ្ចប់ ២.១.១៖ និយមន័យរបស់អ្នកស្រលាញ់ភេទដូចគ្នាឬLGBTI

ពន្យល់ថា ពួកគេមានពេល ១៥ នាទីដើម្បីភ្ជាប់ពាក្យគន្លឹះទាំងនោះទៅនឹងនិយមន័យនានា។

និយមន័យត្រូវបានយកចេញពីប្រភេទដែលត្រូវបានយោងដល់នៅក្នុងជើងទំព័រ ខាងក្រោម។

| ពាក្យគន្លឹះ | និយមន័យ |
| --- | --- |
| បុរសស្រឡាញ់ភេទដូចគ្នា | សំដៅលើមនុស្សប្រុសម្នាក់ដែលមានទំនោរផ្លូវចិត្ត ទំនោរផ្នែកមនោសញ្ចេតនា និង/ឬ ទំនោរផ្លូវភេទចំពោះមនុស្សប្រុស។ វាក៏ជាពាក្យទូទៅសម្រាប់កត្តាផ្លូវភេទរបស់មនុស្សស្រីស្រលាញ់ភេទដូចគ្នា និង មនុស្សប្រុសស្រឡាញ់ភេទដូចគ្នាដែរ - មនុស្សស្រីមួយចំនួនកំណត់ខ្លួនឯងថាជាមនុស្សប្រុសស្រឡាញ់ភេទដូចគ្នាច្រើនជាង មនុស្សស្រីស្រលាញ់ភេទដូចគ្នា |
| នារីស្រឡាញ់ភេទដូចគ្នា | សំដៅលើមនុស្សស្រីម្នាក់ដែលមានទំនោរផ្លូវចិត្ត ទំនោរផ្នែកមនោសញ្ចេតនា និង/ឬទំនោរផ្លូវភេទចំពោះមនុស្សស្រី។ |
| មនុស្សប្តូរភេទ* | មនុស្សប្តូរភេទ (នៅពេលខ្លះត្រូវបានហៅកាត់ថា "trans") គឺជាកម្រងពាក្យ ដែលត្រូវបានប្រើប្រាស់ដើម្បីបកស្រាយអំពីអត្តសញ្ញាណភេទជាច្រើនរបស់អ្នកដែលមានរូបរាង និងចរិកលក្ខណៈខុសប្លែកពីភេទធម្មតា — ដែលរួមមាន មនុស្សប្តូរភេទបន្ទាប់ពីវះកាត់ អ្នកស្លៀកពាក់សម្លៀកបំពាក់ផ្ទុយពីភេទរបស់ខ្លួន (ជួនកាលត្រូវបានគេហៅថា "មនុស្សស្លៀកពាក់ក្លែងខ្លួនភេទផ្ទុយ") និងមនុស្សដែលត្រូវបានគេសម្គាល់ថាជាមនុស្សភេទទីបី។ មនុស្សស្ត្រីប្តូរភេទត្រូវបានគេសម្គាល់ថាជាស្ត្រី ប៉ុន្តែត្រូវបានគេចាត់ថ្នាក់ថាជាបុរសនៅពេលកើត។ មនុស្សប្រុសប្តូរភេទត្រូវបានគេសម្គាល់ថាជាបុរស ប៉ុន្តែត្រូវបានគេចាត់ថ្នាក់ថាជាស្ត្រីនៅពេលកើត។ ស្របពេលជាមួយគ្នានេះ មនុស្សប្តូរភេទដទៃទៀតត្រូវបានគេសម្គាល់ថាគ្មានភេទទាំងពីរ។ មនុស្សប្តូរភេទមួយចំនួនស្វែងរកការវះកាត់ ឬចាក់អ័រម៉ូនដើម្បីរាងកាយរបស់ពួកគេស្របតាមអត្តសញ្ញាណយេនឌ័ររបស់ពួកគេ មនុស្សប្តូរភេទមួយចំនួនទៀតមិនស្វែងរកសេវាទាំងនោះទេ។ |
| មនុស្សស្រឡាញ់ភេទដូចគ្នា | នេះអាចត្រូវបានចាត់ទុកថាជាពាក្យវេជ្ជសាស្ត្រច្រើនជាង ដែលត្រូវបានប្រើប្រាស់ ដើម្បីបកស្រាយអំពីនរណាម្នាក់ដែលមានទំនោរផ្លូវចិត្ត ទំនោរផ្នែកមនោសញ្ចេតនា និង/ឬទំនោរផ្លូវភេទចំពោះនរណាម្នាក់ដែលមានភេទដូចគ្នា។ នៅពេលនេះ ពាក្យ "មនុស្សប្រុសស្រលាញ់ភេទដូចគ្នា" ត្រូវបានប្រើជាទូទៅជាង។ |

| | |
|---|---|
| មនុស្សស្រឡាញ់ភេទផ្ទុយគ្នា | សំដៅលើមនុស្សប្រុសម្នាក់ដែលមានទំនោរផ្លូវចិត្ត ទំនោរផ្នែកមនោសញ្ចេតនា និង/ឬទំនោរផ្លូវភេទចំពោះមនុស្សស្រី ឬមនុស្សស្រីម្នាក់ដែលមានទំនោរផ្លូវចិត្ត ទំនោរផ្នែកមនោសញ្ចេតនា និង/ឬទំនោរផ្លូវភេទចំពោះមនុស្សប្រុស។ |
| ចន្លោះភេទ** | មនុស្សដែលមានចន្លោះភេទបានកើតមកជាមួយនឹងចរិកលក្ខណៈភេទផ្លូវកាយ ឬតាមជីវសាស្ត្រ ដូចជាការវិភាគអំពីសារពាង្គកាយ ផ្លូវភេទ សរីរាង្គបន្តពូជ រចនាបទអ័រម៉ូន និង/ឬ រចនាបទក្រូម៉ូសូម ដែលមិនស័ក្តិសមនឹងនិយមន័យធម្មតានៃមនុស្សប្រុស ឬមនុស្សស្រី។ ចរិកលក្ខណៈទាំងនេះអាចមើលឃើញនៅពេលកើត ឬអាចលេចឡើងនៅពេលក្រោយនៅក្នុងជីវិត ជាញឹកញាប់ នៅពេលពេញវ័យ។ មនុស្សដែលមានចន្លោះភេទអាចមានទំនោរផ្លូវភេទ និងអត្តសញ្ញាណភេទណាមួយ។ |
| ដកស្រែងពី https://www.stonewall.org.uk/help-advice/glossary-terms<br><br>*https://www.unfe.org/definitions/<br><br>**https://www.unfe.org/definitions/ | |

**១.២ វគ្គក្រុមធំ/មតិត្រឡប់** (១៥ នាទី)

ពិភាក្សាជាមួយសិក្ខាកាម សួរសំណួរ និងផ្តល់ចម្លើយ

«តើទំនោរផ្លូវភេទ និងអត្តសញ្ញាណកម្មភេទមានភាពខុសគ្នាដូចម្តេចខ្លះ?»

**១.៣ កិច្ចពិភាក្សា** (៣០ នាទី)

បែងចែកសិក្ខាកាមជាក្រុមតូចៗ និងបង្ហាញស្លាយទៅកាន់ពួកគេ។ ពួកគេមានពេល៣០នាទីក្នុងការពិភាក្សាសំណួរនៅក្នុងស្លាយ៖




**១.៤ វគ្គក្រុមធំ** (៣០ នាទី)

បង្រួមក្រុមចូលគ្នាវិញ និងពិភាក្សាអំពីចម្លើយរបស់ពួកគេចំពោះសំណួរទាំងនោះ នៅពេលដល់សំណួរ ហេតុអ្វីបានជាវាមានសារៈសំខាន់ចំពោះក្រុមការងារអនុវត្តច្បាប់ និងតើវាអាចផ្តល់ការគាំទ្រដល់ការងាររបស់ពួកគេបានដោយរបៀបណានោះ ចូរកត់ត្រានៅខាងមុខបន្ទប់ នៅលើផ្ទាំងក្រដាសធំមួយ និងប្រមូលផ្តុំគំនិតនានា សម្រាប់វិធីដែលយើងអាចលើកទឹកចិត្តឲ្យមានវប្បធម៌នៃការទទួលយក និងការអត់ឱនចំពោះពិពិធភាព ឬភាពចម្រុះខុសប្លែកគ្នា។

**កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល៖**

វត្ថុបំណងចម្បង គឺធ្វើឲ្យសិក្ខាកាមបានស្គាល់អំពីសារៈសំខាន់នៃការយល់ដឹង អំពីនិយមន័យខុសៗគ្នា និងពិពិធភាព ឬភាពចម្រុះគ្នា។ ហើយការយល់ដឹងបន្ថែមពីការប្រើប្រាស់ចំនេះដឹងទាំងនោះ វានឹងជាមូលដ្ឋានគ្រឹះដើម្បីនាំផ្លូវពួកគេទៅធ្វើការវិភាគលើតម្រូវការ។ ការពិចារណាទាំងនោះ អាចរួមបញ្ចូលទាំងរបៀបនៃប្រាស្រ័យទាក់ទងជាមួយជនរងគ្រោះ ឬមិត្តរួមការងារ និងអ្នកដែលពាក់ព័ន្ធនឹងសហគមន៍អ្នកស្រលាញ់ភេទដូចគ្នា ហ៎ាយនិងដឹងថាតើក្រុមអ្នកស្រលាញ់ភេទដូចគ្នាគេប្រើសព្ទនាមអ្វីនៅក្នុងការប្រាស្រ័យទាក់ទង រួមជាមួយតម្រូវការផ្សេងៗទៀតផងដែរ។ ឧទាហរណ៍ដូចជា ការស្វែងរកផលិតផលថែរក្សាអនាម័យផ្ទាល់ខ្លួន និងសម្លៀកបំពាក់។ល។ ជាដើម។ ចំណុចនេះនឹងត្រូវបានសិក្សាស្វែងយល់បន្ថែមទៀតនៅក្នុងមេរៀនទីពីរ។

# ម៉ោងសិក្សាទីពីរ

# អន្តរទំនាក់ទំនង និងយេនឌ័រ

**គោលបំណង៖** ដើម្បីណែនាំអំពីអន្តរទំនាក់ទំនង និងយេនឌ័រតាមរយៈសកម្មភាពផ្សេងៗពដែលផ្តោតលើការយល់ចិត្ត

## វត្ថុបំណងនៃការរៀនសូត្រ៖

នៅចុងបញ្ចប់នៃម៉ោងសិក្សានេះ សិក្ខាកាមនឹង...

- បានសិក្សាស្វែងយល់អំពីអន្តរទំនាក់ទំនងនៅក្នុងយេនឌ័រ

**ពេលវេលា៖** ៩០ នាទី

| សេចក្តីពណ៌នាអំពីធនធាន | សេចក្តីណែនាំអំពីការត្រៀមសម្ភារៈ |
|---|---|
| ការធ្វើបទបង្ហាញ | |
| ២.២.១៖ សកម្មភាពនៅក្នុងសង្គមបិតុនិយម | ព្រីនកាតតួអង្គ ហើយកាត់កាតនោះ |
| ២.២.២ ការត្រៀមគោលដៅ | ព្រីនឲ្យសិក្ខាកាមម្នាក់មួយ |

## ទិដ្ឋភាពទូទៅនៃម៉ោងសិក្សានេះ

| សកម្មភាព | គោលបំណង | ពេលវេលា |
|---|---|---|
| ១. អន្តរទំនាក់ទំនង | បង្ហាញពីគំរូអន្តរទំនាក់ទំនងនៃយេនឌ័រ | ៣០ នាទី |
| ២. ឆ្លុះបញ្ចាំងពីការយកចិត្តទុកដាក់ | បង្កើតការយកចិត្តទុកដាក់ចំពោះការរើសអើងតាមរយៈការឆ្លុះបញ្ចាំង | ៦០ នាទី |

## **សកម្មភាពទីមួយ៖** ទំនាក់ទំនងយេនឌ័រ

**គោលបំណង៖** បង្កើតគំរូនៃអន្តរទំនាក់ទំនងយេនឌ័រ

**ពេលវេលា៖** ៣០ នាទី

**១.១ ការដើរដោយមានអំណាច** (៣០ នាទី)

១. ឲ្យសិក្ខាកាមតម្រង់ជួរតាមចំហៀងខ្លួនកាត់ផ្នែកម្ខាងនៃបន្ទប់បណ្តុះបណ្តាល ធ្វើដូច្នេះ ស្មារបស់ពួកគេនឹងនៅជាប់គ្នា ហើយខ្នងរបស់ពួកគេបែរទៅរកជញ្ជាំង។ ដូច្នេះនៅមុខពួកគេគឺគួរតែមានផ្លូវ ឬគម្លាតមួយដែលស្រឡះ ដែលអនុញ្ញាតឲ្យសិក្ខាកាមម្នាក់បោះជំហានទៅមុខបានរហូតដល់ ១០ ជំហាន ប្រសិនបើចាំបាច់។

២. ប្រគល់កាតចរិកលក្ខណៈ(ពី ២.២.១ កញ្ចប់សកម្មភាព កាតចរិកលក្ខណមួយទៅឲ្យសិក្ខាកាមម្នាក់។ ប្រាប់ទៅសិក្ខាកាមឲ្យទុកកាតនោះ ព្រោះពួកគាត់នឹងប្រើកាតនោះម្តងទៀតនៅសកម្មភាពបន្ទាប់។

៣. ប្រាប់ពួកគេថា ពួកគេនឹងអានប្រយោគជាច្រើន ពួកគេអាចធ្វើការសន្មត់អំពីចម្លើយដោយផ្អែកលើចរិកលក្ខណៈដែលបានប្រគល់ជូនពួកគេនោះ។ ប្រសិនបើប្រយោគដែលបានអាន ត្រូវនឹងចរិកលក្ខណៈរបស់ពួកគេនោះ ពួកគេគួរតែបោះជំហានមកខាងមុខមួយជំហាន។ ប្រសិនបើប្រយោគនោះមិនត្រូវនឹងចរិកលក្ខណៈរបស់ពួកគេទេនោះ ពួកគេគួរតែឈរនៅកន្លែងដដែល។

៤. អានប្រយោគខាងក្រោមយឺតៗ នៅពេលអានប្រយោគនីមួយៗ អនុញ្ញាតឲ្យសិក្ខាកាមបោះជំហានមកខាងមុខ ប្រសិនបើចាំបាច់នឹងសាកសមជាមួយពួកគាត់៖

ប្រយោគ

- ខ្ញុំអាចអានបាន
- ខ្ញុំទៅសាលារៀន
- ខ្ញុំបានទទួលការអប់រំកម្រិតមធ្យមសិក្សា
- មានឱកាសការងារជាច្រើនសម្រាប់មនុស្សដែលមានអាយុស្របាលខ្ញុំ
- ខ្ញុំមានការងារដែលមានប្រាក់ឈ្នួលមួយ
- ប្រសិនបើខ្ញុំឃ្លាន ខ្ញុំតែងតែអាចទិញចំណីអាហារបាន
- ខ្ញុំតែងតែមានប្រាក់សន្សំគ្រប់គ្រាន់ដើម្បីរ៉ាប់រងចំណាយនៅពេលគ្រោះអាសន្ន

តូចតាច ឬសម្ភារៈប្រណិតៗ

- ខ្ញុំមានកន្លែងដែលមានសុវត្ថិភាពមួយសម្រាប់រស់នៅ
- ខ្ញុំទំនងជានឹងទទួលរងការបំពារបំពានផ្លូវភេទនៅពេលណាមួយនៅក្នុងជីវិតរបស់ខ្ញុំ
- ប្រសិនបើមាននរណាម្នាក់រំលោភបំពានលើខ្ញុំ ខ្ញុំមានអារម្មណ៍សុវត្ថិភាពនៅក្នុងការរាយការណ៍អំពីបទឧក្រិដ្ឋនោះ
- ខ្ញុំមានមិត្តភ័ក្តិ និងគ្រួសារដែលគាំទ្រខ្ញុំ
- ខ្ញុំមានឱកាសចូលរួមនៅក្នុងសង្គម និងបង្កើតមិត្តភ័ក្តិ
- ខ្ញុំមានអារម្មណ៍ថាមានលំនឹងផ្លូវចិត្ត
- ខ្ញុំមិនធ្លាប់មានជំងឺផ្លូវចិត្តពីមុនមកទេ
- សម្រាប់ខ្ញុំ ការលែងលះ គឺអាចទទួលយកបាននៅក្នុងសង្គម
- សម្រាប់ខ្ញុំ ការមានដៃគូរួមភេទលើសពីម្នាក់នៅក្នុងជីវិតរបស់ខ្ញុំ គឺអាចទទួលយកបានតាមផ្នែកវប្បធម៌
- ជាក់ស្តែង ខ្ញុំអាចមើលថែតម្រូវចាំបាច់ប្រចាំថ្ងៃរបស់ខ្ញុំបានដោយឯករាជ្យ
- ខ្ញុំអាចប្រាស្រ័យទាក់ទងជាមួយមនុស្សទាំងឡាយដែលរស់នៅក្នុងតំបន់របស់ខ្ញុំ
- ជាក់ស្តែង ខ្ញុំអាចចាកចេញពីផ្ទះរបស់ខ្ញុំ និងធ្វើដំណើរជុំវិញភូមិ/ទីប្រជុំជនរបស់ខ្ញុំបានដោយឯករាជ្យ
- ជាក់ស្តែង ខ្ញុំអាចចូលទៅកាន់អគារគ្រប់ប្រភេទទាំងអស់ រួមបញ្ចូលទាំងអគារដែលមានច្រើនជាន់ផងដែរ។

៥. ស្នើសុំឲ្យសិក្ខាកាមឈរនៅកន្លែងដែលពួកគេបានឈប់នោះ ហើយឲ្យពួកគេគ្រប់រូបឆ្លាស់វេនគ្នាអានកាតចរិកលក្ខណៈរបស់ពួកគេ។ វានឹងរឹតតែគួរឲ្យចាប់អារម្មណ៍នៅពេលឃើញ អ្នកដែលមានកាតចរិកលក្ខណៈដូចគ្នាកំពុងតែឈរនៅកន្លែងដូចគ្នា ឬខុសគ្នា។ សួរពួកគេពីសំណួរដេញដោលមួយចំនួនដូចខាងក្រោម៖

- តើសំណួរប្រភេទណាខ្លះដែលបានជួយដល់អ្នកឲ្យផ្លាស់ទីមកខាងមុខ? និងតើសំណួរប្រភេទណាខ្លះដែលស្ទាក់ផ្លូវអ្នកមិនឲ្យផ្លាស់ទីបាន? (នៅពេលដែលសិក្ខាកាមកំពុងតែចែករំលែកគំនិតរបស់ពួកគេអំពីកត្តាដែលបញ្ឈប់នរណាម្នាក់មិនឲ្យផ្លាស់ទីមកខាងមុខបាននោះ ចូរសរសេរចម្លើយរបស់ពួកគេនៅខាងលើការបញ្ជរក្រដាសធំមួយផ្ទាំង។)
- តើអ្នកមានអារម្មណ៍យ៉ាងដូចម្តេចដែរ នៅពេលដែលអ្នកមិនអាចផ្លាស់ទីទៅខាងមុខបាន? (ជាថ្មីម្តងទៀត កត់ត្រាគំនិតនានានៅលើក្រដាសធំមួយផ្ទាំងទៀត)

៦. ពន្យល់ថា យើងនឹងត្រឡប់មកនិយាយអំពីលំហាត់នេះម្តងទៀតនៅក្នុងម៉ោងសិក្សាបន្ទាប់។ ប្រាប់ពួកគេឲ្យរក្សាទុកកាតចរិកលក្ខណៈនៅជាមួយពួកគេ ពីព្រោះពួកគេនឹងត្រូវការវានៅក្នុងសកម្មភាពបន្ទាប់។

## **សកម្មភាពទីពីរ៖** ការឆ្លុះបញ្ចាំងអំពីការយល់ចិត្ត

**គោលបំណង៖** បង្កើតការយល់ចិត្តចំពោះការរើសអើងតាមរយៈការឆ្លុះបញ្ចាំង

**ពេលវេលា៖** ៦០ នាទី

**សេចក្តីណែនាំសម្រាប់អ្នកសម្របសម្រួល**

**២.១ ការកំណត់គោលដៅ** (២០ នាទី)

១. ចែកក្រដាសឆ្លុះបញ្ចាំង ២.២.២ ការកំណត់គោលដៅ និងពន្យល់ទៅកាន់សិក្ខាកាមថា ពួកគាត់នឹងមិនបង្ហាញអ្វីដែលពួកគាត់បានសរសេរទៅកាន់អ្នកដ៏ទៃ បើគាត់មិនចង់

២. ផ្តល់ជូនសិក្ខាកាមនូវរយៈពេល ២០ នាទីដើម្បីធ្វើការឆ្លុះបញ្ចាំងអំពីគោលដៅរបស់ពួកគេ និងគោលដៅរបស់លំហាត់។

**២.២ ការបង្កើតរូបភាពស្រមើស្រមៃ ដោយមានការណែនាំ**... (**១០ នាទី**)

ពន្យល់ទៅកាន់សិក្ខាកាមថា កិច្ចការបន្ទាប់គឺ ពួកគេនឹងប្រើកាតចរិកលក្ខណៈម្តងទៀត ដែលបានពីសកម្មលើកមុន។

សម្រាប់លំហាត់នេះអ្នកសម្របសម្រួលនឹងត្រូវលើកទឹកចិត្តសិក្ខាកាមឲ្យព្យាយាមយកចិត្តទុកដាក់

និងយល់ពីអារម្មណ៍នៃចរិកលក្ខណៈដែលពួកគេមានៅក្នុងដៃ។ គោលដៅនៃសកម្មភាពនេះគឺដើម្បីឲ្យសិក្ខាកាមអាចសិក្សាស្វែងយល់ពីអារម្មណ៍ខុសៗគ្នានៅពេលត្រូវបានពង្រឹងអំណាច ឬពេលគ្មានអំណាចតើពួកគាត់នឹងមានអារម្មណ៍បែបណា ក៏ប៉ុន្តែអ្នកសម្របសម្រួលមិនត្រូវពន្យល់ថាគោលដៅនៃសកម្មភាពនេះចង់បានអ្វីទេ។

អ្នកសម្របសម្រួលអាចធ្វើការពន្យល់សិក្ខាកាមតាមរយៈការបង្កើតរូបភាពស្រមើស្រមៃ ដែលមានការណែនាំមួយ ដូចខាងក្រោម៖

១. ស្នើសុំឲ្យអ្នកចូលរួសិក្ខាកាមផ្លាស់ទីកៅអីរបស់ពួកគេទៅកាន់ទីធ្លាមួយនៅក្នុងបន្ទប់ដែលមានគម្លាតនៅជុំវិញខ្លួន ហើយពួកគេអាចបែរមុខទៅរកផ្នែកខាងមុខនៃបន្ទប់។

២. ប្រាប់ពួកគេឲ្យបន្ធូរអារម្មណ៍ និងបិទភ្នែករបស់ពួកគេ ដោយដាក់ដៃនៅលើភ្លៅរបស់ពួកគេ។

៣. ប្រាប់ពួកគេដោយពាក្យសម្តីទន់ភ្លន់ ឲ្យពួកគេដកដង្ហើមបន្ធូរអារម្មណ៍ ដែលនឹងបំពេញខ្យល់នៅក្នុងពោះរបស់ពួកគេ បន្ទាប់មកដកដង្ហើមចេញវិញ។ ឬស្នើសុំឲ្យពួកគេដកដង្ហើមចូល ហើយរាប់ ១ ២ ៣ បន្ទាប់មកដកដង្ហើមចេញវិញ ហើយរាប់ ១ ២ ៣ វិញ ធ្វើបែបនេះពីរបីដង រហូតទាល់តែអ្នកអាចមើលឃើញថាអ្នកនៅក្នុងបន្ទប់កំពុងតែបន្ធូរអារម្មណ៍។

៤. នៅពេលនេះ ប្រាប់ពួកគេថា អ្នកនឹងស្នើសុំឲ្យពួកគេធ្វើការស្រមើស្រមៃអំពីចរិកលក្ខណៈនៅលើកាតរបស់ពួកគេ ហើយព្យាយាមស្រមៃចរិកលក្ខណៈនេះឲ្យបានរស់រវើកបំផុតតាមដែលអាចធ្វើបាន។ ដើម្បីជួយដល់ពួកគេនៅក្នុងការធ្វើលំហាត់នេះ អ្នកនឹងផ្តល់ជូនពួកគេនូវជំនួយមួយចំនួនដើម្បីជម្រុញឲ្យពួកគេធ្វើការស្រមើស្រមៃអំពីចម្លើយ។ អានសំណួរខាងក្រោមយឺតៗ៖

- តើតួអង្គរបស់អ្នកមានលក្ខណៈយ៉ាងដូចម្តេចខ្លះ? (ខ្ពស់ ទាប ធំ តូច មានសក់ពណ៌អ្វី និងតើពួកគេស្លៀកសម្លៀកបំពាក់អ្វីខ្លះ?។ល។)
- តើតួអង្គរបស់អ្នកមានអាយុប៉ុន្មានដែរ?
- តើពួកគេរស់នៅកន្លែងណា?
- តើពួកគេរស់នៅជាមួយនរណា?
- ប្រសិនបើពួកគេរស់នៅជាមួយអ្នកដទៃទៀត តើពួកគេមានលក្ខណៈយ៉ាងដូចម្តេច?
- តើមនុស្សម្នាក់នេះមានកុមារភាពដ៏រីករាយមួយដែរឬទេ? (ហេតុអ្វីមាន? ហេតុអ្វីគ្មាន?)
- តើការរស់នៅប្រចាំថ្ងៃសម្រាប់មនុស្សម្នាក់នេះ ជាមធ្យម មានលក្ខណៈយ៉ាងដូចម្តេចខ្លះ?

+ តើពួកគេធ្វើការនៅក្រៅ ឬនៅផ្ទះ?
+ តើពួកគេធ្វើអ្វីខ្លះ?
+ តើពួកគេចូលចិត្តអ្វីដែលពួកគេធ្វើដែរឬទេ?
+ តើតម្រូវការចាំបាច់ប្រចាំរបស់ពួកគេត្រូវបានបំពេញតាមដែរឬទេ? (សុវត្ថិភាព ចំណីអាហារ។ល។?)

- តើពួកគេមានអារម្មណ៍យ៉ាងដូចម្តេចខ្លះចំពោះជីវិតរបស់ពួកគេ?
- តើពួកគេមានអារម្មណ៍យ៉ាងដូចម្តេចខ្លះចំពោះអនាគត និងហេតុអ្វី?

៥. ពីរបីនាទីបន្ទាប់ពីធ្វើការឆ្លុះបញ្ចាំងរួចរាល់ហើយនោះ ប្រើដោយពាក្យសម្តីថ្នមៗយឺតៗ ស្នើសុំសិក្ខាកាម ឲ្យបើកភ្នែករបស់ពួកគេវិញ រ។

**២.៣ ប្រសិនបើខ្ញុំជាអ្នក**... (១៥ នាទី)

**កំណត់សម្គាល់របស់អ្នកសម្របសម្រួល**

កិច្ចការនេះនឹងជួយដល់សិក្ខាកាមឲ្យទទួលបានបទពិសោធន៍ពីអារម្មណ៍ខុសៗគ្នា និងការឆ្លុះបញ្ចាំងពីជីវិតរបស់អ្នកដ៏ទៃ។ សិក្ខាកាមខ្លះអាចនឹងមានអារម្មណ៍ដូចគ្មានភាពអង់អាចតាមរយៈតួអង្គរបស់ខ្លួន ឬក៏នៅពេល ដែលគិតទៅដល់សមត្ថភាពរបស់ខ្លួនក្នុងការសម្រេចគោលដៅដែលខ្លួនឯងបានរៀបចំ។ ខ្លះទៀតអាចនឹងមានអារម្មណ៍ថាភាពអង់អាចរបស់ខ្លួនឯងមានច្រើនជាងមុន នៅពេលដែលដាក់អារម្មណ៍ខ្លួនឯងជាមួយតួអង្គ ដែលខ្លួនកំពុងស្រមៃដល់។

អ្វីដែលចង់បានពីការធ្វើលំហាត់មួយនេះ គឺដើម្បីស្វែងយល់បន្ថែមពីអ្វីទៅជា ភាពខុសប្លែកគ្នានៅពេលដែលមាន និងគ្មានអំណាច ឬភាពអង់អាច ហើយកត្តាស្មុគស្មាញផ្សេងៗទៀតផងដែរ ដែលអាចជះឥទ្ធិពល ឬធ្វើឲ្យមានការប្រែប្រួលទៅតាមមនុស្សម្នាក់ៗ។ ករណីនេះនឹងធ្វើការបកស្រាយបន្ថែមនៅម៉ោងសិក្សាបន្ទាប់ ដែលនឹងធ្វើការបកស្រាយលំការរើសអើង៖

១. ស្នើសុំឲ្យសិក្ខាកាមយកក្រដាសកិច្ចការឆ្លុះបញ្ចាំង ដែលពួកគេទើបតែបានធ្វើ មកពិនិត្យឡើងវិញ។ ប្រាប់ពួកគេឲ្យអានឡើងវិញ ហើយលើកសាកស្រមើស្រមៃថាពួកគាត់គឺជាតួអង្គរបស់ខ្លួន ដែលបានស្រមៃឡើងម្តង។

២. ពួកគេគួរតែស្រមើស្រមៃថា ទោះបីជាពេលនេះពួកគេគឺជាតួអង្គទាំងនោះក៏ដោយ ក៏ពួកគេនៅតែមានគោលដៅដូចគ្នានឹងគោលដៅដែលពួកគេបានសរសេរមុននេះដែរ។

៣. ក្នុងនាមជាតួអង្គរបស់ខ្លួន ហើយអាចគោលដៅរបស់តួអង្គរបស់ខ្លួនឡើងវិញ និងចាប់ផ្តើមឆ្លើយសំណួរ នៅលើស្លាយខាងក្រោម៖

**២.៤ វគ្គក្រុមធំ** (១៥ នាទី)

១. បង្អែមក្រុមតូចៗចូលគ្នាវិញដើម្បីធ្វើការផ្តល់មតិត្រឡប់។ ប្រសិនបើសិក្ខាកាមទាំងឡាយមានអារម្មណ៍សុខស្រួលនៅក្នុងការចែករំលែកគោលដៅរបស់ពួកគេ ចូរលើកទឹកចិត្តពួកគេឲ្យធ្វើបែបនោះ និងស្នើសុំឲ្យពួកគេបរិយាយអំពីការឆ្លុះបញ្ចាំងរបស់ពួកគេ ដោយប្រើសំណួរដេញដោលនានាដូចខាងក្រោម៖

ក. តើកត្តា និងបញ្ហាប្រឈមអ្វីខ្លះដែលអ្នកបានកំណត់រកឃើញ សម្រាប់គោលដៅរបស់អ្នក និងតើកត្តា និងបញ្ហាប្រឈមទាំងនោះធ្វើឲ្យអ្នកមានអារម្មណ៍យ៉ាងដូចម្តេចខ្លះ?

ខ. តើកត្តា និងបញ្ហាប្រឈមទាំងនេះមានភាពខុសគ្នាដូចម្តេចខ្លះ នៅពេលដែលអ្នកសម្លឹងមើលគោលដៅរបស់អ្នកក្នុងនាមជាតួអង្គទាំងនោះ? និងតើវាធ្វើឲ្យអ្នកមានអារម្មណ៍យ៉ាងដូចម្តេចខ្លះ?

គ. តើអ្វីដែលបណ្តាលឲ្យមានភាពខុសគ្នាទាំងនោះ?

២. ពន្យល់ថា យើងនឹងត្រឡប់មកអនុវត្តលំហាត់នេះម្តងទៀតនៅក្នុងម៉ោងសិក្សាបន្ទាប់។

## ឆ្លុះបញ្ចាំង៖ ប្រសិនបើខ្ញុំជាអ្នក

តាំងខ្លួនអ្នកជាតួអង្គ ហើយឆ្លើយនឹងសំណួរខាងក្រោម៖

- នៅពេលនេះ តើអ្នកមានទំនុកចិត្តដល់កម្រិតណា ថាអ្នកអាចសម្រេចគោលដៅនីមួយៗបាន?
- តើកត្តា (ចំណេះដឹង ជំនាញ បទពិសោធន៍ ទំនាក់ទំនង។ល។) អ្វីខ្លះដែលអ្នកមាន ដើម្បីជួយដល់អ្នកនៅក្នុងការសម្រេចគោលដៅនីមួយៗ?
  - តើអ្នកមានអារម្មណ៍យ៉ាងដូចម្តេចខ្លះ នៅពេលដែលអ្នកគិតដល់កត្តាទាំងនោះ?
- តើមានបញ្ហាប្រឈមអ្វីខ្លះនៅតាមផ្លូវរបស់អ្នក?
  - តើអ្នកមានអារម្មណ៍យ៉ាងដូចម្តេចខ្លះ នៅពេលដែលអ្នកគិតដល់បញ្ហាប្រឈមទាំងនោះ?

UNODC United Nations Office on Drugs and Crime

UN WOMEN

# ម៉ោងសិក្សាទីបី

# ការរើសអើងយេនឌ័រ

**គោលបំណង៖** ដើម្បីសិក្សាស្វែងយល់អំពីការរើសអើងយេនឌ័រ និងថាមវន្តនៃអំណាចនៅក្នុងសង្គមបិតុនិយម និងលក្ខណៈស្មុគស្មាញនៃទំនាក់ទំនងយេនឌ័រ

## វត្ថុបំណងនៃការរៀនសូត្រ៖

នៅចុងបញ្ចប់នៃម៉ោងសិក្សានេះ សិក្ខាកាមនឹង...

- អាចកំណត់និយមន័យអំពីទំនាក់ទំនងយេនឌ័រ
- បានវិភាគអំពីឧទាហរណ៍នានានៃការរើសអើង

**ពេលវេលា៖** ៩០ នាទី

| សេចក្តីពណ៌នាអំពីធនធាន | សេចក្តីណែនាំអំពីការត្រៀមសម្ភារៈ |
|---|---|
| ការធ្វើបទបង្ហាញ | |
| ផ្ទាំងក្រដាសធំមួយចំនួន | |

## ទិដ្ឋភាពទូទៅនៃម៉ោងសិក្សានេះ

| សកម្មភាព | គោលបំណង | ពេលវេលា |
|---|---|---|
| ១. ការរើសអើង | ណែនាំឲ្យស្គាល់ពីទស្សនៈបែបទ្រឹស្តីនៃអន្តរទំនាក់ទំនងយេនឌ័រ និងការរើសអើង | ៣០ នាទី |
| ២. រឿងទាក់ទាងនឹងការរើសអើង | ស្វែងយល់បន្ថែមពីចំនុចខុសៗគ្នានៃប្រភេទនៃការរើសអើងទាំងក្នុងការអនុវត្ត និងបទពិសោធន៍ផ្ទាល់ខ្លួន | ៦០ នាទី |

## សកម្មភាពទីមួយ៖ ការរើសអើង

**គោលបំណង៖** ដើម្បីណែនាំឲ្យស្គាល់ពីទស្សន:បែបទ្រឹស្តីនៃអន្តរទំនាក់ទំនងយេនឌ័រ និងការរើសអើង

**ពេលវេលា៖** ៣០ នាទី

**១.២ ការធ្វើបទបង្ហាញ** (៣០ នាទី)

**កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល៖**

ប្រើប្រាស់ស្លាយនានាដូចខាងក្រោមដើម្បីពិចារណាអំពីម៉ោងសិក្សាមុនៗ និង ណែនាំអំពីទស្សន:ផ្សេងៗ ដែលបង្កើតជាមូលដ្ឋានដល់សកម្មភាពនានា។

**កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល**

## ការរើសអើង

មនុស្សម្នាក់ត្រូវបានគេ គោរពដោយមិនស្មើភាព ដោយសារតែពួកគេជាមនុស្សបែបណាមួយ ឬចរិកលក្ខណៈណាមួយ ដោយសារកត្តា កម្រិតអាយុ ជាតិសាសន៍ ការអប់រំ អត្តសញ្ញាណកម្មផ្លូវភេទ ចំនួនទឹកប្រាក់ដែលគេរកបាន។ល។

## ការរើសអើងប្រឆាំងនឹងកុមារី និងស្ត្រី



«ការរើសអើងប្រឆាំងនឹងស្ត្រីភេទ មានន័យថា ការបែងចែក ឬការកាត់ចេញ ឬការរឹតត្បិតណាមួយ ផ្អែកលើភេទ ដែលមានអានុភាព ឬមានបំណងធ្វើឲ្យខូចខាត ឬធ្វើអោយៈភាពនូវការទទួលស្គាល់ ការអាស្រ័យផល ឬការអនុវត្តរបស់ស្ត្រី ឬដោយមិនគិតដល់ស្ថានភាពអាពាហ៍ពិពាហ៍ របស់ពួកគេទាំងអស់នោះ ហើយកត្តាទាំងនោះដោយផ្អែកលើមូលដ្ឋានស្មើភាពគ្នារវាងបុរស និងស្ត្រី មូលដ្ឋានសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាននៅក្នុងវិស័យនយោបាយ[8] សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ ពលរដ្ឋ ឬនៅក្នុងវិស័យណាមួយផ្សេងទៀត»។ (CEDAW)

https://www.un.org/womenwatch/daw/cedaw/cedaw.htm

UNODC United Nations Office on Drugs and Crime

UN WOMEN

## ការរើសអើងដោយផ្ទាល់

ការរើសអើង **ដោយផ្ទាល់** ប្រឆាំងនឹងកុមារី និងស្ត្រីភេទ ងាយនឹងមើលដឹងដោយសារវាស្តែងនឹងភ្នែក។

ឧទាហរណ៍៖ នៅប្រទេសមួយចំនួន មនុស្សស្រីមិនអាចកាន់កាប់ទ្រព្យសម្បត្តិបានទេ

ឬមនុស្សស្រីត្រូវហាមដោយច្បាប់សម្រាប់ការងារមួយចំនួន

ឬដោយសារទំនៀមទំលាប់សង្គម ក្មេងស្រីមិនអនុញ្ញាតឲ្យរៀនបានខ្ពង់ខ្ពស់នោះទេ។(អង្គការ UN Women)

[8] https://www.un.org/womenwatch/daw/cedaw/cedaw.htm




គោលបំណងនៅកន្លែង គឺដើម្បីគូសបញ្ជាក់ថា ទោះបីជាយើងស្ថិតនៅក្នុងក្រុមជាច្រើនខុសៗគ្នាក៏ដោយ ក៏យើងនៅតែអាចទទួលរងការរើសអើងពីជ្រុងជាច្រើនរួមបញ្ចូលគ្នាបានដែរ។ ដូច្នេះ ស្ត្រីពីរនាក់ដែលមកពីប្រទេសតែមួយ មិនប្រាកដថានឹងត្រូវប្រឈមមុខនឹងកត្តាការរើសអើងដូចគ្នានោះទេ។

## សកម្មភាពទីពីរ៖ សាច់រឿងនៃការរើសអើង

**គោលបំណង៖** ដើម្បីសិក្សាស្វែងយល់អំពីប្រភេទខុសៗគ្នានៃការរើសអើងនៅក្នុងទម្លាប់នៃការអនុវត្តតាម រយៈបទពិសោធន៍ផ្ទាល់ខ្លួន។

**ពេលវេលា៖** ៦០ នាទី

**សេចក្តីណែនាំសម្រាប់អ្នកសម្របសម្រួល៖**

**២.១ ការចែករំលែកបទពិសោធន៍** (២០ នាទី)

១. ស្នើសុំឲ្យសិក្ខាកាមធ្វើការជាគូ សម្រាប់សកម្មភាពនេះ។

២. ស្នើសុំឲ្យពួកគេពិភាក្សាជាមួយដៃគូរបស់ពួកគេ អំពីឧទាហរណ៍ណាមួយដែលពួកគេមាន ដែលស្តីពីការរើសអើងយេនឌ័រដែលពួកគេបានឆ្លងកាត់ដោយផ្ទាល់ ឬបានមើលឃើញដោយផ្ទាល់។

៣. ទុកពេលឲ្យសិក្ខាកាមចំនួន ១៥ នាទី នៅក្នុងការពិភាក្សាជាគូ បន្ទាប់មកបង្រួមក្រុមចូលគ្នាវិញ ហើយប្រើពេល៥នាទី ស្នើសុំឲ្យពួកគេលើកឡើងនូវឧទាហរណ៍ពីរបី(កុំច្រើនពេកពីព្រោះពួកគេនឹងមានឱកាសធ្វើការចែករំលែកក្រោយពេលបញ្ចប់ផ្នែកបន្ទាប់ទៀតនៃសកម្មភាពនេះ)។

រូបភាព: UNODC/ UN Women/ Ploy Phutpheng

សកម្មភាពនេះ នឹងផ្តលើឱកាសដល់សិក្ខាកាមឆ្លុះបញ្ចាំងលើការរើសអើងក្នុងបរិបទក្នុងស្រុក។ គំនិតទាំងនេះ នឹងបន្តនៅក្នុងថ្ងៃទី ម៉ោងទី៣ នៃវគ្គបណ្តុះបណ្តាល នៅពេលនោះសិក្ខាកាមនិងត្រូវបានសួរក្នុងការអនុវត្តវិធីសាស្ត្រផ្អែកលើគោលការណ៍សិទ្ធិមនុស្ស។

**២.២ វិភាគអំពីបទពិសោធន៍នៅក្នុងបរិបទនយោបាយ និងសង្គម** (២០ នាទី)

នៅពេលនេះ ស្នើសុំឲ្យសិក្ខាកាមគិតដល់ឧទាហរណ៍ ដែលពួកគេបានពិភាក្សាមុននេះ និងសម្គាលមើលថាអ្វីដែលបានបណ្តាលឬអនុញ្ញាតឲ្យការរើសអើងប្រភេទនោះកើតឡើង។អ្នកសម្របសម្រួលគួរតែធ្វើជាគំរូនៃសកម្មភាពនេះ តាមរយៈការផ្តល់ឧទាហរណ៍មួយ។ ពួកគេក៏អាចប្រើប្រាស់ឧទាហរណ៍មួយនៃសាច់រឿងនៅក្នុងសកម្មភាពមុន និងពន្យល់អំពីរបៀប ដែលការរួមបញ្ចូលគ្នានៃកង្វះខាតរបស់ច្បាប់រដ្ឋាភិបាល ដែលមិនបានផ្តល់ការការពារ និងគោលនយោបាយគ្រប់គ្រង បានអនុញ្ញាតឲ្យការរើសអើងនោះកើតឡើង និងទាញសេចក្តីសន្និដ្ឋានអំពីមូលហេតុដែលនៅពីក្រោយការដែលនរណាម្នាក់មានអាកប្បកិរិយា ឬធ្វើអំពើជាក់លាក់ណាមួយ។

**២.៣ ការប្រជុំក្រុម** (២០ នាទី)

ប្រមូលយកមតិត្រឡប់ពីក្រុម និងកត់ត្រាចំណុចសំខាន់ៗនៅលើផ្ទាំងក្រដាសធំ។ ពន្យល់ថា ចំណុចទាំងអស់នេះនឹងត្រូវបានយោងប្រើ សារជាថ្មីម្តងទៀតនៅក្នុងម៉ោងសិក្សាថ្ងៃទី ៣។

# ម៉ោងសិក្សាទីបួន

# បរិបទនៃការរើសអើង

**គោលបំណង៖** ដើម្បីសិក្សាស្វែងយល់អំពីការរើសអើងយេនឌ័រ និងការប្រែប្រួលនៃអំណាចនៅក្នុងបរិបទនៃប្រទេសមួយ

## វត្ថុបំណងនៃការរៀនសូត្រ៖

នៅចុងបញ្ចប់នៃម៉ោងសិក្សានេះ សិក្ខាកាមនឹង...

- បានពិភាក្សាអំពីឧទាហរណ៍នៃការរើសអើងរបស់ខ្លួនផ្ទាល់ នៅក្នុងបរិបទនៃប្រទេសរបស់ពួកគេ
- បានដឹង "ចំណុចដាក់សម្ពាធ" មួយចំនួនដែលអាចធ្វើឲ្យមានការរើសអើងយេនឌ័រកើតឡើងនៅក្នុងវិជ្ជាជីវៈនៃការអនុវត្តច្បាប់

**ពេលវេលា៖** ៩០ នាទី

| សេចក្តីពណ៌នាអំពីធនធាន | សេចក្តីណែនាំអំពីការត្រៀមសម្ភារៈ |
|---|---|
| ការធ្វើបទបង្ហាញ | |

## ទិដ្ឋភាពទូទៅនៃម៉ោងសិក្សានេះ

| សកម្មភាព | គោលបំណង | ពេលវេលា |
|---|---|---|
| រើសអើង | សិក្សាស្វែងយល់អំពីការរើសអើងយេនឌ័រ និងការប្រែប្រួលនៃអំណាចនៅក្នុងបរិបទនៃប្រទេសមួយ | ៩០ នាទី |

## **សកម្មភាពទីមួយ៖** ការរើសអើងនៅក្នុងបរិបទ

**គោលបំណង៖ ដើម្បីសិក្សាស្វែងយល់អំពីការរើសអើងយេនឌ័រ និងការប្រែប្រួលនៃអំណាចនៅក្នុងបរិបទនៃប្រទេសមួយ**

**១.១ ស្ថិតិ** (២០ នាទី)

មុនពេលចាប់ផ្តើមវគ្គបណ្តុះបណ្តាល អ្នកសម្របសម្រួលគួរតែរើសយកទិន្នន័យស្ថិតិមួយដែលពាក់ព័ន្ធនឹងការរើសអើងយេនឌ័រនៅក្នុងបរិបទប្រទេសជាមុនសិន។ ស្ថិតិទាំងនេះគួរតែត្រូវបានធ្វើបទបង្ហាញនៅលើស្លាយ តែបង្ហាញតែចំនួនលេខជាមុនសិន ហើយអ្នកសម្របសម្រួលគួរតែអានស្ថិតិនោះឡើង (ដូចជា ចំនួនករណីហិង្សាក្នុងគ្រួសារ ក្នុងមួយឆ្នាំៗជាដើម)។ ពេលអានហើយសាកឲ្យសិក្ខាកាមធ្វើការទស្សន៍ទាយថាតើស្ថិតិមួយណាដែលត្រូវនឹងអំណះអំណាននោះ។

**១.២ សម្តាល់ «ចំណុចដាក់សម្ពាធ» (៤០ នាទី)**

១. បែងចែកសិក្ខាកាមជាក្រុមតូចៗ និងប្រគល់ជូនពួកគេនូវផ្ទាំងក្រដាសធំ និងប៊ិចៗ

២. ចាប់ផ្តើមសកម្មភាពតាមរយៈការពន្យល់ថា តាមប្រវត្តិសាស្ត្រ មន្ត្រីអនុវត្តច្បាប់ភាគច្រើនដោយបុរស ហើយទោះបីជាមានកើនឡើងនូវចំនួនស្ត្រីក្នុងអង្គភាពអនុវត្តចច្បាប់ក៏ដោយ ក៏នៅមានផ្លូវដ៏វែងឆ្ងាយទៀតដែលត្រូវកើតឡើង (ដែលរួមបញ្ចូលទាំងកម្មវិធី ដែលកម្មសិក្សានៃការបណ្តុះបណ្តាលនេះជាផ្នែកមួយនៃរឿងនោះផងដែរ)។ ដូចដែលយើងបានលើកឡើងនៅក្នុងម៉ោងសិក្សាមុននេះរួចហើយ គឺមានទាំងឧទាហរណ៍នៃការរើសអើងដោយផ្ទាល់ និងដោយប្រយោល។ កិច្ចការដែលត្រូវអនុវត្តជាក្រុម គឺដើម្បីកត់សម្គាល់ «ចំណុចដាក់សម្ពាធ» អាចកើតឡើងបាននៅក្នុងប្រព័ន្ធដោយចំហរចំពោះការរើសអើងយេនឌ័រចំពោះស្ត្រី ដែលបង្កើតជាឧបសគ្គ/ការបង្អាក់ស្ត្រីកាន់តែច្រើន ក្នុងការមិនឲ្យចូលរួមនៅក្នុងវិស័យវិជ្ជាជីវៈ។ អ្នកសម្របសម្រួលអាចផ្តល់ឧទាហរណ៍មួយចំនួនដូចជា៖

- ការរឹតត្បិតផ្នែកកម្ពស់ចំពោះតួនាទីមួយចំនួន
- មន្ត្រីដែលស្ត្រីត្រូវបានតម្រូវឲ្យស្លៀកឯកសណ្ឋានជាសំពត់ ដែលរឹតត្បិតដល់ការផ្លាស់ទីនៃរាងកាយ
- កង្វះគោលនយោបាយស្តីពីមាតុភាព
- វិសាលភាពនៃប្រាក់ឈ្នួលមិនស្មើភាព
- មានភាពជាបុរសដែលជះឥទ្ធិពលអវិជ្ជមាន នៅក្នុងក្រុមការងារអនុវត្តច្បាប់ ដែលបង្កផលប៉ះពាល់ដល់ការជ្រើសរើសបុគ្គលិកដោយស្មើភាព ឬសក្តានុពលរបស់ក្រុមការងារ។

Photo: UNODC/ UN Women

## ១.៣ ការប្រជុំក្រុម

១. បង្រួមក្រុមចូលគ្នាវិញ និងចែករំលែកឧទាហរណ៍នានា។

២. ពិភាក្សាអំពីគំនិតមួយចំនួន ក្នុងករណីដែលការដឹងអំពីចំណុចដាក់សម្ពាធទាំងនេះ គឺអាចជួយយើងដឹងយុទ្ធសាស្ត្រដើម្បីបន្ធូរបន្ថយការរើសអើង។ ទោះបីជាយ៉ាងណាក៏ដោយ សកម្មភាពជាច្រើនទៀតនឹងត្រូវបានអនុវត្តចំពោះចំណុចនេះនៅក្នុងម៉ោងសិក្សា ៣.៣។

៣. បិទការងារជាក្រុម នៅលើជញ្ជាំងបន្ទប់បណ្តុះបណ្តាល ដើម្បីទុកប្រើប្រាស់នៅថ្ងៃបន្ទាប់ទៀត។

## កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល

ឧទាហរណ៍នានា នឹងអាស្រ័យលើគោលនយោបាយ ទម្លាប់អនុវត្ត និងវប្បធម៌នៅក្នុងបរិបទប្រទេស ដូច្នេះគេណែនាំថាអ្នកសម្របសម្រួលគួរតែត្រៀមឧទាហរណ៍ក្នុងបរិបទជាក់លាក់មួយចំនួនទុកជាមុន។

# ថ្ងៃទី ៣

## ម៉ោងសិក្សាទីមួយ

## ការរំលោភបំពាន និងអំពើហិង្សាយេនឌ័រ

**គោលបំណង៖** ដើម្បីធ្វើឲ្យសិក្ខាកាមអាចយល់ដឹងអំពីការរំលោភបំពាន និងអំពើហិង្សាយេនឌ័រ

**វត្ថុបំណងនៃការរៀនសូត្រ៖**

នៅចុងបញ្ចប់នៃម៉ោងសិក្សានេះ សិក្ខាកាមនឹងអាច...

- កំណត់និយមន័យការរំលោភបំពាន និងអំពើហិង្សាយេនឌ័រ ឬ(GBV/CBA)
- ផ្តល់ឧទាហរណ៍យ៉ាងតិចបី អំពី GBV/CBA

**ពេលវេលា៖** ៩០ នាទី

| **សេចក្តីពណ៌នាអំពីធនធាន** | **សេចក្តីណែនាំអំពីការត្រៀមសម្ភារៈ** |
|---|---|
| ការធ្វើបទបង្ហាញ | |
| ៣.១.១ កាតប្រភេទការរំលោភបំពាន និងអំពើហិង្សាយេនឌ័រ | រៀបចំ២កញ្ចប់ ហើយព្រីនចេញ រួចកាត់ឲ្យហើយ |

*ពន្យល់ថាមេរៀនទី ពីរ៖ ការអនុវត្តការស៊ើបអង្កេតយេនឌ័រដោយមានព័ត៌មានគ្រប់គ្រាន់ ជាមួយជនរងគ្រោះដោយសារអំពើជួញដូរមនុស្ស និងជនដែលងាយរងគ្រោះដទៃទៀត៖ ហ្វឹកហាត់សម្រាប់មន្ត្រីជួរមុខ និងក្រុមការងារអនុវត្តច្បាប់ ដោយផ្តោតលើរបៀបដាក់ឲ្យដំណើរការនូវវិធីសាស្ត្រក្នុងការស៊ើបអង្កេតដែលឆ្លើយតបនឹងយេនឌ័រ។ មេរៀននេះផ្តោតលើការសិក្សាស្វែងយល់ថាតើ GBV/ GBA មានអត្ថន័យយ៉ាងដូចម្តេច និងមូលហេតុឫសគល់របស់វា។

## ទិដ្ឋភាពទូទៅនៃម៉ោងសិក្សានេះ

| សកម្មភាព | គោលបំណង | ពេលវេលា |
|---|---|---|
| 1. អំពើហិង្សាប្រឆាំងនឹង | សិក្សាស្វែងយល់អំពីប្រភេទខុសៗគ្នានៃអំពើហិង្សាយេនឌ័រ | ៥០ នាទី |
| 2. មន្ត្រីអនុវត្តច្បាប់ – ដោះស្រាយបញ្ហាមួយចំនួន | បង្កើនការយល់ដឹងពី ទំហំនៃបញ្ហា និងបង្កើតការពិភាក្សាអំពីតួនាទី នៃក្រុមមន្ត្រីអនុវត្តច្បាប់ | ៤០ នាទី |

## សកម្មភាពទីមួយ៖ អំពើហិង្សាប្រឆាំងនឹង...

**គោលបំណង៖** ដើម្បីសិក្សាស្វែងយល់អំពីប្រភេទខុសៗគ្នានៃអំពើហិង្សាយេនឌ័រ

**ពេលវេលា៖** ៥០ នាទី

**សេចក្តីណែនាំសម្រាប់អ្នកសម្របសម្រួល**

**១.១ ការងារជាក្រុម** (២០ នាទី)

បំបែកសិក្ខាកាមជាពីរក្រុម ហើយប្រគល់ជូនក្រុមនីមួយៗនូវឯកសារ ៣.១.១ ប្រភេទអំពើហិង្សាយេនឌ័រ។

ពន្យល់ដល់សិក្ខាកាមថា ពួកគេនឹងដោះស្រាយចំណោទបញ្ហានៅកម្រាលឥដ្ឋ ហើយអ្នកសម្របសម្រួលនឹងបង្ហាញស្លាយកិច្ចការទៅកាន់ពួកគេ៖




ប្រមូលកាតសម្រាប់សកម្មភាព ៣.១.១នៅលើកម្រាលឥដ្ឋ ហើយបង្កើតតារាងមួយ ដូចខាងក្រោមនេះ៖

| បុរស | ស្ត្រី | ទាំងពីរ |
|---|---|---|
| | | |
| | | |
| | | |
| | | |

ក្រុមនីមួយៗនឹងទទួលបានកាតមួយដុំ ដែលកាតទាំងនោះទាក់ទងទៅហ្នឹងអំពើហិង្សា ឬការរំលោពបំពានយេនឌ័រ បន្ទាប់មកក្រុមនីមួយៗត្រូវតំរៀបកាតទាំងនោះ ទៅតាមកន្លែងដែលអ្នកគិតថា ស័ក្តិសមនឹងកាតទាំងនោះបំផុត។

**១.២ វគ្គក្រុមធំ** (៣០ នាទី)

បង្រួមក្រុមទាំង២ចូលគ្នាវិញ  និងស្នើសុំឲ្យក្រុមនានាដើរទៅមើលរបៀបដែលក្រុមដទៃទៀតបានតំរៀបកាតរបស់ពួកគេ ហើយលើកទឹកចិត្តឲ្យសិក្ខាកាមចែករំលែងគំនិតដែលពួកគេយល់ឃើញ និងឲ្យពួកគេសួរសំណួរ។

បន្ទាប់មកជ្រើសរើសមួយក្រុម  ហើយឈរនៅជុំវិញចម្លើយសកម្មភាពល្បែងតំរៀបកាតនៅលើកម្រាលរបស់ពួកគេ ជ្រើសរើសឧទាហរណ៍ខុសៗគ្នានៃ ការរំលោភបំពាន និងហិង្សាយេនឌ័រ (GBA និង GBV)

និងសួរសំណួរដេញដោល ដូចជា៖

- តើនេះស្ថិតនៅក្នុងប្រភេទណាមួយនៃអំពើហិង្សា? តើវាអាចនឹងជាប់ពាក់ព័ន្ធជាមួយអ្វីណាខ្លះ?
- នៅទីនេះ តើនរណាទំនងជាជនបង្កហេតុ/ជនរងគ្រោះច្រើនជាង និងហេតុអ្វី?
- តើមានភាពខុសគ្នាដែរឬទេ រវាងប្រភេទអំពើហិង្សាដែល ស្ត្រី គឺជាជនរងគ្រោះ និងប្រភេទអំពើហិង្សាដែល បុរស គឺជាជនរងគ្រោះ?
- នៅក្នុងប្រភេទអំពើហិង្សាទាំងនេះ តើអ្នកគិតថាសហគមន៍អ្នកស្រលាញ់ភេទដូចគ្នា (ឬ LGBTI)ងាយរងគ្រោះដោយសារអំពើហិង្សាប្រភេទមួយណាច្រើនជាងគេ និងហេតុអ្វី?

## កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល

អ្នកសម្របសម្រួលអាចប្រើប្រាស់វីឌីអូនៅក្នុងជើងទំព័រខាងក្រោមដើម្បីគាំទ្រដល់ស្លាយនេះ។[90]

[៩] https://eige.europa.eu/gender-based-violence/what-is-gender-based-violence

[90] http://www.unwomen.org/en/what-we-do/ending-violence-against-women

# អំពើហិង្សាប្រឆាំងនឹងស្ត្រី GBV

ទង្វើណាមួយនៃអំពើហិង្សាយេនឌ័រ ដែលបណ្តាលឲ្យមាន ឬទំនងជានឹងបណ្តាលឲ្យមានគ្រោះថ្នាក់ផ្លូវកាយ ផ្លូវភេទ ឬផ្លូវចិត្ត ឬធ្វើឲ្យស្ត្រីរងគ្រោះ រួមបញ្ចូលទាំងការគម្រាមកំហែងថានឹងប្រព្រឹត្តិអំពើទាំងនោះផងដែរ ឬការគម្រាមបង្ខំ ឬការដកហូតសេរីភាពតាមទំនើងចិត្ត ទោះបីជាកើតឡើងនៅទីសាធារណៈ ឬនៅក្នុងជីវិតឯកជនក៏ដោយ។ អំពើហិង្សាប្រឆាំងនឹងស្ត្រី គួរតែបានយល់ដឹងដោយទូលំទូលាយជាងនេះ ហើយមិនមែនយកចិត្តទុកដាក់លើតែចំណុចមួយចំនួនដូចខាងក្រោមនោះទេ៖

អំពើហិង្សាផ្លូវកាយ ផ្លូវភេទ និងផ្លូវចិត្តដែលកើតឡើងនៅក្នុងគ្រួសារ រួមមាន ការវាយតប់ ការរំលោភបំពានផ្លូវភេទលើកូនស្រីនៅក្នុងផ្ទះ ឬអំពើហិង្សាទាក់ទងនឹងបណ្តាការ ការរំលោភសេពសន្តវៈកម្រិយា ការកាត់ស្បែកចុងប្រដាប់បន្តពូជស្ត្រី និងទម្លាប់អនុវត្តតាមបែបប្រពៃណីផ្សេងទៀតដែលបង្កការរងគ្រោះដល់ស្ត្រី ឬក៏អំពើហិង្សាលើដៃគូស្និទ្ធស្នាល អំពើហិង្សាលើអ្នកដែលមិនមែនជាស្វាមីភរិយា និងអំពើហិង្សាដែលទាក់ទងនឹងការកេងប្រវ័ញ្ច។ អំពើហិង្សាផ្លូវកាយ ផ្លូវភេទ និងផ្លូវចិត្តដែលកើតឡើងដែលនៅក្នុងសង្គមទូទៅ រួមមាន ការរំលោភសេពសន្តវៈ ការរំលោភបំពានផ្លូវភេទ ការបៀតបៀនផ្លូវភេទនៅទីធ្លាសាធារណៈ និងការបៀតបៀនផ្លូវភេទ និងការគម្រាមកំហែងនៅកន្លែងធ្វើការ នៅស្ថាប័នសិក្សា និងនៅកន្លែងផ្សេងទៀត ការជួញដូរស្ត្រី និងពេស្យាចារដោយបង្ខំ។ អំពើហិង្សាផ្លូវកាយ ផ្លូវភេទ និងផ្លូវចិត្តត្រូវបានបង្កឡើង ឬអនុញ្ញាតឲ្យប្រព្រឹត្តិដោយរដ្ឋមួយចំនួន នៅគ្រប់កន្លែងទាំងអស់ដែលកើតមានអំពើហិង្សា។

Source: Articles 1 and 2 of the United Nations General Assembly. Declaration on the Elimination of Violence Against Women. In: 85th Plenary Meeting. December 20, 1993. Geneva, Switzerland; 1993.

UNODC United Nations Office on Drugs and Crime

UN WOMEN

# យុទ្ធសាស្ត្រទូទៅដែលប្រើដោយដៃគូបំពាន

- ចិត្តសាស្ត្រ
  - គំរាមគំហែង
  - រំលោភបំពានផ្លូវចិត្ត (Gaslighting)
  - ល្បែងផ្លូវចិត្ត
- សេដ្ឋកិច្ច
  - ដកសិទ្ធិនៃការទទួលបានហិរញ្ញវត្ថុ
  - ប្រើប្រាស់ហិរញ្ញវត្ថុរបស់ជនរងគ្រោះទាំងអស់
  - បំផ្លាញទ្រព្យសម្បត្តិ
- ផ្លូវភេទ
  - រួមភេទដោយបង្ខំ
  - ហិង្សាលើផ្លូវភេទ
  - គ្រប់គ្រងលើការពន្យាកំណើត
- រាងកាយ
  - ហិង្សាលើរាងកាយ
  - ចេតនាធ្វើឲ្យមានគ្រោះថ្នាក់ខាងផ្លូវកាយ

UNODC United Nations Office on Drugs and Crime

UN WOMEN

# យុទ្ធសាស្ត្រទូទៅដែលប្រើដោយដៃគូបំពាន

- ការដាក់នៅដោយឡែក
  - បង្ខាំង ឬរារាំងមិនឲ្យជួបជាមួយគ្រួសារ និងមិត្តភក្តិ
- ផ្លូវច្បាប់
  - កុហកប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌអំពីជនរងគ្រោះ
- កុមារ
  - រារាំងមិនអោយជួបកូន
  - កុហកកុមារដើម្បីផ្តាច់ទំនាក់ទំនងផ្សេងៗ
  - គំរាម ឬធ្វើបាបកុមារ
- ឃ្លាំមើល (Stalking)
  - តាមឃ្លាំមើលទាំងផ្លូវកាយ និងផ្លូវចិត្ត
- ទំនាក់ទំនង
  - បង្ខូចកេរ្តិ៍ឈ្មោះ
  - ព្យាយាមមិនឲ្យទាក់ទងបាន
- ទ្រព្យសម្បត្តិ និងសត្វចិញ្ចឹម
  - បំផ្លាញ ឬធ្វើបាបដោយមិនអាចឲ្យប្រើ ឬជួបបាន

UNODC United Nations Office on Drugs and Crime

UN WOMEN

## **សកម្មភាពទីពីរ៖** មន្ត្រីអនុវត្តច្បាប់ លើការដោះស្រាយបញ្ហាចំនួន

**គោលបំណង៖** ដើម្បីបង្កើតការយល់ដឹងអំពីវិសាលភាពនៃបញ្ហា និងបង្កើតកិច្ចពិភាក្សាអំពីតួនាទីរបស់ក្រុមការងារអនុវត្តច្បាប់

**ពេលវេលា៖** ៤០ នាទី

**កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល**

មុនពេលចាប់ផ្តើមព្រឹត្តិការណ៍បណ្តុះបណ្តាល អ្នកសម្របសម្រួលគួរតែរៀបចំស្លាយមួយដែលស្តិតិទាក់ទងនឹងការរំលោភបំពាន ឬហិង្សាយេនឌ័រ (GBA/GBV) សំខាន់ៗនៅលើនោះ ស្តិតិទាំងនេះគួរតែជាការរួមបញ្ចូលគ្នានៃស្តិតិជាក់លាក់តាមប្រទេស និងស្តិតិជាសកល។

ធនធានខាងក្រោមអាចត្រូវបានប្រើប្រាស់សម្រាប់ស្តិតិជាសកលមួយចំនួន៖http://www.unwomen.org/en/what-we-do/ending-violence-against-women/facts-and-figures

អ្នកសម្របសម្រួលអាចបង្ហាញតែតួលេខរបស់ស្តិតិមុនសិន ហើយរក្សាទុកអង្គហេតុដែលទាក់ទងនឹងស្តិតិទាំងនោះនៅក្នុងឯកសារដាច់ដោយឡែកមួយ ដែលមានតែគ្រូបណ្តុះបណ្តាលប៉ុណ្ណោះដែលអាចមើលបាន។

**ការសម្របសម្រួលសកម្មភាព**

១. ពន្យល់ប្រាប់សិក្ខាកាមថា អ្នកនឹងអានអង្គហេតុមួយចំនួន ហើយពួកគេធ្វើការទស្សន៍ទាយថាតើស្តិតិណាខ្លះដែលពាក់ព័ន្ធនឹងអង្គហេតុទាំងនោះ។

២. គ្រូបណ្តុះបណ្តាលគួរតែលើកទឹកចិត្តឲ្យមានការពិភាក្សាជុំវិញស្តិតិសំខាន់ៗឧទាហរណ៍៖ សួរសំណួរ ដូចជា៖

- តើមានប្រភេទជាក់លាក់ណាមួយនៃ GBA/GBV កម្រិតខ្ពស់ នៅក្នុងតំបន់របស់ពួកគេដែរឬទេ?
- តើពួកគេគិតថាបញ្ហាផ្នែកសង្គម និងវប្បធម៌អ្វីខ្លះនៅក្នុងប្រទេសរបស់ពួកគេដែលធ្វើឲ្យ GBA/GBV មានការកើនឡើង?
- តើវាត្រូវបានគេមើលឃើញថាជាអាកប្បកិរិយា "ធម្មតា" នៅក្នុងសហគមន៍មួយចំនួន មែនដែរឬទេ?
- ហេតុអ្វីបានជាហេតុការណ៍នានាតែងតែ មិនត្រូវបានរាយការណ៍ទៅកាន់នគរបាល?

លើកទឹកចិត្តសិក្ខាកាមឲ្យធ្វើការចែករំលែកអំពីបទពិសោធន៍របស់ពួកគេនៅក្នុងការដោះស្រាយ GBA/GBV

សួរសិក្ខាកាមថា តើពួកគេមានឧទាហរណ៍ណាមួយស្តីពីទម្លាប់អនុវត្តល្អមួយ របស់ក្រុមការងារអនុវត្តច្បាប់ ដែលបំពេញការងារដើម្បីកាត់បន្ថយ GBA/GBV។

**កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល**

គេបានណែនាំថា អ្នកសម្របសម្រួលគួរតែត្រៀមឧទាហរណ៍មួយចំនួនស្តីពីទម្លាប់អនុវត្តល្អបំផុត ដើម្បីចែករំលែកជាមួយក្រុមសិក្ខាកាមមុនពេលចាប់ផ្តើមម៉ោងសិក្សា ហើយវានឹងរឹតតែមានប្រសិទ្ធភាពជាពិសេសទៀត ប្រសិនបើអ្នកសម្របសម្រួលចែករំលែករូបភាព ឬ វីឌីអូដើម្បីគាំទ្រដល់ឧទាហរណ៍ទាំងនោះ។

រូបភាព: UNODC/ UN Women/ Pathuumporn Thongking

# ម៉ោងសិក្ខាទីពីរ

# ការប្រែប្រួលនៃអំណាច ដែលស្ថិតនៅពីក្រោយការរំលោភបំពាន/អំពើហិង្សាយេនឌ័រ (GBA/GBV)

**គោលបំណង៖** ដើម្បីបង្កើតការយល់ចិត្តចំពោះជនរងគ្រោះនៃ GBA/GBV

**វត្ថុបំណងនៃការរៀនសូត្រ៖**

នៅចុងបញ្ចប់នៃម៉ោងសិក្ខានេះ សិក្ខាកាមនឹង...

- បានយល់ដឹងអំពីអំណាច និងការត្រួតត្រា
- បានពិភាក្សាអំពីបញ្ហាប្រឈមសម្រាប់ជនរងគ្រោះនៃ GBA/GBV ក្នុងការរាយការណ៍អំពី GBA/GBV ទៅក្រុមការងារអនុវត្តច្បាប់

**ពេលវេលា៖** ៩០ នាទី

| សេចក្តីពណ៌នាអំពីធនធាន | សេចក្តីណែនាំអំពីការត្រៀមសម្ភារៈ |
|---|---|
| ការធ្វើបទបង្ហាញ | |
| ៣.២.១ កិច្ចការស្តីពីអំណាច និងការត្រួតត្រា | ត្រៀមទុកជាមុននូវកិច្ចការស្រួលៗចំនួន ៣ ដែលកិច្ចការមួយៗត្រូវការ១០នាទីដើម្បីធ្វើ ជាមួយនឹងក្រដាសដែលមានការណែនាំដើម្បីឲ្យសិក្ខាកាមធ្វើតាម។ យកសម្ភារៈមកឲ្យគ្រាន់ ចឹងសិក្ខាកាមមួយៗអាចធ្វើកិច្ចការស្រួលៗនោះយ៉ាងហោចម្នាក់មួយ។ |

## ទិដ្ឋភាពទូទៅនៃម៉ោងសិក្សានេះ

| សកម្មភាព | គោលបំណង | ពេលវេលា |
|---|---|---|
| ១. អំណាច និងការត្រួតត្រា | ស្វែងយល់ពីការប្រែប្រួលអំណាច និងការត្រួតត្រាដែលកើតឡើងនៅក្នុងទំនាក់ទំនង ដែលការរំលោភបំពាន និងហិង្សាយេនឌ័រកើតឡើង | ៦០ នាទី |
| ២. អ្នកសម្របសម្រួល នឹងដឹកនាំការធ្វើបទបង្ហាញ និងក្រុមធំ | បង្ហាញសិក្ខាកាមពីវិធីខុសៗគ្នាដែលអំណាចនិងការត្រួតត្រាត្រូវបានប្រើដោយជនល្មើស | ៣០ នាទី |

## សកម្មភាពទីមួយ៖ អំណាច និងការត្រួតត្រា

**គោលបំណង៖** ដើម្បីសិក្សាស្វែងយល់ការប្រែប្រួលនៃអំណាច និងការត្រួតត្រាដែលកើតឡើងនៅក្នុងទំនាក់ទំនងនៃ GBA/GBV។

**ពេលវេលា៖** ៦០ នាទី

**សេចក្តីណែនាំសម្រាប់អ្នកសម្របសម្រួល**

**១.១ ការងារជាក្រុម** (៤៥ នាទី)

ការរៀបចំ

- សម្រាប់កិច្ចការនេះ អ្នកសម្របសម្រួលគួរតែត្រៀម "កិច្ចការ" ចំនួនបី ជាមុន ហើយកិច្ចការទាំងនោះគួរតែជាកិច្ចការសាមញ្ញ និងងាយដោះស្រាយ។ គួរតែជ្រើសយកប្រភេទរឿងហេតុនៃកិច្ចការ ដែលតែងតែកើតឡើង និងតម្រូវឲ្យមានការផ្ទង់អារម្មណ៍។ កិច្ចការនេះគួរតែចំណាយពេលមិនតិចជាង ១០ នាទី និងមិនលើសពី ១៥ នាទី ដើម្បីបញ្ចប់។ គ្រូបណ្តុះបណ្តាលគួរតែត្រៀម/ព្រីនចេញពីអ៊ីនធឺណិត នូវកម្រងសេចក្តីណែនាំដែលត្រួសត្រាយផ្លូវសម្រាប់ការដំណើរការកិច្ចការនេះ។ កិច្ចការទាំងនោះគួរតែរួមបញ្ចូលឧទាហរណ៍៖
  + ១. បត់យន្តហោះក្រដាស
  + ២. ចងវត្ថុពីរជាមួយគ្នា ដោយប្រើចំណងពិសេសមួយ
  + ៣. កាត់ក្រដាសរូបសត្វ
  + ៤. ធ្វើតាមក្រដាសណែនាំ ដោយសង់ផ្ទះដោយប្រដាប់លេងរបស់កូនក្មេង ឬដីឥដ្ឋ។

- ក្រដាសណែនាំ របស់កិច្ចការគួរតែដាក់នៅក្នុងស្រោមសំបុត្រដាច់ដោយឡែកពីគ្នាជាមុន ធ្វើដូច្នេះសិក្ខាកាមអាចអានក្រដាសកិច្ចការរបស់ពួកគេបាននោះទេ រហូតទាល់តែដល់ពេលពួកគេធ្វើកិច្ចការ។

វិធីសាស្ត្រ៖




Dragon
Dragon
Designed by Jo Nakashima
http://jonakashima.com.br
http://youtube.com/jonakashima
Date: 20/Feb/2015
Difficulty Level: low intermediate
Time to fold it: 30 minutes
Video: http://youtu.be/KUsxMXwCW8A
Paper: 20cm x 20cm
Standard paper
Tissue foil
Wet folding
1.
2.
3.
4.
5.
6.
7.
8.
9.


Dragon
10.
11.
12.
13.
14.
15.
16.
17.
18.
19.
20.
21.
22.
23.
24.


Dragon
25.
26.
27.
28.
29.
30.
31.
32.
33.
Pleat-fold under the wings
34.
35.
36.


Dragon
37.
38.
39.
Release the trapped layers
40.
41.
42.
43.
44.
45.
46.
47.
48.


Dragon
49.
50.
51.
52.
53.
54.
55.
56.




- ចែកសិក្ខាកាមជាក្រុមតូចៗ ដែលក្នុងមួយក្រុមមានគ្នា ៣ នាក់ និងផ្តល់ជូនក្រុមនីមួយៗនូវ ឯកសារ ៣.២.១ អំណាច និងការត្រួតត្រា
- ពន្យល់ប្រាប់ពួកគេថាជាមុនថា ក្នុងកិច្ចការគឺមានតួអង្គ ៣ ផ្សេងគ្នា ហើយសមាជិកម្នាក់ៗនឹងឆ្លាស់វេនគ្នាដើរ តួ។ ដូច្នេះម្នាក់ៗនឹងត្រូវធ្វើកិច្ចការដើរតួ ៣ ដងដូចគ្នា។
- តួអង្គ មានដូចតទៅ៖
  + ១. **អ្នករួចខ្លួន/ជនរងគ្រោះ**៖ អ្នកនឹងត្រូវបំពេញកិច្ចការជាក់ស្តែងម្នាក់មួយ។
  + ២. **ជនបង្កហេតុ**៖ អ្នកនឹងចំណាយពេល ៧ នាទីដំបូង និយាយរឿងអវិជ្ជមានទៅកាន់អ្នករួចខ្លួន ឬជនរងគ្រោះ និង ៣ នាទីបន្ទាប់លើកទឹកចិត្តខ្លួន ដែលជាជនបង្កហេតុ។

+ ៣. **អ្នកអង្កេតការណ៍៖** អ្នកនឹងត្រូវមើលអន្តរកម្មរវាងអ្នករួចខ្លួនឬជនរងគ្រោះ និងជនបង្កហេតុ និងធ្វើការអង្កេតលើតរិយាបទរបស់អ្នកទាំង២នោះ និងសួរខ្លួនឯងថាមានអារម្មណ៍យ៉ាងដូចម្តេចខ្លះនៅពេលមើលឃើញអន្តរកម្មទាំងនោះ។

- នៅក្នុងការសម្តែងនីមួយៗ កិច្ចការនេះនឹងចំណាយពេល ១០ នាទី ហើយអ្នកសម្របសម្រួលនឹងត្រួតពិនិត្យមើលពេលវេលា និងឲ្យសញ្ញាដល់ ជនបង្កហេតុថាពួកគេដល់ពេលដែលត្រូវចំនាយ ៣ នាទីសម្រាប់លើកទឹកចិត្តជនបង្កហេតុខ្លួនឯងហើយ។
- ពន្យល់សិក្ខាកាមថា សកម្មភាពនេះត្រូវបានរៀបរៀងឡើងដោយចេតនា ដើម្បីធ្វើឲ្យពួកគេមានអារម្មណ៍មិនសុខស្រួល ដូច្នេះការចូលតួរបស់តួអង្គនឹងកាន់តែសមជាងមុន។
- បន្ទាប់មកទៀត ឲ្យក្រុមមួយៗនូវ កញ្ចប់ក្រដាសការណែនាំ៣ដុំ ទុកក្នុងស្រោមសំបុត្របិទជិត។ ពួកគេអាចបើកមើលស្រោមសំបុត្រនោះបាន លុះត្រាតែមានការអនុញ្ញាតឬក៏នៅពេលដែលពួកគេដល់វេនដើរតួ អ្នករួចចេញ ឬជនរងគ្រោះ។
- ធ្វើសកម្មភាពនេះ ៣ ដង ចឹងសមាជិកក្រុមនីមួយៗអាចឆ្លងកាត់ដើរតួទាំងអស់។

**១.២ ការពិភាក្សា** (១៥ នាទី)

នៅពេលបញ្ចប់រួចរាល់ហើយ បង្ហាញស្លាយ និងទុកពេលជូនសិក្ខាកាមចំនួន ១០ នាទី ដើម្បីឲ្យពួកគេធ្វើការពិភាក្សាគ្នាអំពីសំណួរទាំងនោះ។



ប្រើពេលល ៥ នាទី ដើម្បីប្រមូលមតិត្រលប់ពីសិក្ខាកាម។

## កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល

គោលបំណងរបស់កិច្ចការនេះគឺដើម្បីសិក្សាស្វែងយល់អំពីការប្រែប្រួលនៃអំណាច និង ការត្រួតត្រា នៅក្នុងស្ថានភាពនៃ GBA/GBV មួយ។

ជាញឹកញាប់ មនុស្សមិនអាចយល់អំពីមូលហេតុដែលបុគ្គលមួយរូប អាចរស់រាននៅក្នុងស្ថានភាព ដែលមានការរំលោភបំពានបាននោះទេ។ មូលហេតុទាំងនោះមានភាពស្មុគស្មាញ ហើយនៅពេលនេះ យើងនឹងធ្វើការសិក្សាស្វែងយល់តាមរយៈស្លាយទាំងនេះ។ សកម្មភាពទាំងនេះមានបំណងធ្វើឲ្យ សិក្ខាកាមគិតអំពីរឿងជះឥទ្ធិពលការរំលោភបំពាន និងហិង្សាយេនឌ័រ GBA/GBV មកលើទំនុកចិត្ត របស់មនុស្សម្នាក់ៗ។ អាចពន្យល់ថែមថា ប្រសិនបើយើងត្រូវបានគេប្រាប់ដដែលថា យើងមិនទាន់ល្អ គ្រប់គ្រាន់នោះទេ យូរៗទៅយើងនឹងមានអារម្មណ៍ ហើយជឿថាយើងពិតជាមិនទាន់ល្អគ្រប់គ្រាន់ដូចគេ និយាយមែន ។ ប្រសិនបើយើងនៅតែបន្តរស់នៅ ដោយមានភាពភ័យខ្លាចចំពោះអំពើហិង្សា ជាបន្តបន្ទាប់នោះ វានឹងជះឥទ្ធិពលលើរបៀបដែលយើងឆ្លុះបញ្ចាំងពីខ្លួនឯង និងជឿតាមអ្វីដែល អ្នកដទៃមើលមកយើង ហើយស្ថានភាពបែបនេះក៏ជះឥទ្ធិពលលើសម្រេចចិត្តរបស់នរណាម្នាក់ នៅក្នុង ការទៅជួបក្រុមមន្ត្រីអនុវត្តច្បាប់ផងដែរ។

## **សកម្មភាពទីពីរៈ** ការធ្វើបទបង្ហាញ និងការប្រជុំក្រុម ដែលដឹកនាំដោយអ្នកសម្របសម្រួល

**គោលបំណងៈ** ដើម្បីពន្យល់សិក្ខាកាមអំពីយុទ្ធសាស្ត្រខុសៗគ្នានៃអំណាច និងការត្រួតត្រាដែលត្រូវ បានប្រើប្រាស់ដោយជនបង្កហេតុ

**ពេលវេលាៈ** ៣០ នាទី

**២.១ ការធ្វើបទបង្ហាញអំពីអំណាច និងការត្រួតត្រា** (១៥ នាទី)

ប្រើស្លាយដើម្បីពន្យល់សិក្ខាកាមអំពីយុទ្ធសាស្ត្រខុសៗគ្នាដែលជនបង្កហេតុប្រើប្រាស់ដើម្បី ប្រើអំណាច និងការត្រួតត្រាលើអ្នករួចខ្លួន/ជនរងគ្រោះ។

## ២.២ ការប្រជុំក្រុម (១៥ នាទី)




១. សួរទៅកាន់ក្រុមទាំងមូលថា តើ ពួកគេគិ តថា ឧបសគ្គអ្វី ខ្លះដែលរារាំងមិ នឲ្យអ្នករួចខ្លួន ឬ ជនរងគ្រោះ ក្នុងការស្វែងរកជំនួយពី ក្រុមមន្ត្រី អនុវត្តច្បាប់។

២. សួរទៅកាន់ក្រុមថា តើ ពួកគេគិ តថាមានយោបល់អ្វី ខ្លះ សម្រាប់ជួយឲ្យក្រុមមន្ត្រី អនុវត្ត ច្បាប់ អាចជួយលុបបំបាត់ ឧបសគ្គទាំងនោះបាន ហើ យថែមទាំងអាចធ្វើ ឲ្យអ្នករួចគេចខ្លួន ឬជនរងគ្រោះហ៊ា នចេញទៅស្វែងជំនួយ និ ងគ្រាំទ្រ ជាមួយនឹ ងអារម្មណ៍ ត្រូវបានគេ ស្វាគមន៍ និ ងទទួលស្គាល់ដោយវប្បធម៌ សង្គម។

៣. អ្នកសម្របសម្រួលគួរតែត្រៀមឧទាហរណ៍ ជាក់លាក់ក្នុងប្រទេស ដែលបង្ហាញពី ក្រុមមន្ត្រី អនុវត្តច្បាប់កំពុងធ្វើ សកម្មភាព ដែលធ្វើ ឲ្យមានរូបភាពបែបវិ ជ្ជមាននៅក្នុងវប្បធម៌ សង្គម ធ្វើ ឲ្យអ្នករួចគេចខ្លួន ឬជនរងគ្រោះហ៊ា នចេញទៅស្វែងជំនួយនិ ងគ្រាំទ្រ ជាមួយនឹ ង អារម្មណ៍ ត្រូវបានគេស្វាគមន៍ ។ ឧទាហរណ៍ រួមមាន៖

- ការចុះផ្តល់សេវាសាធារណៈនៅតាមសហគមន៍ដើម្បីអប់រំសមាជិករបស់ សហគមន៍អំពី GBA/GBV និងសេវានានា
- យុទ្ធនាការផ្សព្វផ្សាយ
- ការធ្វើការជាមួយអ្នកដឹកនាំសហគមន៍

# ម៉ោងសិក្ខាទីបី

# ក្របខណ្ឌច្បាប់ និងដំណោះស្រាយសម្រាប់យេនឌ័រផ្អែកលើមូលដ្ឋានសិទ្ធិ

## គោលបំណង៖ ធ្វើឲ្យសិក្ខាកាមមានភាពសាំជាមួយនឹងក្របខណ្ឌច្បាប់ និងដំណោះស្រាយសម្រាប់យេនឌ័រផ្អែកលើមូលដ្ឋានសិទ្ធិ

## វត្ថុបំណងនៃការរៀនសូត្រ៖

នៅចុងបញ្ចប់នៃម៉ោងសិក្ខានេះ សិក្ខាកាមនឹង...

- ដឹងអំពីអនុសញ្ញា និងក្របខណ្ឌច្បាប់សំខាន់ៗមួយចំនួន ដែលគាំទ្រដល់សមភាពយេនឌ័រ
- ពន្យល់បន្ថែមថាតើ ដំណោះស្រាយសម្រាប់យេនឌ័រផ្អែកលើមូលដ្ឋានសិទ្ធិជាអ្វី
- រំឭកឡើងវិញអំពីប្រការយ៉ាងតិចបី នៃ CEDAW និងរបៀបដែលប្រការទាំងនោះត្រូវបានយកមកអនុវត្តនៅក្នុងបរិបទនៃការអនុវត្តច្បាប់

**ពេលវេលា៖** ៩០ នាទី

| សេចក្តីពណ៌នាអំពីធនធាន | សេចក្តីណែនាំអំពីការត្រៀមសម្ភារៈ |
|---|---|
| ការធ្វើបទបង្ហាញ | |
| ៣.៣.១ ឯកសារ CEDAW | ព្រីនចេញជូនសិក្ខាកាមម្នាក់មួយច្បាប់ |

## ទិដ្ឋភាពទូទៅនៃម៉ោងសិក្សានេះ

| សកម្មភាព | គោលបំណង | ពេលវេលា |
|---|---|---|
| ១. ទិដ្ឋភាពទូទៅ នៃក្របខណ្ឌច្បាប់ | បង្ហាញជូនសិក្ខាកាមពីទិដ្ឋភាពទូទៅនៃអនុសញ្ញា និងក្របខណ្ឌច្បាប់សំខាន់ៗមួយចំនួន ដែលគាំទ្រដល់សមភាពយេនឌ័រ | ៣០ នាទី |
| ២. ប្រើប្រាស់វិធីសាស្ត្រដោយផ្អែកលើមូលដ្ឋានសិទ្ធិមនុស្ស ជាមួយ CEDAW | បង្កើតគំនិតនៃការប្រើប្រាស់វិធីសាស្ត្រដោយផ្អែកលើមូលដ្ឋានសិទ្ធិមនុស្ស តាមរយៈ CEDAW ក្នុងបរិបទក្រុមមន្ត្រីអនុវត្តច្បាប់ | ៦០ នាទី |

## **សកម្មភាពទីមួយ៖** ទិដ្ឋភាពទូទៅនៃក្របខណ្ឌច្បាប់

**គោលបំណង៖** ដើម្បីផ្តល់ជូនសិក្ខាកាមនូវទិដ្ឋភាពទូទៅនៃក្របខណ្ឌច្បាប់សំខាន់ៗអំពីសមភាពយេនឌ័រ។

**សេចក្តីណែនាំសម្រាប់អ្នកសម្របសម្រួល**

**១.១ ការធ្វើបទបង្ហាញ** (៣០ នាទី)

សួរសិក្ខាកាមថាតើ "សិទ្ធិមនុស្ស" មានអត្ថន័យយ៉ាងដូចម្តេច

## កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល៖

ពន្យល់ថា សមភាពយេនឌ័រគឺជាចំណុចសំខាន់របស់សិទ្ធិមនុស្ស ហើយច្បាប់សិទ្ធិមនុស្សអន្តរជាតិទាមទារឲ្យមាន «សិទ្ធិស្មើភាពរវាងបុរស និងស្ត្រី»។

គ្រប់សន្ធិសញ្ញាទាំងអស់ដែលនឹងលើកឡើងជាបន្តបន្ទាប់នៅខាងក្រោម ត្រូវបានលើកឡើងដោយផ្អែកលើមូលដ្ឋានទាមទារឲ្យមានសមភាពយេនឌ័រ។

ទោះបីជាយ៉ាងណាក៏ដោយ ដូចដែលយើងបានឃើញនៅក្នុងវគ្គបណ្តុះបណ្តាលទាំងមូលរួចហើយទម្លាប់ អនុវត្តផ្នែកវប្បធម៌ និងភាពអយុត្តិធម៌នៅក្នុងសង្គមដែលបានចាក់ឫសគល់យ៉ាងជ្រៅ បានបង្ហាញថា នៅពេលខ្លះ ស្ត្រីបានទទួលរងការរើសអើង និងមានការរំលោភបំពានលើសិទ្ធិរបស់ពួកគេ។

ឧទាហរណ៍៖

- អំពើហិង្សាយេនឌ័រ មានផលប៉ះពាល់លើស្ត្រីយ៉ាងតិច ៣0% នៅលើសកលលោក។[99]

ហើយនៅក្នុងប្រទេសមួយចំនួន៖

- ច្បាប់ និងគោលនយោបាយហាមឃាត់ស្ត្រីពីការទទួលបានសិទ្ធិស្មើគ្នានូវដីធ្លី ទ្រព្យសម្បត្តិ និងផ្ទះ
- ការរើសអើងខាងសេដ្ឋកិច្ច និង ការរើសអើងខាងសង្គមបណ្តាលឲ្យមានជម្រើសនៅក្នុងជីវិតសម្រាប់ស្ត្រី កាន់តែតិចតួច និងកាន់តែក្រីក្រថែមទៀត ដែលធ្វើឲ្យពួកគេងាយរងគ្រោះដោយសារការជួញដូរ
- ស្ត្រីមិនត្រូវបានអនុញ្ញាតឲ្យទទួលបានសិទ្ធិពាក់ព័ន្ធនឹងសុខភាពផ្លូវភេទ និងសុខភាពបន្តពូជរបស់ពួកគេនោះទេ
- អ្នកការពារសិទ្ធិមនុស្សរបស់ស្ត្រីត្រូវបានបណ្តេញចេញពីសហគមន៍របស់ពួកគេ និង ត្រូវបានគេយល់ថាជាអ្នកបង្កការគម្រាមកំហែងដល់សាសនា កិត្តិយស ឬវប្បធម៌
- តួនាទីដ៏សំខាន់របស់ស្ត្រីចំពោះសន្តិភាព និងសន្តិសុខ ជាញឹកញាប់ ត្រូវបានគេមើលរំលង ដោយសារតែហានិភ័យជាក់លាក់ណាមួយដែលពួកគេនឹងត្រូវប្រឈមនៅក្នុងស្ថានភាពដែលមានជម្លោះ
- លើសពីនេះទៀត ក្រុមស្ត្រីមួយចំនួន ប្រឈមមុខនឹងកញ្ចុំនៃការរើសអើងរួមបញ្ចូលគ្នាជាច្រើន ដោយសារតែកត្តានានា ដូចជា អាយុ ជាតិសាសន៍ ពិការភាព ឬស្ថានភាពផ្នែកសេដ្ឋកិច្ច និងសង្គមរបស់ពួកគេ ដូចជា ទំនោរផ្លូវភេទ បន្ថែមពីលើយេនឌ័ររបស់ពួកគេ។

---

[99] https://www.ohchr.org/EN/Issues/Women/WRGS/Pages/WRGSIndex.aspx.

- ដើម្បីធានាឲ្យបានសិទ្ធិមនុស្សរបស់ស្ត្រីប្រកបដោយប្រសិទ្ធភាពនោះ ជាដំបូង គឺតម្រូវឲ្យមានការយល់ដឹងគ្រប់ជ្រុងជ្រោយអំពីរចនាសម្ព័ន្ធសង្គម និងទំនាក់ទំនងនៃអំណាចដែលមិនត្រឹមតែបង្កើតជាគ្រោងមួយសម្រាប់ច្បាប់ និងនយោបាយប៉ុណ្ណោះទេ ប៉ុន្តែវាក៏បង្កើតជាគ្រោងសម្រាប់ផ្នែកសេដ្ឋកិច្ច ការប្រែប្រួលនៃសង្គម និងជីវិតគ្រួសារ និងសហគមន៍ផងដែរ។
- ផ្នត់គំនិតយេនឌ័រដែលបង្កភាពអន្តរាយ ចាំបាច់ត្រូវតែលុបបំបាត់ ធ្វើដូច្នេះស្ត្រីនឹងលែងត្រូវបានមើលថាក្នុងផ្លូវ ដែលថា «ស្ត្រីគួរតែធ្វើបែបនេះ ឬបែបនោះ» តែបង្ហាញមកវិញថាស្ត្រីគឺជាស្ត្រី ស្ត្រីគឺជាបុគ្គលម្នាក់ ដែលមានតម្រូវការផ្ទាល់ខ្លួន និងមានអ្វីដែលពួកគេគួរតែទទួលបាន។

**ពិភាក្សា**

តើសមភាព និងសមធម៌មានភាពខុសគ្នាយ៉ាងដូចម្តេចខ្លះ?

## សមភាព ធៀបនឹង សមធម៌

«សមភាពយេនឌ័រ ឬសមភាពរវាងបុរស និងស្ត្រី... មិនមែនមានន័យថា ស្ត្រី និងបុរស ចាំបាច់ត្រូវតែប្រែក្លាយជាដូចគ្នានោះទេ ប៉ុន្តែវាមានន័យថា សិទ្ធិ ទំនួលខុសត្រូវ និងឱកាស របស់ពួកគេនឹងមិនអាស្រ័យលើ ថាតើពួកគេត្រូវបានកើតមកជាបុរស ឬស្ត្រីនោះទេ។

សមភាពយេនឌ័រ មានន័យថា ភាពយុត្តិធម៌នៅក្នុងការគោរពចំពោះបុរស និងស្ត្រី ស្របតាម តម្រូវការរបស់ពួកគេរៀងៗខ្លួន។ ចំណុចនេះអាចរួមបញ្ចូលការគោរពចំពោះពួកគេស្មើៗគ្នាក្តី ឬខុសគ្នាក្តី ប៉ុន្តែត្រូវបានពួកគេត្រូវបានគេផ្តល់ សិទ្ធិ អត្ថប្រយោជន៍ កាតព្វកិច្ច និងឱកាស ដូចៗគ្នា។»[១២] – *អង្គការអប់រំ វិទ្យាសាស្ត្រ និង វប្បធម៌នៃអង្គការសហប្រជាជាតិ (UNESDOC)*

https://unesdoc.unesco.org/ark:/48223/pf0000121145

UNODC United Nations Office on Drugs and Crime

UN WOMEN

## សមភាពជាសំខាន់

- ទទួលស្គាល់ថា មិនប្រាដថាមនុស្សគ្រប់រូបមានរបស់ល្អដូចគ្នា អាចទទួលបានលទ្ធផលដូចគ្នា ហើយសុទ្ធតែទទួលបានឱកាសដូចគ្នានោះទេ។ ឧទាហរណ៍ ការប្រកួតលើទីធ្លាប្រកួតមានកម្ពស់មិនស្មើគ្នា ឬការមកពីសហគមន៍ដែលគេមិនអើពើ ឬមានពិការភាពផ្លូវកាយ។
- សមភាពជាសំខាន់(Substantive Equality) ទទួលស្គាល់ថា ប្រហែលជាចាំបាច់ត្រូវមានវិធីសាស្ត្រជាក់លាក់មួយចំនួន ដើម្បីកែតម្រូវ អតុល្យភាពនៅក្នុងប្រព័ន្ធ ដូច្នេះបុគ្គលគ្រប់រូបនឹងត្រូវបានផ្តល់ឱកាសទទួលស្មើៗគ្នានោះ ហើយនឹងមានសំណាងដូចគ្នានៅដើម្បីសម្រេចបានអ្វីមួយ ឬទទួលបានលទ្ធផលដូចគ្នាផងដែរ។

UNODC United Nations Office on Drugs and Crime

UN WOMEN

[១២] https://unesdoc.unesco.org/ark:/48223/pf0000121145.

## CEDAW

- អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ
- ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៧៩
- ត្រូវបានពណ៌នាថាជាច្បាប់សិទ្ធិស្ត្រីអន្តរជាតិ
- មាន ៣០ ប្រការ

កំណត់និយមន័យ ការរើសអើង ថាជា៖

«...ការបែងចែក ការដាក់ចេញ ឬការរឹតត្បិតណាមួយ ផ្អែកលើភេទ ដែលមានអនុភាព ឬមានបំណងធ្វើឲ្យខូចខាត ឬធ្វើមោយៈ ភាពនូវការទទួលស្គាល់ ការអរស្រ័យផល ឬការអនុវត្តដោយស្ត្រី ដោយមិនគិតដល់ស្ថានភាពអាពាហ៍ពិពាហ៍របស់ពួកគេ ដោយឈរលើមូលដ្ឋានស្មើភាពគ្នារវាងបុរស និងស្ត្រី នៃមូលដ្ឋានសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាននៅក្នុងវិស័យនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ ពលរដ្ឋ ឬនៅក្នុងវិស័យណាមួយផ្សេងទៀត។»

UNODC United Nations Office on Drugs and Crime

UN WOMEN

## ការប្តេជ្ញារបស់ CEDAW

**តាមរយៈការចុះហត្ថលេខាលើអនុសញ្ញានេះ រដ្ឋាភិបាលប្តេជ្ញាចិត្ត**[13]...

រួមបញ្ចូលគោលការណ៍ដែលមានសមភាពរវាងបុរស និងស្ត្រីនៅក្នុងប្រព័ន្ធច្បាប់របស់ពួកគេ ហើយលុបចោលនូវរាល់ច្បាប់ដែលមានការរើសអើងទាំងអស់ និងអនុម័តិច្បាប់ដែលសមស្រប ដែលហាមឃាត់ការរើសអើងប្រឆាំងនឹងស្ត្រី

១. បង្កើតសាលាជម្រះក្តី និងស្ថាប័នសាធារណៈផ្សេងទៀត ដើម្បីធានាចំពោះការការពារស្ត្រី ប្រឆាំងនឹងការរើសអើងប្រកបដោយប្រសិទ្ធភាព និង

២. ធានាឲ្យមានការលុបបំបាត់គ្រប់ទង្វើនៃការរើសអើងប្រឆាំង នឹងស្ត្រីទាំងអស់ ដែលបង្កឡើងដោយមនុស្ស អង្គភាព ឬសហគ្រាសនានា។

http://www.un.org/womenwatch/daw/cedaw

UNODC United Nations Office on Drugs and Crime

UN WOMEN

5 GENDER EQUALITY

[13] http://www.un.org/womenwatch/daw/cedaw.

## កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល

គ្រប់រដ្ឋាភិបាលនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ទាំងអស់ សុទ្ធតែបានធ្វើការប្តេជ្ញាចិត្តថានឹងពង្រឹងសិទ្ធិមនុស្សរបស់ស្ត្រី និងលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រី តាមរយៈការផ្តល់សច្ចាប័ន ឬការចូលជាសមាជិក អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ (CEDAW) ស្របពេលជាមួយគ្នានេះ ប្រទេសនានា ដូចជា ប្រទេសកម្ពុជា ប្រទេសហ្វីលីពីន ប្រទេសថៃ និងប្រទេសទីម័រខាងកើត ក៏បានបង្កើនវឌ្ឍនភាពនៅក្នុងការធ្វើសច្ចាប័ន ឬការចូលជាសមាជិកពិធីសារតាមជម្រើសនៃ CEDAW ។

ប៉ុន្តែ នៅតែមាន ខដាក់លក្ខខណ្ឌ ចំពោះ CEDAW ពោលគឺ៖

| | |
|---|---|
| ប្រទេសឥណ្ឌូនេស៊ី | មាត្រា ២៩ (១) |
| ប្រទេសម៉ាឡេស៊ី | ទូទៅ៖ ប្រសិនបើ "ពុំមានភាពខុសគ្នាពីបញ្ញត្តិនានានៃច្បាប់ Islamic sharia" និងរដ្ឋធម្មនុញ្ញនោះទេ<br>មាត្រា ៥ (ក)<br>មាត្រា ៧ (ខ)<br>មាត្រា ៩ ៩២)<br>មាត្រា ១៦ (១) (ក)(គ)(ច)(ឆ)<br>មាត្រា ១១ ត្រូវបានបកស្រាយថា «ហាមឃាត់តែការរើសអើងដែលផ្អែកលើមូលដ្ឋានសមភាពរវាងបុរស និងស្ត្រីប៉ុណ្ណោះ» |
| ប្រទេសមីយ៉ាន់ម៉ា | មាត្រា ២៩ |
| ប្រទេសថៃ | មាត្រា ២៩(១) |
| ប្រទេសវៀតណាម | មាត្រា ២៩(១) |




## កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល

គោលដៅរបស់សិក្ខាកាម គឺមិនចាំបាច់ត្រូវសិក្សាស្វែងយល់អំពីក្របខណ្ឌច្បាប់ឲ្យស៊ីជម្រៅខ្លាំងនោះទេ ក្នុងមេរៀននេះ។ គោលបំណង គឺដើម្បីណែនាំទៅកាន់ពួកគេ ឲ្យស្គាល់អំពីក្របខណ្ឌច្បាប់ទាំងនោះ និងផ្តល់ជូននូវទិដ្ឋភាពទូទៅអំពីបរិបទ ខ្លឹមសារ និងគោលបំណងនៃក្របខណ្ឌច្បាប់ទាំងនោះ។ ធ្វើដូច្នេះ សិក្ខាកាមនឹងដឹងអំពីអ្វីដែលគាំទ្រ និងជម្រុញ សមភាពយេនឌ័រ នៅកម្រិតអន្តរជាតិ និងកម្រិតជាតិ។ ជាចុងបញ្ចប់ គឺដើម្បីជម្រុញទឹកចិត្តក្រុមសិក្ខាកាមអនុវត្តច្បាប់ ឲ្យចាត់វិធានការដើម្បីធ្វើឲ្យមានឆ្លើយតបនឹងយេនឌ័របានកាន់តែខ្លាំង នៅក្នុងប្រតិបត្តិការការងាររបស់ពួកគេ តាមរយៈការដឹងអំពីលក្ខខណ្ឌតម្រូវផ្នែកច្បាប់ ព្រមទាំងជម្រុញទឹកចិត្តផ្នែកសីលធម៌ និងផ្នែកផ្លូវចិត្តថា។ ម៉ោងសិក្សាផ្សេងទៀតនៅក្នុងវគ្គបណ្តុះបណ្តាលនេះ គឺជាការជម្រុញបន្ថែម។

ដូច្នេះអ្នកសម្របសម្រួលគួរតែមានការយល់ដឹងអំពីក្របខណ្ឌច្បាប់ ដែលធ្វើឲ្យពួកគេអាចផ្តល់ទិដ្ឋភាពទូទៅអំពីបរិបទ ខ្លឹមសារ និងគោលបំណងនៃក្របខណ្ឌច្បាប់ទាំងនោះ។ អាចរកតំណភ្ជាប់ទៅកាន់ប្រភពព័ត៌មាននានាដែលបានលើកឡើងទាំងអស់ ត្រូវបានផ្តល់ជូននៅក្នុងលេខយោងនីមួយៗ។

---

[១៤] https://www.un.org/womenwatch/daw/beijing/platform/
[១៥] http://www.peacewomen.org/why-WPS/solutions/resolutions
[១៦] https://sustainabledevelopment.un.org/?menu=1300
[១៧] https://www.agipp.org/en/issuesthataffectwomensparti/national-strategic-plan-advancement-women

## តើវិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្ស (HRBA) គឺជាអ្វី?

តើវិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្សគឺជាអ្វី?

វិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្ស គឺជាក្របខណ្ឌនៃទស្សនៈមួយ សម្រាប់ដំណើរការអភិវឌ្ឍធនធានមនុស្ស ដែលតាមធម្មតា គឺផ្អែកលើស្តង់ដារសិទ្ធិមនុស្សអន្តរជាតិ និងត្រូវបានកំណត់ទិសដៅនៃប្រតិបត្តិការ ចំពោះការលើកកម្ពស់ និងការពារសិទ្ធិមនុស្ស។ វិធីសាស្ត្រនេះព្យាយាមវិភាគអំពីវិសមភាពដែលជា ចំណុចសំខាន់នៃបញ្ហានានានៃការអភិវឌ្ឍ និងកែតម្រូវទម្លាប់អនុវត្តដែលមានការរើសអើង និងការបែង ចែកអំណាចដោយអយុត្តិធម៌ ដែលបង្កឧបសគ្គដល់វឌ្ឍនភាពនៃការអភិវឌ្ឍ។
18

https://www.unicef.org/policyanalysis/rights/index_62012.html.

UNODC United Nations Office on Drugs and Crime

UN WOMEN

### កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល

សិក្ខាកាមភាគច្រើន ទំនងជានឹងពុំមានតួនាទីដែលពួកគេជាអ្នកសម្រេចចិត្តលើគោលនយោបាយ និង ទម្លាប់អនុវត្តនោះទេ ហើយទោះបីជាពួកគេមានតួនាទីក៏ដោយ ក៏ការគាំទ្រចំពោះការបង្កើតវិធីសាស្ត្រ ដែលផ្អែកលើសិទ្ធិ (RBA) នៅក្នុងការងារអនុវត្តច្បាប់ អាចនឹងតម្រូវឲ្យមានគំនិតផ្តួចផ្តើមនៅក្នុងការ អភិវឌ្ឍសមត្ថភាព ច្រើនជាងវគ្គបណ្តុះបណ្តាលដែលមានរយៈពេលបីថ្ងៃ។ គោលបំណងនៃសកម្មភាព នេះ គឺដើម្បីណែនាំសិក្ខាកាមអំពីទស្សនៈរបស់ RBA និង របៀបដែលសិទ្ធិមនុស្សនានាគួរតែត្រូវបាន ប្រមូលផ្តុំគ្នា ដើម្បីផ្តល់ការណែនាំដែលមានយុទ្ធសាស្ត្រល្អមួយ។ អ្នកសម្របសម្រួលគួរតែបញ្ជាក់ថា ជាក់ស្តែង ការបង្កើតវិធីសាស្ត្រដែលផ្អែកលើសិទ្ធិ មានភាពស្មុគស្មាញ ពីព្រោះវាតម្រូវឲ្យមានការវិភាគ យ៉ាងពេញលេញ និងការយល់ដឹងអំពីកត្តាសង្គម និងនយោបាយដែលជះឥទ្ធិពលដល់ការបង្កើតវិធី សាស្ត្រនោះ ជាពិសេសនៅក្នុងបរិបទរបស់ប្រទេសដែលវិធីសាស្ត្រនេះកំពុងតែត្រូវបានបង្កើតឡើង។[១៩]

សកម្មភាពនៅក្នុងម៉ោងសិក្សានេះ គឺជាវិធីសាស្ត្រដ៏សាមញ្ញមួយនៅក្នុងការណែនាំអំពី RBA នៅក្នុង នាមជា ទស្សនៈមួយ។

---

[១៨] https://www.unicef.org/policyanalysis/rights/index_62012.html.
[១៩] https://www.un.org/womenwatch/daw/news/savitri.htm.

## គោលការណ៍ PANEL នៃ HRBA[20]

**ការចូលរួម (P = Participation)**

ជនគ្រប់រូបគួរចូលរួមក្នុងការសម្រេចចិត្តនានា នៅពេលដែលមានផលប៉ះពាល់ចំពោះសិទ្ធិរបស់ពួកគេ។

**គណនេយ្យភាព (A = Accountability)**

គួរតែមានការពិនិត្យតាមដានអំពីរបៀបដែលសិទ្ធិមនុស្សកំពុងរងផលប៉ះពាល់ ព្រមទាំងការកែតម្រូវនានានៅពេលដែលមានហេតុការណ៍ ដែលបណ្តាលឲ្យមានផលប៉ះពាល់អវិជ្ជមានកើតឡើង។

**ការមិនរើសអើង និងសមភាព (N = Non-Discrimination and Equality)**

រាល់ទម្រង់នៃការរើសអើងទាំងអស់ត្រូវបាមឃាត់ ការពារ និងលុបបំបាត់។ ផ្តល់អទិភាពដល់មនុស្ស ដែលប្រឈមមុខនឹងឧបសគ្គដ៏ធំ ក្នុងការទទួលស្គាល់សិទ្ធិរបស់ពួកគេ ។

**ការផ្តល់ភាពអង់អាច (E = Empowerment)**

មនុស្សគ្រប់រូបគួរតែយល់ដឹងអំពីសិទ្ធិរបស់ពួកគេ និងគួរតែទទួលបានការគាំទ្រទាំងស្រុង ឲ្យចូលរួមនៅក្នុងការបង្កើតគោលនយោបាយ និងទម្លាប់អនុវត្តនានា ដែលមានទាក់ទងនឹងជីវិតរបស់ពួកគេ។

**ភាពស្របច្បាប់ (L = Legality)**

វិធីសាស្ត្រនានាគួរតែផ្អែកលើមូលដ្ឋាននៃសិទ្ធិស្របច្បាប់ ដែលត្រូវបានកំណត់នៅក្នុងច្បាប់របស់ប្រទេស និងច្បាប់អន្តរជាតិ។

UNODC United Nations Office on Drugs and Crime

http://www.scottishhumanrights.com/media/1409/shrc_hrba_leaflet.pdf

UN WOMEN

## **សកម្មភាពទីពីរ៖** អនុវត្ត HRBA ដោយប្រើ CEDAW

**គោលបំណង៖** ដើម្បីបង្កើតគំនិតអំពីការអនុវត្ត HBRA តាមរយៈ CEDAW នៅក្នុងបរិបទរបស់ក្រុមការងារអនុវត្តច្បាប់

**ពេលវេលា៖ ៦០ នាទី**

**សេចក្តីណែនាំសម្រាប់អ្នកសម្របសម្រួល៖**

**២.១ កិច្ចការ៖ ការអនុវត្ត** CEDAW (៣០ នាទី)

បំបែកសិក្ខាកាមជាក្រុមតូចៗ និងផ្តល់ជូនសិក្ខាកាមម្នាក់ៗនូវសំណៅចម្លងមួយច្បាប់នៃ ឯកសារ ៣.៣.១ CEDAW (មើលក្នុងឧបសម្ព័ន្ធ) ដើម្បីឲ្យពួកគេអាន និងផ្ទាំងក្រដាសធំ និងបិចមួយចំនួន។

បង្ហាញស្លាយកិច្ចការ។

## កិច្ចការអំពី CEDAW

ចូរអានសេចក្តីសង្ខេបអំពី CEDAW និងពិភាក្សាជាមួយក្រុមរបស់អ្នកអំពីសំណួរខាងក្រោម៖

- តើមាត្រាណាខ្លះដែលត្រូវបានយកមកអនុវត្តនៅក្នុងការងាររបស់មន្ត្រីអនុវត្តច្បាប់?
- តើមាត្រាទាំងនោះបានណែនាំ ឬជួយដល់ការបំពេញការងាររបស់អ្នកយ៉ាងដូចម្តេចខ្លះ?
- តើមាត្រាណាខ្លះដែលក្រុមមន្ត្រីអនុវត្តច្បាប់យកមកប្រើប្រាស់ហើយមានរូបភាពដូចជានិយោជកម្នាក់?
- តើមាត្រានោះបានណែនាំ ឬជួយដល់ការបំពេញការងាររបស់អ្នកយ៉ាងដូចម្តេចខ្លះ?

UNODC United Nations Office on Drugs and Crime

UN WOMEN

[20] http://www.scottishhumanrights.com/media/1409/shrc_hrba_leaflet.pdf.

## ២.២ ការប្រជុំក្រុម (៣០ នាទី)

ប្រមូលមតិត្រឡប់របស់សិក្ខាកាម វាអាចនឹងមានការបកស្រាយខុសៗគ្នាជាច្រើន ដែលអាចលើកជាអំណះអំណាងសម្រាប់សំណួរពីរដំបូង ខាងក្រោមគឺជាចំណុចមួយចំនួនដែលកាន់តែគួរឲ្យកត់សម្គាល់ថែមទៀត។

| មាត្រា | ការអនុវត្តនៅក្នុងក្រុមការងារអនុវត្តច្បាប់ |
|---|---|
| **៣. ធានាចំពោះសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន**<br>រដ្ឋាភិបាលត្រូវចាត់វិធានការលើគ្រប់វិស័យទាំងអស់ដូចជា វិស័យនយោបាយ សង្គមកិច្ច សេដ្ឋកិច្ច និងវប្បធម៌ ដើម្បីធានាថាកុមារី និងស្ត្រីអាចទទួលបានសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន។ | ក្រុមការងារអនុវត្តច្បាប់ទទួលខុសត្រូវចំពោះការត្រួតពិនិត្យថាសិទ្ធិនានាត្រូវបានអនុវត្តតាម និងត្រូវបានអនុវត្ត ទាំងនៅក្នុងចំណោមប្រជាពលរដ្ឋ និងនៅក្នុងក្រុមការងាររបស់ពួកគេផ្ទាល់ផងដែរ។ |
| **៥. តួនាទីដែលផ្អែកលើផ្នត់គំនិត**<br>រដ្ឋាភិបាលត្រូវធ្វើការដើម្បីកែប្រែផ្នត់គំនិតនានាអំពីកុមារី និងស្ត្រី និងកុមារា និងបុរស ជាពិសេសប្រសិនបើតួនាទីទាំងនេះផ្អែកលើគំនិតដែលថាកុមារា និងបុរសត្រូវបានចាត់ទុកថាល្អជាងស្ត្រី និងកុមារីនោះ។ | ចំណុចនេះគួរតែត្រូវបានឆ្លុះបញ្ចាំងនៅក្នុងគោលនយោបាយជ្រើសរើសមន្ត្រីរបស់មន្ត្រីក្នុងការងារអនុវត្តច្បាប់។ |
| **៦. ការជួញដូរ និងពេស្យាកម្ម**<br>រដ្ឋាភិបាលត្រូវចាត់ចំណាត់ការ ដែលរួមបញ្ចូលទាំងការបង្កើតច្បាប់ថ្មីៗ ការបញ្ឈប់ការជួញដូរ និងការកេងប្រវ័ញ្ចលើពេស្យាកម្មកុមារី និងស្ត្រីផងដែរ។ | ក្រុមការងារអនុវត្តច្បាប់ជម្រុញឲ្យមានការឆ្លើយតប និងការស៊ើបអង្កេត |

| | |
|---|---|
| **៧. ជីវិតនយោបាយ និងជីវិតសាធារណៈ**<br>ស្ត្រីមានសិទ្ធិស្មើគ្នានៅក្នុងការបោះឆ្នោត និងទទួលបានការបោះឆ្នោតជ្រើសរើសនៅក្នុងមុខតំណែងនានានៅក្នុងជួររដ្ឋាភិបាល។ កុមារី និងស្ត្រីមានសិទ្ធិចូលរួមនៅក្នុងការសម្រេចចិត្តរបស់រដ្ឋាភិបាល និងវិធីដែលរដ្ឋាភិបាលធ្វើការសម្រេចចិត្តទាំងនោះ។ ពួកគេមានសិទ្ធិចូលរួមនៅក្នុងអង្គការមិនមែនរដ្ឋ-ភិបាល (NGOs)។ | នៅក្នុងអំឡុងពេលបោះឆ្នោត នៅពេលខ្លះក្រុមការងារអនុវត្តច្បាប់អាចចូលរួមនៅក្នុង ការរក្សាសន្តិភាព និងធានាថាប្រជាពលរដ្ឋអាចទៅកាន់ស្ថានីយ៍បោះឆ្នោតបាន។ |
| **១១. ការងារ**<br>ស្ត្រីមានសិទ្ធិធ្វើការដូចបុរសដែរ។ ពួកគេគួរតែអាចចូលរួមនៅក្នុងការងារណាមួយតាមជម្រើសរបស់ពួកគេ។ ស្ត្រីត្រូវតែមានឱកាសស្មើគ្នានៅក្នុងការស្វែងរកការងារ ទទួលបានប្រាក់ឈ្នួលស្មើគ្នា ទទួលបានការតម្លើងតំណែង និងការបណ្តុះបណ្តាល និងទទួលបានលក្ខខណ្ឌការងារដែលធ្វើឲ្យមានសុខភាពល្អ និងមានសុវត្ថិភាព។ ស្ត្រីមិនគួរទទួលបានការរើសអើង ដោយសារតែពួកគេបានរៀបអាពាហ៍ពិពាហ៍រួចហើយ ពួកគេមានផ្ទៃពោះ ពួកគេទើបតែមានកូន ឬពួកគេជាអ្នកមើលថែទាំកូននោះទេ។ ស្ត្រីគួរតែទទួលបានជំនួយដូចគ្នាពីរដ្ឋាភិបាល សម្រាប់ការចូលនិវត្តន៍ ភាពគ្មានការងារធ្វើ ការព្យាបាលជំងឺ និងជរាភាព។ | ចំណុចនេះចាំបាច់ត្រូវតែបានឆ្លុះបញ្ចាំង នៅក្នុងគោលនយោបាយធនធានមនុស្ស ឲ្យច្បាស់លាស់ និងតុល្យភាព(ជាក់ស្តែង)។ ពោលគឺ ប្រសិនបើគោលនយោបាយជ្រើសរើសបុគ្គលិកមួយកំណត់លក្ខខណ្ឌផ្នែករាងកាយ ដូចជា កម្ពស់ ជាដើម ដែលមានការពិបាកសម្រាប់ស្ត្រីភាគច្រើននៅក្នុងការបំពេញតាម។ |
| **១២. សុខភាព**<br>រដ្ឋាភិបាលត្រូវតែធ្វើឲ្យប្រាកដថា កុមារី និងស្ត្រីមិនទទួលរងការរើសអើងនៅក្នុងការថែទាំសុខភាពនោះទេ។ កុមារី និងស្ត្រីត្រូវតែទទួលបានការថែទាំក្រោមលក្ខខណ្ឌដូចគ្នានឹងកុមារា និងបុរសដែរ។ ជាពិសេស ស្ត្រីមានសិទ្ធិទទួលបានសេវានានាដែលទាក់ទងនឹងការធ្វើផែនការគ្រួសារ និងការមានផ្ទៃពោះ។ | ចំណុចនេះមានទំនាក់ទំនងទៅវិញទៅមកជាមួយនឹងករណីជួញដូរមនុស្ស និងការថែទាំជនរងគ្រោះនៅពេលក្រោយ (after care)។ |

| | |
|---|---|
| **១៣. ជីវិតខាងសេដ្ឋកិច្ច និងសង្គមកិច្ច**<br>កុមារី និងស្ត្រីមានសិទ្ធិដូចគ្នានឹងកុមារា និងបុរសនៅគ្រប់វិស័យទាំងអស់នៃជីវិត ទាំងខាងសេដ្ឋកិច្ច និងសង្គមកិច្ច ដូចជា ការទទួលបានអត្ថប្រយោជន៍ផ្នែកគ្រួសារ ការទទួលបានកម្ចីធនាគារ និងការចូលរួមលេងកីឡា និងការចូលរួមនៅក្នុងជីវិតតាមបែបវប្បធម៌ជាដើម។ | ធានាថា ទម្លាប់អនុវត្តការងារប្រកបដោយភាពយុត្តិធម៌ត្រូវបានប្រកាន់ខ្ជាប់ និងថាស្ត្រី និងកុមារីមិនស្ថិតនៅក្រោមទម្លាប់អនុវត្តមិនល្អ ឬមិនស្របច្បាប់នោះទេ។ |
| **១៥. ច្បាប់**<br>កុមារី និងស្ត្រី និងកុមារា និងបុរស មានឋានៈស្មើគ្នានៅចំពោះមុខច្បាប់ រួមបញ្ចូលទាំងច្បាប់ស្តីពីសេរីភាពនៅក្នុងការធ្វើដំណើរទៅកាន់ទីកន្លែងដែលពួកគេជ្រើសរើស ការជ្រើសរើសទីកន្លែងសម្រាប់រស់នៅ ការចុះហត្ថលេខាលើកិច្ចសន្យា និងការទិញ និងលក់ទ្រព្យសម្បត្តិ ផងដែរ។ ស្ត្រីមាន "សមត្ថភាពតាមផ្លូវច្បាប់" ដូចបុរសដែរ។ | មានសារៈសំខាន់នៅក្នុងការធានាថា សិទ្ធិនានាត្រូវបានអនុវត្តតាម។ |
| **១៦. ជីវិតអាពាហ៍ពិពាហ៍ និងជីវិតគ្រួសារ**<br>ស្ត្រីមានសិទ្ធិដូចគ្នានឹងបុរសដែរ នៅក្នុងការជ្រើសរើសអ្នកដែលពួកគេនឹងរៀបអាពាហ៍ពិពាហ៍ជាមួយ កំណត់ចំនួនកូនដែលពួកគេចង់បាន និងមើលថែ នៅពេលដែលកូនៗកើតមក។ ស្ត្រីក៏មានសិទ្ធិស្មើគ្នាចំពោះទ្រព្យសម្បត្តិដែលពួកគេទទួលបានជាមួយស្វាមីរបស់ពួកគេនៅពេលដែលពួកគេរៀបអាពាហ៍ពិពាហ៍ផងដែរ។ ដើម្បីបញ្ឈប់ការរៀបអាពាហ៍ពិពាហ៍នៅវ័យក្មេង រដ្ឋាភិបាលត្រូវតែកំណត់អាយុទាបបំផុតសម្រាប់ការរៀបអាពាហ៍ពិពាហ៍ និងធ្វើឲ្យប្រាកដថា ការកំណត់នេះត្រូវបានគេអនុវត្តតាម។ រាល់ការរៀបអាពាហ៍ពិពាហ៍ទាំងអស់ត្រូវតែបានចុះបញ្ជី (មានកំណត់ត្រាជាផ្លូវការនៅជាមួយរដ្ឋាភិបាល)។ | មានសារៈសំខាន់នៅក្នុងការធានាថា សិទ្ធិនានាត្រូវបានអនុវត្តតាម ជាពិសេសនៅក្នុងករណីជួញដូរមនុស្ស។ |

អ្នកសម្របសម្រួលគួរតែត្រៀមឧទាហរណ៍ក្នុងស្រុក ឬក្រៅស្រុកមួយចំនួន នៅពេលដែលមានការប្រើប្រាស់ CEDAW និងរបៀបវាស់វែងសិទ្ធិមនុស្សផ្សេងទៀត ផ្អែកលើ HRBA ក្នុងប្រតិបត្តិការនៅក្នុងការអនុវត្តច្បាប់។

# ម៉ោងសិក្សាទីបួន

# ការរំឭកមេរៀន និងការបង្កើតផែនការសកម្មភាព

**គោលបំណង៖** ដើម្បីរំឭកឡើងវិញអំពីវគ្គបណ្តុះបណ្តាលនេះ និងបង្កើតផែនការសកម្មភាពមួយសម្រាប់ការចុះអនុវត្តមេរៀនដែលរៀនហើយ

## វត្ថុបំណងនៃការរៀនសូត្រ៖

នៅក្នុងអំឡុងម៉ោងសិក្សានេះ សិក្ខាកាមនឹង...

- រំឭកមាតិការនៃមេរៀនទី ១ឡើងវិញ
- រំឭកឡើងវិញអំពីចំណុចរៀនសូត្រសំខាន់ៗដែលទទួលបានពីមេរៀននេះ
- បង្កើតផែនការសកម្មភាពមួយសម្រាប់ការចុះអនុវត្ត

**ពេលវេលា៖** ៦០ នាទី

| សេចក្តីពណ៌នាអំពីធនធាន | សេចក្តីណែនាំអំពីការត្រៀមសម្ភារៈ |
|---|---|
| រំឭកមេរៀនទី ១ | រៀបចំទុកមុនសម្រាប់ការរំឭកសកម្មភាព |
| សិក្ខាកាមធ្វើការវាយតម្លៃលើមេរៀនទី ១ | អ្នកសម្របសម្រួលនឹងប្រើប្រាស់វិធីសាស្ត្រដែលគេចង់ធ្វើ |
| ៣.៤.១ សំណួរឆ្លុះបញ្ចាំងអំពីផែនការសកម្មភាព | ព្រីនចេញឲ្យម្នាក់មួយច្បាប់ |

## ទិដ្ឋភាពទូទៅនៃម៉ោងសិក្សានេះ

| សកម្មភាព | គោលបំណង | ពេលវេលា |
|---|---|---|
| ១. រំឭកមេរៀន និងការវាយតម្លៃ | ពិនិត្យមើលឡើងវិញនូវ ចំនុចដែលបានរៀនសំខាន់ៗ នៅក្នុងវគ្គ ហើយបង្កើតផែនការសកម្មភាពដើម្បីសម្រាប់ការចុះអនុវត្តមេរៀនដែលបានរៀនហើយ | ៣០ នាទី |
| ២. ផែនការសកម្មភាព | បង្កើតផែនការសកម្មភាពដើម្បីសម្រាប់ការចុះអនុវត្តមេរៀនដែលបានរៀនហើយ | ៣០ នាទី |

## សកម្មភាពទីមួយ៖ រំឭកមេរៀន និងការវាយតម្លៃ

**គោលបំណង៖** ដើម្បីរំឭកឡើងវិញអំពីចំណុចរៀនសូត្រសំខាន់ៗដែលទទួលបានពីវគ្គបណ្តុះបណ្តាលនេះ

**ពេលវេលា៖** ៣០ នាទី

**សេចក្តីណែនាំសម្រាប់អ្នកសម្របសម្រួល៖**

**១.១ រំឭកមេរៀនទី ១** (២០ នាទី)

មានវិធីជាច្រើនដែលអ្នកសម្របសម្រួលអាចចូលមកកាន់ម៉ោងសិក្សានេះបាន ហើយមានយោបល់មួយសម្រាប់អ្នកសម្រប់សម្រួល គឺបច្ចេកទេស «សំណួរចេញពីមួក» ឬ «question out of the hat»។

មុនពេលចាប់ផ្តើមម៉ោងសិក្សានេះ អ្នកសម្របសម្រួលគួរតែសរសេរសំណួរអំពីវគ្គសិក្សានេះនៅលើក្រដាស តូចៗ (គ្រប់គ្រាន់សម្រាប់សិក្ខាកាមម្នាក់មួយសំណួរ) និងបត់ក្រដាសទាំងនោះ ហើយដាក់វានៅក្នុងមួក ឬចានគោម។

ស្នើសុំឲ្យសិក្ខាកាមឈរជារង្វង់ យកសំណួរមួយចេញពីមួក ហើយឆ្លើយតបទៅនឹងសំណួរនោះ។

**១.២ ការវាយតម្លៃវគ្គសិក្សា** (១០ នាទី)

អ្នកសម្របសម្រួលគួរស្នើសុំមតិយោបល់របស់សិក្ខាកាម នៅចុងបញ្ចប់នៃមេរៀន នេះតាមរយៈវិធីសាស្ត្រវាយតម្លៃនិងទម្រង់ ដែលបានណែនាំដោយស្ថាប័នរបស់ពួកគេ ឬនៅក្នុងឧបសម្ព័ន្ធ។

## **សកម្មភាពទីពីរៈ** ការធ្វើផែនការសកម្មភាព

**គោលបំណងៈ** ដើម្បីបង្កើតផែនការសកម្មភាពមួយសម្រាប់ការចុះអនុវត្តមេរៀនដែលបានរៀនហើយ

**ពេលវេលាៈ** ៣០ នាទី

**សេចក្តីណែនាំសម្រាប់អ្នកសម្របសម្រួលៈ**

**២.១ ការបង្កើតផែនការសកម្មភាព**

ផ្តល់ជូនសិក្ខាកាមនូវ ៣.៤.១ ឯកសារនៃផែនការសកម្មភាព និងពន្យល់ថា នៅក្នុងឯកសារនោះ មានសំណួរឆ្លុះបញ្ចាំងជាច្រើន និងគំរូផែនការសកម្មភាពមួយ។

ទុកពេលឲ្យសិក្ខាកាមចំនួន ២០ នាទី ដើម្បីធ្វើការឆ្លុះបញ្ចាំងអំពីខ្លួនឯង និងបំពេញ។

**២.២ ការប្រជុំក្រុម**

អញ្ជើញសិក្ខាកាមឲ្យចែករំលែក អំពីផែនការសកម្មភាពរបស់ពួកគេ ប្រសិនបើពួកគេមានអារម្មណ៍ចង់ធ្វើការចែករំលែក និងឆ្លើយតបទៅនឹងសំណួរចុងក្រោយណាមួយ។

# ឧបសម្ព័ន្ធ

## សម្ភារៈបណ្តុះបណ្តាល

## ១.១.១ យេនឌ័រ និងភេទ

| ភេទ | យេនឌ័រ |
|---|---|
| ស្ត្រីមានក្រូម៉ូសូម X ២ នៅខណៈពេលដែលបុរសមានក្រូម៉ូសូម X ១ និងក្រូម៉ូសូម Y ១ | ស្ត្រីងាយរំជួលចិត្តជាងបុរស |
| ស្ត្រីផ្តល់កំណើតដល់ទារក | ស្ត្រីមានសក់វែងជាងបុរស |
| បុរសមានអរម៉ូនតេស្តូស្តេរ៉ូននៅកម្រិតខ្ពស់ជាងស្ត្រី | បុរសពូកែបើកបរជាងស្ត្រី |
| ស្ត្រីមានអរម៉ូនអេស្ត្រូជែននៅកម្រិតខ្ពស់ជាងបុរស | ស្ត្រីទទួលខុសត្រូវចំពោះការថែទាំកូន |
| ស្ត្រីអាចបំបៅដោះកូនបានស្ត្រីអាចបំបៅដោះកូនបាន | បុរសកាន់តួនាទីដែលមានអំណាចខ្ពស់ភាគច្រើនក្នុងជួររដ្ឋាភិបាល |
| បុរសបែកសម្លេងនៅពេលពេញវ័យ | កុមារាចូលចិត្តពណ៌ខៀវ ហើយកុមារីចូលចិត្តពណ៌ផ្កាឈូក |

ស្ត្រី

បុរស

## ១.១.២ សម្ភារៈ

# គ្រឿងជាត់មុខ

# កាបូបដៃ

# កាសែត

# ក្រវ៉ាត់ ក

ខោជើងវែង

ស្នាំងខ្លះ

រទេះរុញកូនក្មេង

កុំព្យូទ័រយួរដៃ

# រថយន្ត

ការបើកបរ

ការសាងសង់

# ការចម្អិនម្ហូប

# លេងជាមួយកូនៗ

ការសម្អាតផ្ទះ

ដៃរបៀបអាវ

# ចាក់សាំងទ្បាន

# ទៅផ្សារ

# ការរាំ

## ១.១.២ តួនាទី

# គ្រូបង្រៀន

# គិលានុប្បដ្ឋាយិកា

អ្នកនយោបាយ

មេគ្រួសារ

# អ្នកមើលថែទាំកូន

# អ្នកមើលថែ
# មនុស្សចាស់ៗ

# កសិកម្ម

# អ្នកពន្លត់អគ្គីភ័យ

# អ្នកបើកតាក់ស៊ី

# ១.២.១ កញ្ចប់សកម្មភាពស្តីពី គុណភាព អារម្មណ៍ និងអាកប្បកិរិយានៃយេនឌ័រ

សូមពិចារណាលើសំណួរខាងក្រោមនៅពេលអ្នកអានករណីសិក្សានៅក្នុងកញ្ចប់សកម្មភាពនេះ។

១. តើអ្នកគិតថាតួអង្គក្នុងករណីសិក្សាជាបុរសឬស្រីទេ? ចូរពន្យល់ចម្លើយរបស់អ្នក។

២. តើផលប៉ះពាល់អ្វីខ្លះដែលអាចកើតឡើង ពីសកម្មភាពដែលពាក់ព័ន្ធនៅក្នុងការសិក្សាករណី រួមទាំងប្រតិកម្មរបស់ក្រុមគ្រួសារនិងសហគមន៍ និងផលប៉ះពាល់ផ្នែកច្បាប់សេដ្ឋកិច្ច ឬផលប៉ះពាល់រយៈពេលវែង?

៣. តើផលប៉ះពាល់ នឹងខុសគ្នាទេប្រសិនបើបុគ្គល ដែលធ្វើសកម្មភាពនោះជាបុរសឬស្រី? បើដូច្នេះ តើធ្វើដូចម្តេច?

៤. តើអ្នកគិតថាផលប៉ះពាល់ ដែលទាក់ទងនឹងថ្ងៃនេះខុសគ្នាពីជំនាន់ ដែលឪពុកម្តាយ ឬជីដូនជីតារបស់អ្នកនៅក្មេងទេ?

## ករណីសិក្សា ក៖ សាច់រឿងនៃព័ត៌មាន

នគរបាលកំពុងស្វែងរកមនុស្សពីរនាក់ ដែលមានវ័យ ១៦ឆ្នាំ ឈ្មោះ ក្រហម និងខៀវ។ បុគ្គលទាំងពីរនាក់ត្រូវបានជាប់ចោទពី បទលួចចូលទៅក្នុងសាលសហគមន៍មូលដ្ឋានមួយ និងបានចំណាយពេលនៅទីនោះពេញមួយយប់។ នគរបាលក៏បានរកឃើញដបស្រាមួយចំនួន ដែលបានផឹកអស់ និងកញ្ចប់ស្រោមអនាម័យមួយចំនួននៅកន្លែងកើតហេតុផងដែរ។

អ្នកស្រុកម្នាក់ ដែលរស់នៅក្នុងមូលដ្ឋានបានឃើញមនុស្សវ័យក្មេងទាំងពីរនាក់នោះ នៅក្នុងមជ្ឈមណ្ឌល និងបានសួរដេញដោលពួកគេអំពី មូលហេតុដែលពួកគេនៅទីនោះ។ គេបានរាយការណ៍ថា ខៀវ បានប្រែជាខឹងសម្បារ និងប្រើហិង្សាលើអ្នកស្រុកម្នាក់នោះ រហូតទាល់តែ ក្រហម បានអង្វរឲ្យ ខៀវ ឲ្យឈប់ធ្វើទង្វើបែបនោះ បន្ទាប់មកទាំងពីរនាក់នោះក៏រត់គេចខ្លួនទៅបាត់។

គេបានពណ៌នាថា ក្រហម ជាជនងាយរងគ្រោះ និងមានសាវតាគ្រួសារដែលមានការលំបាក នៅខណៈពេលដែលសាលារៀនរបស់ ខៀវ បានរាយការណ៍ថា ពួកគេមានភាពភ្ញាក់ផ្អើលយ៉ាងខ្លាំងចំពោះអាកប្បកិរិយានេះ ពីព្រោះ ខៀវ គឺជាអ្នកកីឡាដែលមានទេពកោសល្យដ៏ខ្លាំងពូកែម្នាក់។

## ករណីសិក្សា ខ៖ អត្ថបទសារព័ត៌មាន

ភេរវករដែលត្រូវបានសង្ស័យម្នាក់ ត្រូវបានចាប់ខ្លួនបន្ទាប់ពីបានសម្រុកចូលទៅក្នុងផ្សារទំនើបមួយ និងបាន គម្រាមបាញ់អ្នកទិញទំនិញដែលគ្មានកំហុសម្នាក់ កាលពីរសៀលថ្ងៃសៅរ៍។

សាក្សីម្នាក់បានរៀបរាប់អំពីហេតុការណ៍នោះថា៖

«ខ្ញុំបានតក់ស្លុតយ៉ាងខ្លាំង ហើយខ្ញុំបានរត់ និងស្រែកនៅពេលដែលខ្ញុំបានឃើញភេរវករចូលទៅក្នុងផ្សារទំនើបនោះ។ ជាសំណាងល្អ ដែលមានផ្ទាំងស្លាកសញ្ញាធំមួយនៅទីនោះ ហើយខ្ញុំបានលាក់ខ្លួននៅខាងក្រោយផ្ទាំងស្លាកសញ្ញាធំនោះ ដូច្នេះពួកគេមើលមិនឃើញខ្ញុំនោះទេ។»

ភេរវករត្រូវបានបញ្ឈប់សកម្មភាព ដោយសារមានម្ចាស់ហាងដ៏អង់អាចក្លាហានម្នាក់ បានបោះបាល់ទៅត្រូវនឹងក្បាលរបស់ភេរវកនោះ និងបានវាយពួកគេឲ្យសន្លប់។

មិត្តភ័ក្តិមួយក្រុមបានប្រាប់អ្នកកាសែតរបស់យើងថា ពួកគេមានការដឹងគុណយ៉ាងខ្លាំងចំពោះទង្វើដ៏អង់អាចក្លាហានរបស់ម្ចាស់ហាងនោះ។

«ពួកយើងស្ថិតនៅក្នុងបារមួយនៅក្នុងផ្សារទំនើបនោះ ពេលកំពុងតែផឹកស្រាបៀរ និងទស្សនាការប្រកួតបាល់ទាត់។ យើងបានចេញទៅខាងក្រៅដើម្បីជក់បារី ពេលនោះយើងបានឃើញភេរវករ កំពុងតែរត់សំដៅមករកយើង។ ចៃដន្យអី វាជាពេលដែលម្ចាស់ហាងម្នាក់នោះបានបោះបាល់ទៅត្រូវនឹងក្បាលរបស់ភេរវករ និងបានវាយពួកគេឲ្យសន្លប់។»

**ករណីសិក្សា គះ ការវាយតម្លៃអំពីខ្សែភាពយន្ត**

សាច់រឿងស្នេហាបាននាំតួអង្គពីររូប ដែលមានឈ្មោះ បៃតង និងក្រហម ឲ្យមកជួបគ្នា។

«បៃតង» ជាមនុស្សដែល ឪពុកម្តាយមិននៅជាមួយគ្នា ព្រោះឪពុកម្តាយគេតែងតែរស់នៅមិនចុះសម្រុង និងមិនមានទំនាក់ទំនងល្អនឹងគ្នា ហើយក៏សម្រេចទៅកន្លែងផ្សេងដើម្បីចាប់ផ្តើមជីវិតថ្មីម្តងទៀត។

«ក្រហម» គឺជាមេធាវីដ៏ជោគជ័យម្នាក់ ដែលទំនងជាមានអ្វីៗគ្រប់យ៉ាង ដែលគេចង់បាននៅក្នុងជីវិតរបស់គេ ប៉ុន្តែនៅពីក្រោយអ្វីដែលយើងមើលឃើញនោះ ក្រហម បានទទួលរងភាពភ័យខ្លាច ដែលលាក់ទុកយ៉ាងជ្រៅនៅក្នុងចិត្ត ដែលបន្សល់ទុកពីការរស់នៅឆ្លងកាត់សង្គ្រាម និងជាលទ្ធផល គាត់មានបញ្ហាញៀនសុរា។

តួអង្គទាំងពីរបានជួបគ្នានៅយប់ធ្លាក់ព្រិលមួយ នៅពេលដែល បៃតង ដើរពីកន្លែងធ្វើការទៅផ្ទះ និងបានឃើញ ក្រហម កំពុងតែដើរទ្រេតទ្រោតចេញពីបារនីយដ្ឋានមួយនៅក្នុងសភាពស្រវឹងស្រា និងត្រូវបានវាយប្លន់ដោយមនុស្សវ័យក្មេងពាក់ស្រោមមុខពីរនាក់។ បៃតងបានចូលទៅជួយសង្គ្រោះ ក្រហម ដោយបានរើសដំបងមួយដើមពីលើកម្រាល និងបានរត់តម្រង់ទៅរកពួកគេ។

បន្ទាប់ពីបានជួយ ក្រហម ឲ្យស្វាងស្រវឹង និងលាងរបួសរបស់គេរួចហើយ អ្នកទាំងពីរបានចាប់ផ្តើមទំនាក់ទំនងមិត្តភាព ដែលមិនទំនងនឹងកើតឡើងមួយ ហើយបង្កើតបានជាស្នេហា។

## ១.៤.១ ផ្ទាំងកាតឥទ្ធិពល

# សាសនា

# នយោបាយ

# ការអប់រំ

# មុខរបរ

# វិស័យព័ត៌មាន/ បណ្តាញសង្គម

# ២.១.១ និយមន័យ អ្នកស្រលាញ់ភេទដូចគ្នា ឬ

ផ្គូផ្គងពាក្យទៅនឹងនិយមន័យត្រឹមត្រូវខាងក្រោម៖

| | |
|---|---|
| បុរសស្រលាញ់ភេទដូចគ្នា | មនុស្សស្រលាញ់ភេទផ្ទុយគ្នា |
| មនុស្សស្រលាញ់ភេទដូចគ្នា | ចន្លោះភេទ** |
| នារីស្រលាញ់ភេទដូចគ្នា | មនុស្សប្តូរភេទ* |

| ពាក្យគន្លឹះ | និយមន័យ |
|---|---|
| | សំដៅលើមនុស្សប្រុសម្នាក់ដែលមានទំនោរផ្លូវចិត្ត ទំនោរផ្នែកមនោសញ្ចេតនា និង/ឬ ទំនោរផ្លូវភេទចំពោះមនុស្សប្រុស។ វាក៏ជាពាក្យទូទៅសម្រាប់កត្តាផ្លូវភេទរបស់មនុស្សស្រីស្រលាញ់ភេទដូចគ្នា និង មនុស្សប្រុសស្រឡាញ់ភេទដូចគ្នាដែរ - មនុស្សស្រីមួយចំនួនកំណត់ខ្លួនឯងថាជាមនុស្សប្រុសស្រឡាញ់ភេទដូចគ្នាច្រើនជាង មនុស្សស្រីស្រលាញ់ភេទដូចគ្នា |
| | សំដៅលើមនុស្សស្រីម្នាក់ដែលមានទំនោរផ្លូវចិត្ត ទំនោរផ្នែកមនោសញ្ចេតនា និង/ឬទំនោរផ្លូវភេទចំពោះមនុស្សស្រី។ |
| | មនុស្សប្តូរភេទ (នៅពេលខ្លះត្រូវបានហៅកាត់ថា «trans») គឺជាកម្រងពាក្យ ដែលត្រូវបានប្រើប្រាស់ដើម្បីបកស្រាយអំពីអត្ត-សញ្ញាណភេទជាច្រើនរបស់អ្នកដែលមានរូបរាង និងចរិកលក្ខណៈខុសប្លែកពីភេទធម្មតា — ដែលរួមមាន មនុស្សប្តូរភេទបន្ទាប់ពីវះកាត់ អ្នកស្លៀកពាក់សម្លៀកបំពាក់ផ្ទុយពីភេទរបស់ខ្លួន (ជួនកាលត្រូវបានគេហៅថា "មនុស្សស្លៀកពាក់ក្លែងខ្លួនភេទផ្ទុយ") និងមនុស្សដែលត្រូវបានគេសម្គាល់ថាជាមនុស្សភេទទីបី។ មនុស្សស្ត្រីប្តូរភេទត្រូវបានគេសម្គាល់ថាជាស្ត្រី ប៉ុន្តែត្រូវបានគេចាត់ថ្នាក់ថាជាបុរសនៅពេលកើត។ មនុស្សប្រុសប្តូរភេទត្រូវបានគេសម្គាល់ថាជាបុរស ប៉ុន្តែត្រូវបានគេចាត់ថ្នាក់ថាជាស្ត្រីនៅពេលកើត។ ស្របពេលជាមួយគ្នានេះ មនុស្សប្តូរភេទដទៃទៀតត្រូវបានគេសម្គាល់ថាគ្មានភេទទាំងពីរ។ មនុស្សប្តូរភេទមួយចំនួនស្វែងរកការវះកាត់ ឬចាក់អ័រម៉ូនដើម្បីរាងកាយរបស់ពួកគេស្របតាមអត្តសញ្ញាណយេនឌ័ររបស់ពួកគេ មនុស្សប្តូរភេទមួយចំនួនទៀតមិនស្វែងរកសេវាទាំងនោះទេ។ |
| | នេះអាចត្រូវបានចាត់ទុកថាជាពាក្យវេជ្ជសាស្ត្រច្រើនជាង ដែលត្រូវបានប្រើប្រាស់ ដើម្បីបកស្រាយអំពីនរណាម្នាក់ដែលមាន ទំនោរផ្លូវចិត្ត ទំនោរផ្នែកមនោសញ្ចេតនា និង/ឬទំនោរផ្លូវភេទចំពោះនរណាម្នាក់ដែលមានភេទដូចគ្នា។ នៅពេលនេះ ពាក្យ "មនុស្សប្រុសស្រលាញ់ភេទដូចគ្នា" ត្រូវបានប្រើជាទូទៅជាង។ |
| | សំដៅលើមនុស្សប្រុសម្នាក់ដែលមានទំនោរផ្លូវចិត្ត ទំនោរផ្នែកមនោសញ្ចេតនា និង/ឬទំនោរផ្លូវភេទចំពោះមនុស្សស្រី ឬមនុស្សស្រីម្នាក់ដែលមានទំនោរផ្លូវចិត្ត ទំនោរផ្នែកមនោសញ្ចេតនា និង/ឬទំនោរផ្លូវភេទចំពោះមនុស្សប្រុស។ |
| | មនុស្សដែលមានចន្លោះភេទបានកើតមកជាមួយនឹងចរិកលក្ខណៈភេទផ្លូវកាយ ឬតាមជីវសាស្ត្រ ដូចជាការវិភាគអំពីសារពាង្គកាយ ផ្លូវភេទ សរីរាង្គបន្តពូជ រចនាបទអ័រម៉ូន និង/ឬរចនាបទក្រូម៉ូសូម ដែលមិនស័ក្តិសមនឹងនិយមន័យធម្មតានៃមនុស្សប្រុស ឬមនុស្សស្រី។ ចរិកលក្ខណៈទាំងនេះអាចមើលឃើញនៅពេលកើត ឬអាចលេចឡើងនៅពេលក្រោយនៅក្នុងជីវិត ជាញឹកញាប់ នៅពេលពេញវ័យ។ មនុស្សដែលមានចន្លោះភេទអាចមានទំនោរផ្លូវភេទ និងអត្តសញ្ញាណភេទណាមួយ។ |

ដកស្រង់ពី https://www.stonewall.org.uk/help-advice/glossary-terms

*https://www.unfe.org/definitions/

**https://www.unfe.org/definitions/

# ២.២.១ កាតតួអង្គ

| | |
|---|---|
| កុមារីអាយុ ១០ ឆ្នាំ ដែលមកក្រុមជាតិជាតិភាគតិច រស់នៅតាមទីជនបទដាច់ស្រយាល នៃប្រទេសមួយដែលទើបតែរងគ្រោះដោយសារទឹកជំនន់ដ៏ធ្ងន់ធ្ងរកាលពីថ្មីៗនេះ។ | បុរសអាយុ ៣៥ ឆ្នាំម្នាក់ ដែលត្រូវជិះរទេះរុញ បន្ទាប់ពីជួបឧបទ្ទវហេតុ នៅក្នុងគ្រឹះស្ថានឧស្សាហកម្មមួយ (គ្មានសំណង)។ គាត់គឺជាឪពុករបស់កូនប្រាំនាក់។ |
| បុរសអាយុ ៤៥ ឆ្នាំម្នាក់ ដែលជាប្រធាននាយកប្រតិបត្តិនៃអាជីវកម្មដ៏ជោគជ័យមួយ។ គាត់គ្មានគ្រួសារនោះទេ និងមានមិត្តភ័ក្តិតែពីរបីនាក់ប៉ុណ្ណោះ។ | នារីអាយុ ២៥ ឆ្នាំម្នាក់ មានកំសោយផ្នែកសោតវិញ្ញាណ និងជួបការលំបាកនៅក្នុងការរៀនសូត្រ។ នាងគឺជាសមាជិកម្នាក់នៃគ្រួសារដ៏ធំមួយដែលមានសមាជិកគ្រួសារច្រើននាក់។ |
| និស្សិតមហាវិទ្យាល័យ ភេទស្រី វ័យ ២៥ឆ្នាំ ដែលជាអ្នករកស៊ីផ្លូវភេទ។ | ក្មេងប្រុស កំព្រា វ័យ ១៥ ឆ្នាំ ដែលត្រូវថែទាំប្អូនបង្កើតរបស់គាត់ដែលមានអាយុ ១០ ឆ្នាំម្នាក់ និង ៨ ឆ្នាំ ម្នាក់។ |
| ស្ត្រីមេម៉ាយ វ័យ ៨០ ឆ្នាំ ដែលរកចំណូលបានតិចជាង ១ ដុល្លារក្នុងមួយថ្ងៃ។ | អ្នកនយោបាយជាស្ត្រី វ័យ ៣៥ ឆ្នាំម្នាក់ ដែលមានផ្ទៃពោះ និងទើបតែក្លាយជាស្ត្រីមេម៉ាយកាលពីថ្មីៗនេះ។ |
| ក្មេងស្រី វ័យ ១៦ ឆ្នាំ ដែលត្រូវបានគេជួញដូរឲ្យទៅធ្វើការនៅក្នុងហាងម៉ាស្សាមួយកន្លែង។ | បុរស ដែលជាប្រធាននាយកប្រតិបត្តិនៃក្រុមហ៊ុនមួយដែលមានតម្លៃរាប់លាន។ |

# ២.២.២ ការកំណត់គោលដៅ

សម្គាល់គោលដៅចំនួនប្រាំ ដែលអ្នកមានបំណងសម្រេចឲ្យបាន នៅក្នុងរយៈពេលបីឆ្នាំបន្ទាប់ខាងមុខ និងដាក់ចំណាត់ថ្នាក់ថាតើអ្នកមានទំនុកចិត្តដល់កម្រិតណាចំពោះសមត្ថភាពរបស់អ្នកនៅក្នុងការសម្រេចឲ្យបាននូវគោលដៅនីមួយៗ។

| សេចក្តីពណ៌នាអំពីគោលដៅ | ដាក់ចំណាត់ថ្នាក់ ថាតើអ្នកមានទំនុកចិត្តដល់កម្រិតណានៅក្នុងការសម្រេចគោលដៅ។<br>១ = គ្មានទាល់តែសោះ<br>៥ = មានទំនុកចិត្តខ្លាំងណាស់ | តើអ្នកមានរបស់ ឬកត្តាអ្វីខ្លះដើម្បីជួយដល់អ្នកនៅក្នុងការសម្រេចគោលដៅរបស់អ្នក? និងតើមានឧបសគ្គអ្វីខ្លះ? |
|---|---|---|
| | ១ ២ ៣ ៤ ៥ | របស់ ឬកត្តា៖<br>ឧបសគ្គ៖ |
| | ១ ២ ៣ ៤ ៥ | របស់ ឬកត្តា៖<br>ឧបសគ្គ៖ |
| | ១ ២ ៣ ៤ ៥ | របស់ ឬកត្តា៖<br>ឧបសគ្គ៖ |
| | ១ ២ ៣ ៤ ៥ | របស់ ឬកត្តា៖<br>ឧបសគ្គ៖ |
| | ១ ២ ៣ ៤ ៥ | របស់ ឬកត្តា៖<br>ឧបសគ្គ៖ |

## ៣.១.១ ប្រភេទហិង្សាយេនឌ័រ

ស្ត្រី

បុរស

ទាំងពីរភេទ

# គំរាមគំហែង

# ហិង្សាផ្លូវកាយ

# រំលោភបំពានខាងផ្លូវចិត្ត (Gas-lighting)

ចេតនាធ្វើឲ្យមានគ្រោះថ្នាក់ខាងផ្លូវកាយ(ដូចជាបើកឡានលឿនខ្លាំង និងប្រឈមនឹងគ្រោះថ្នាក់)

ល្បែងផ្លូវចិត្ត

រួមភេទដោយបង្ខំ

បង្ខាំង ឬរារាំងមិនឲ្យជួប
ជាមួយគ្រួសារ និងមិត្តភក្តិ

ដកសិទ្ធិនៃការទទួល បាន
ហិរញ្ញវត្ថុ

កុហកប្រព័ន្ធយុត្តិធម៌
ព្រហ្មទណ្ឌអំពីជនរងគ្រោះ

ប្រើប្រាស់លុយរបស់ជនរងគ្រោះ

រារាំងមិនឲ្យជួបកូន

កុហកកូន ដើម្បីមិនឲ្យបានជួបអាណាព្យាបាល

ហិង្សាលើផ្លូវភេទ

គំរាមថានឹងធ្វើបាបកូន

គ្រប់គ្រងលើការ
ពន្យាកំណើត

# តាមឃ្លាំមើល(Stalking) ទាំងតាមផ្លូវកាយ និងផ្លូវចិត្ត

# បរិហារកេរ្តិ៍

# បំផ្លាញកេរ្តិ៍ឈ្មោះរបស់ជនរងគ្រោះ

# ការបដិសេធសិទ្ធិទទួលបានទ្រព្យសម្បត្តិ និងសត្វចិញ្ចឹម

# បង្កអន្តរាយដល់ទ្រព្យសម្បត្តិឬសត្វចិញ្ចឹម

# ៣.២.១ កិច្ចការ អំណាច និងការត្រួតត្រា

បុគ្គលម្នាក់ៗនៅក្នុងក្រុមនឹងផ្លាស់វេនគ្នាសម្តែងជាតួអង្គនីមួយៗ។

**ជនបង្កហេតុ**

វាគឺជាការងាររបស់អ្នកនៅក្នុងពិនិត្យមើលកិច្ចការដែលអ្នករួចខ្លួន/ជនរងគ្រោះកំពុងតែធ្វើ។ នៅក្នុងរយៈពេល ៧ នាទីដំបូងនៃកិច្ចការនេះ អ្នកគួរតែផ្តល់យោបល់ អវិជ្ជមាន ទៅកាន់អ្នករួចខ្លួន/ជនរងគ្រោះ ឧទាហរណ៍៖

- អ្នករាងយឺតបន្តិចហើយ តើអ្នកធ្វើឲ្យលឿនជាងនេះបន្តិចមិនបានទេឬ?
- ខ្ញុំមិនចូលចិត្តរបៀបដែលអ្នកកំពុងតែធ្វើនេះទេ។
- តើអ្នកមិនអាចធ្វើឲ្យបានជាងនេះទេឬ?

**អ្នករួចខ្លួន/ជនរងគ្រោះ**

អ្នកមានពេល ១០ នាទី ដើម្បីបញ្ចប់កិច្ចការដែលអ្នកត្រូវបានប្រគល់ជូន។ វាគឺជាទំនួលខុសត្រូវរបស់អ្នកបង្កហេតុនៅក្នុងការមើលអ្នកធ្វើកិច្ចការ និងធ្វើឲ្យប្រាកដថា អ្នកធ្វើវាបានល្អ។

**អ្នកអង្កេតការណ៍**

អ្នកមានតួនាទីមើលទំនាក់ទំនងរវាងជនរងគ្រោះ និងជនបង្កហេតុ កត់សម្គាល់អំពីការប្រែប្រួល និងកត់សម្គាល់ថាតើវាមានអារម្មណ៍យ៉ាងដូចម្តេចនៅក្នុងនាមដើរតួអ្នកអង្កេតការណ៍។

# ៣.៣.១

ខាងក្រោមនេះ គឺជាសេចក្តីសង្ខេបអំពីមាត្រាទាំង ៣០ ដែលត្រូវបានរួមបញ្ចូលនៅក្នុង CEDAW[២១]

| លេខមាត្រា | សេចក្តីសង្ខេប |
|---|---|
| **១. និយមន័យ** | "ការរើសអើងប្រឆាំងនឹងកុមារី និងស្ត្រី មានន័យថា ការប្រព្រឹត្តិ ដោយផ្ទាល់ ឬ ដោយប្រយោល ចំពោះកុមារី និងស្ត្រី ខុសពីការប្រព្រឹត្តិចំពោះកុមារា និងបុរស តាមវិធីមួយដែលរារាំងពួកគេមិនឲ្យអាស្រ័យផលលើសិទ្ធិរបស់ពួកគេ។ |
| **២. វិធានការផ្នែកគោលនយោបាយ** | រដ្ឋាភិបាលមិនត្រូវអនុញ្ញាតឲ្យមានការរើសអើងប្រឆាំងនឹងកុមារី និងស្ត្រីនោះទេ។ ត្រូវតែមានច្បាប់ និងគោលនយោបាយដើម្បីការពារពួកគេពីការរើសអើងណាមួយ។ ច្បាប់ និងគោលនយោបាយជាតិទាំងអស់ត្រូវតែផ្អែកលើសមភាពរវាងកុមារី និងស្ត្រី និងកុមារា និងបុរស។ គួរតែមានការដាក់ទោសចំពោះការមិនអនុវត្តតាមច្បាប់ទាំងនោះ។ |
| **៣. ធានាចំពោះសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន** | រដ្ឋាភិបាលត្រូវចាត់វិធានការលើគ្រប់វិស័យទាំងអស់ ដូចជា វិស័យនយោបាយ សង្គមកិច្ច សេដ្ឋកិច្ច និងវប្បធម៌ ដើម្បីធានាថាកុមារី និងស្ត្រីអាចទទួលបានសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន។ |
| **៤. វិធានការពិសេសៗ** | រដ្ឋាភិបាលគួរតែចាត់វិធានការពិសេសៗ ឬចំណាត់ការពិសេសៗ ដើម្បីបញ្ឈប់ការរើសអើងប្រឆាំងនឹងកុមារី និងស្ត្រី។ ចំណាត់ការពិសេសៗ ដែលអំណោយផលចំពោះកុមារី និងស្ត្រី មិនមែនជាវិធីមួយដែលរើសអើងប្រឆាំងនឹងកុមារា និងបុរសនោះទេ។ តែវិធីសាស្ត្រពិសេសៗទាំងនោះសំដៅលើការបង្កើនល្បឿននៃសមភាពរវាងកុមារី និងស្ត្រី និងកុមារា និងបុរស។ វិធីសាស្ត្រពិសេសៗទាំងនេះគួរតែបន្តអនុវត្តរហូតទាល់តែសម្រេចបាននូវសមភាពរវាងកុមារី និងស្ត្រី និងកុមារា និងបុរស។ |
| **៥. តួនាទីដែលផ្អែកលើផ្នត់គំនិត** | រដ្ឋាភិបាលត្រូវធ្វើការដើម្បីកែប្រែផ្នត់គំនិតនានាអំពីកុមារី និងស្ត្រី និងកុមារា និងបុរស។ ជាពិសេស ប្រសិនបើតួនាទីទាំងនេះផ្អែកលើគំនិតដែលថា កុមារា និងបុរសត្រូវបានចាត់ទុកថាល្អជាងស្ត្រី និងកុមារីនោះ។ |
| **៦. ការជួញដូរ និងពេស្យាកម្ម** | រដ្ឋាភិបាលត្រូវចាត់ចំណាត់ការ ដែលរួមបញ្ចូលទាំងការបង្កើតច្បាប់ថ្មីៗ ការបញ្ឈប់ការជួញដូរ និងការកេងប្រវ័ញ្ចលើពេស្យាកម្មកុមារី និងស្ត្រីផងដែរ។ |

[២១] www.unicef.org/gender/files/CEDAW_In_Brief_For_Adolescent-Web_Version.pdf.

| លេខមាត្រា | សេចក្តីសង្ខេប |
|---|---|
| **៧. ជីវិតនយោបាយ និង ជីវិតសាធារណៈ** | ស្ត្រីមានសិទ្ធិស្មើគ្នានៅក្នុងការបោះឆ្នោត និងទទួលបានការបោះឆ្នោតជ្រើសរើសនៅក្នុងមុខតំណែងនានាក្នុងជួររដ្ឋាភិបាល។ កុមារី និងស្ត្រីមានសិទ្ធិចូលរួមក្នុងការសម្រេចចិត្តរបស់រដ្ឋាភិបាល និងវិធីដែលរដ្ឋាភិបាលធ្វើការសម្រេចចិត្តទាំងនោះ។ ពួកគេត្រូវមានសិទ្ធិចូលរួមនៅក្នុងអង្គការមិនមែនរដ្ឋាភិបាលផងដែរ។ |
| **៨. ការចូលរួមនៅកម្រិតអន្តរជាតិ** | កុមារី និងស្ត្រីមានសិទ្ធិតំណាងឲ្យប្រទេសរបស់ពួកគេនៅកម្រិតអន្តរជាតិ និងចូលបម្រើការងារនៅក្នុងអង្គការអន្តរជាតិ ដូចជា អង្គការសហប្រជាជាតិ សហភាពអឺរ៉ុប និងគណៈកម្មាធិការអន្តរជាតិកាកបាទក្រហម និងអង្គការអន្តរជាតិជាច្រើនទៀត។ |
| **៩. សញ្ជាតិ** | កុមារី និងស្ត្រីមានសិទ្ធិទទួលបានសញ្ជាតិមួយ និងផ្លាស់ប្តូរសញ្ជាតិនោះ ប្រសិនបើពួកគេចង់ផ្លាស់ប្តូរ។ សញ្ជាតិរបស់ស្ត្រីម្នាក់ មិនត្រូវបានផ្លាស់ប្តូរដោយស្វ័យប្រវត្តិ ដោយគ្រាន់តែបន្ទាប់ពីពួកគេបានរៀបអាពាហ៍-ពិពាហ៍រួចនោះទេ ឬពីព្រោះតែស្វាមីរបស់នាងបានផ្លាស់ប្តូរសញ្ជាតិរបស់គាត់នោះទេ។ ស្ត្រីអាចបន្តសញ្ជាតិរបស់ពួកគេទៅឲ្យកូនរបស់ពួកគេបាន ដូចគ្នានឹងបុរសដែរ។ |
| **១០. ការអប់រំ** | រដ្ឋាភិបាលត្រូវតែបញ្ឈប់ការរើសអើងប្រឆាំងនឹងកុមារី និងស្ត្រី នៅក្នុងការអប់រំ។ កុមារី និងស្ត្រីមានសិទ្ធិទទួលបានការអប់រំ ដូចគ្នានឹងកុមារា និងបុរសដែរ។ កុមារី និងស្ត្រីគួរតែទទួលបានការណែនាំអំពីការងារ និងការបណ្តុះបណ្តាលវិជ្ជាជីវៈនៅគ្រប់កម្រិតទាំងអស់ ទទួលបានការសិក្សានៅសាលារៀន ការប្រឡង បុគ្គលិកបង្រៀន អគារសិក្សា និងបរិក្ខារ និងឱកាសទទួលបានអាហារូបករណ៍ និងជំនួយនានា ដូចគ្នានឹងកុមារា និងបុរសដែរ។ កុមារី និងស្ត្រី មានសិទ្ធិចូលរួមលេងកីឡា និងការអប់រំកាយ និងទទួលបានព័ត៌មានជាក់លាក់ដើម្បីធានាចំពោះសុខភាព និងសុខមាលភាពគ្រួសារ។ រដ្ឋាភិបាលគួរតែធ្វើឲ្យប្រាកដថា កុមារីមិនបានបោះបង់ចោលការសិក្សានោះទេ។ ពួកគេក៏គួរតែជួយកុមារី និងស្ត្រីដែលឆាប់បោះបង់ចោលការសិក្សា ឲ្យត្រឡប់ចូលសាលារៀនវិញ និងបញ្ចប់ការសិក្សារបស់ពួកគេ។ |

| លេខមាត្រា | សេចក្តីសង្ខេប |
|---|---|
| **១១. ការងារ** | ស្ត្រីមានសិទ្ធិធ្វើការដូចបុរសដែរ។ ពួកគេគួរតែអាចចូលរួមនៅក្នុងការងារណាមួយតាមជម្រើសរបស់ពួកគេ។ ស្ត្រីត្រូវតែមានឱកាសស្មើគ្នាក្នុងការស្វែងរកការងារ ទទួលបានប្រាក់ឈ្នួលស្មើគ្នា ទទួលបានការតម្លើងតំណែង និងការបណ្តុះ បណ្តាល និងទទួលបានលក្ខខណ្ឌការងារដែលធ្វើឲ្យល្អ និងមានសុវត្ថិភាព។ ស្ត្រីមិនគួរទទួលបានការរើសអើង ដោយសារតែពួកគេបានរៀបអាពាហ៍ពិពាហ៍រួចហើយ ពួកគេមានផ្ទៃពោះ ពួកគេទើបតែមានកូន ឬពួកគេជាអ្នកថែទាំកូននោះទេ។ ស្ត្រីគួរទទួលបានជំនួយដូចគ្នាពីរដ្ឋាភិបាល សម្រាប់ការចូលនិវត្តន៍ ភាពគ្មានការងារធ្វើ ការព្យាបាលជំងឺ និងជរាភាព។ |
| **១២. សុខភាព** | រដ្ឋាភិបាលត្រូវតែធ្វើឲ្យប្រាកដថា កុមារី និងស្ត្រីមិនទទួលរងការរើសអើងនៅក្នុងការថែទាំសុខភាពនោះទេ។ កុមារី និងស្ត្រីត្រូវតែទទួលបានការថែទាំសុខភាពក្រោមលក្ខខណ្ឌដូចគ្នានឹងកុមារា និងបុរសដែរ។ ជាពិសេស ស្ត្រីមានសិទ្ធិទទួលបានសេវានានាដែលទាក់ទងនឹងការធ្វើផែនការគ្រួសារ និងការមានផ្ទៃពោះ។ |
| **១៣. ជីវិតខាងសេដ្ឋកិច្ច និងសង្គមកិច្ច** | កុមារី និងស្ត្រីមានសិទ្ធិដូចគ្នានឹងកុមារា និងបុរស នៅគ្រប់វិស័យទាំងអស់នៃជីវិតខាងសេដ្ឋកិច្ច និងសង្គមកិច្ច ដូចជា ការទទួលបានអត្ថប្រយោជន៍ផ្នែកគ្រួសារ ការទទួលបានកម្ចីធនាគារ និងការចូលរួមលេងកីឡា និងការចូលរួមនៅក្នុងជីវិតតាមបែបវប្បធម៌ជាដើម។ |
| **១៤. កុមារី និងស្ត្រីនៅតាមជនបទ** | រដ្ឋាភិបាលត្រូវតែធ្វើអ្វីមួយដើម្បីដោះស្រាយបញ្ហារបស់កុមារី និងស្ត្រីដែលរស់នៅតាមទីជនបទ និងជួយដល់ពួកគេនៅក្នុងការមើលថែទាំ និងរួមចំណែកដល់គ្រួសារ និងសហគមន៍របស់ពួកគេ។ កុមារី និងស្ត្រីនៅតាមទីជនបទត្រូវតែទទួលបានការគាំទ្រឲ្យចូលរួមនៅក្នុង និងទទួលបានអត្ថប្រយោជន៍ពីការអភិវឌ្ឍជនបទ ការថែទាំសុខភាពប្រាក់កម្ចី ការអប់រំ និងស្ថានភាពរស់នៅដែលសមស្រប ដូចគ្នានឹងអ្វីដែលកុមារា និងបុរសទទួលបានដែរ។ កុមារី និងស្ត្រីនៅតាមជនបទមានសិទ្ធិបង្កើតក្រុម និងសមាគមផ្ទាល់ខ្លួនរបស់ពួកគេ។ |
| **១៥. ច្បាប់** | កុមារី និងស្ត្រី និងកុមារា និងបុរស មានឋានៈស្មើគ្នានៅចំពោះមុខច្បាប់ រួមបញ្ចូលទាំងច្បាប់ស្តីពីសេរីភាពនៅក្នុងការធ្វើដំណើរទៅកាន់ទីកន្លែងដែលពួកគេជ្រើសរើស ការជ្រើសរើសទីកន្លែងសម្រាប់រស់នៅ ការចុះហត្ថលេខាលើកិច្ចសន្យា និងការទិញ និងលក់ទ្រព្យសម្បត្តិ ផងដែរ។ ស្ត្រីមាន "សមត្ថភាពតាមផ្លូវច្បាប់" ដូចបុរសដែរ។ |

| លេខមាត្រា | សេចក្តីសង្ខេប |
|---|---|
| **១៦. ជីវិតអាពាហ៍ពិពាហ៍ និងជីវិតគ្រួសារ** | ស្ត្រីមានសិទ្ធិដូចគ្នានឹងបុរសដែរ នៅក្នុងការជ្រើសរើសអ្នកដែលពួកគេនឹងរៀបអាពាហ៍ពិពាហ៍ជាមួយ កំណត់ចំនួនកូនដែលពួកគេចង់បាន និងមើលថែ នៅពេលដែលកូនៗកើតមក។ ស្ត្រីក៏មានសិទ្ធិស្មើគ្នាចំពោះទ្រព្យសម្បត្តិដែលពួកគេទទួលបានជាមួយស្វាមីរបស់ពួកគេ នៅពេលដែលពួកគេរៀបអាពាហ៍ពិពាហ៍ផងដែរ។ ដើម្បីបញ្ឈប់ការរៀបអាពាហ៍ពិពាហ៍នៅវ័យក្មេង រដ្ឋាភិបាលត្រូវតែកំណត់អាយុទាបបំផុតសម្រាប់ការរៀបអាពាហ៍ពិពាហ៍ និងធ្វើឲ្យប្រាកដថាការកំណត់នេះត្រូវបានគេអនុវត្តតាម។ រាល់ការរៀបអាពាហ៍ពិពាហ៍ទាំងអស់ត្រូវតែបានចុះបញ្ជី (មានកំណត់ត្រាជាផ្លូវការនៅជាមួយរដ្ឋាភិបាល)។ |
| **មាត្រា ១៧-២២** | មាត្រាទាំងនេះបង្កើតគណៈកម្មាធិការទទួលបន្ទុកការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រី (គណៈកម្មាធិការ CEDAW) ដើម្បីត្រួតពិនិត្យឡើងវិញថាតើមានវឌ្ឍនភាពអ្វីខ្លះដែលត្រូវបានធ្វើឡើងដោយប្រទេសនានា។ មាត្រាទាំងនេះនិយាយអំពីរបៀបធ្វើការរបស់គណៈកម្មាធិការនេះ។ |
| **មាត្រា ២៣-៣០** | មាត្រាទាំងនេះដោះស្រាយជាមួយផ្នែករដ្ឋបាល (ឬការគ្រប់គ្រង) របស់អនុសញ្ញានេះ។ មាត្រាទាំងនេះនិយាយអំពីរបៀបដែលអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលទាំងឡាយគួរតែធ្វើការជាមួយគ្នាដើម្បីធ្វើឲ្យប្រាកដថា សិទ្ធិរបស់កុមារី និងស្ត្រីទទួលបានការការពារ។ មាត្រាទាំងនេះក៏និយាយអំពីរបៀបដោះស្រាយភាពមិនចុះសម្រុងគ្នារវាងរដ្ឋាភិបាលទាំងឡាយពាក់ព័ន្ធនឹងសិទ្ធិរបស់កុមារី និងស្ត្រីផងដែរ។ |

# ៣.៤.១ សំណួរឆ្លុះបញ្ចាំងអំពីការធ្វើផែនការសកម្មភាព

១. តើចំណុចសំខាន់ចំនួន ៣ ណាខ្លះ ដែលអ្នកនឹងចងចាំពីការបណ្តុះបណ្តាលនេះ ហើយនឹងធ្វើការសាកល្បង និងអនុវត្តនៅក្នុងការងាររបស់អ្នកមានអ្វីខ្លះ?

ក. .

ខ. .

គ. .

២. តើអ្នកមានបំណងអនុវត្តចំណុចសំខាន់ៗ ដែលអ្នកបានកំណត់រកឃើញនៅក្នុងសំណួរខាងលើនេះយ៉ាងដូចម្តេច (ត្រូវការរយៈពេលប៉ុន្មានសម្រាប់អនុវត្តចំនុចទាំងនោះ)?

ក. .

ខ. .

គ. .

៣. តើមានផ្នែកណា ឬចំណុចណាមួយ ដែលអ្នកមានបំណងចង់រៀនសូត្របន្ថែមទៀតដែរ ឬទេ?

៤. តើអ្នកនឹងធ្វើផែនការរៀនសូត្របន្ថែម អំពីផ្នែកនានាដែលបានសរសេរនៅក្នុងសំណួរទី ៣ ដោយរបៀបណា?

## មេរៀនទី ១
## ការយល់ដឹងអំពីយេនឌ័រសម្រាប់ក្រុមមន្ត្រីជួរមុខ និងក្រុមការងារអនុវត្តច្បាប់

UNODC
United Nations Office on Drugs and Crime

Regional Office for Southeast Asia and the Pacific
United Nations Building, 3rd floor B Block, Secretariat Building,
Raj Damnern Nok Avenue, Bangkok 10200, Thailand
Tel. (66-2) 288-2100 Fax. (66-2) 281-2129
Email: unodc-thailandfieldoffice@un.org
Website: http://www.unodc.org/southeastasiaandpacific
Twitter: @UNODC_SEAP

UN WOMEN

Regional Office for Asia and the Pacific
United Nations Building, 14th floor, Rajdamnern Nok Avenue,
Bangkok 10200, Thailand
Tel: +66 2 288 2093 Fax: +66 2 280 6030
Email: info.bangkok@unwomen.org
Website: https://asiapacific.unwomen.org/en
Facebook: https://www.facebook.com/unwomenasia/
Twitter: @unwomenasia